# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៧៥

បាលីប្រែ ៩២ - ៩៣

ពុទ្ធសករាជ ២៥៥៣
ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# អភិធម្មបិដក

## និង

# បរមត្ថទីបនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# យមកៈ

## ឆដ្ឋភាគ ~ សត្តមភាគ

# ៧៥

## បាលីប្រែ ៩២~៩៣



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៧៥

# អភិធម្មបិដក

# យមក ឆដ្ឋភាគ

## ឥន្ទ្រិយយមកៈ

## បណ្ណត្តិវារៈ

[ ១ ] ឥន្ទ្រិយ ២២ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ឥត្ថិន្ទ្រិយ ១ បុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ សុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ១ អញ្ញិន្ទ្រិយ ១ អញ្ញាតាវិន្ទ្រិយ ១ ។

### ឧទ្ទេស

[ ២ ] ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ចក្ខុន្ទ្រិយ ក៏ឈ្មោះថា ចក្ខុ ។ សោតៈ ឈ្មោះថា សោតិន្ទ្រិយ សោតិន្ទ្រិយ ក៏ឈ្មោះថា សោតៈ ។ ឃានៈ ឈ្មោះថា ឃានិន្ទ្រិយ ឃានិន្ទ្រិយ ក៏ឈ្មោះថា ឃានៈ ។ ជិវ្ហា ឈ្មោះថា ជិវ្ហិន្ទ្រិយ ជិវ្ហិន្ទ្រិយ ក៏ឈ្មោះថា ជិវ្ហា ។ កាយ ឈ្មោះថា កាយិន្ទ្រិយ កាយិន្ទ្រិយ ក៏ឈ្មោះថា កាយ ។ មនៈ ឈ្មោះថា មនិន្ទ្រិយ មនិន្ទ្រិយ ក៏ឈ្មោះថា មនៈ ។ ឥត្ថី ឈ្មោះថា ឥត្ថិន្ទ្រិយ ឥត្ថិន្ទ្រិយ ក៏ឈ្មោះថា ឥត្ថី ។ បុរិសៈ ឈ្មោះថា បុរិសិន្ទ្រិយ បុរិសិន្ទ្រិយ ក៏ឈ្មោះថា បុរិសៈ ។ ជីវិត ឈ្មោះថា ជីវិតិន្ទ្រិយ

ជីវិតិន្ទ្រិយ ក៏ឈ្មោះថា ជីវិត ។ សុខ ឈ្មោះថា សុខិន្ទ្រិយ សុខិន្ទ្រិយ ក៏ឈ្មោះថា សុខ ។ ទុក្ខ ឈ្មោះថា ទុក្ខិន្ទ្រិយ ទុក្ខិន្ទ្រិយ ក៏ឈ្មោះថា ទុក្ខ ។ សោមនស្ស ឈ្មោះថា សោមនស្សិន្ទ្រិយ សោមនស្សិន្ទ្រិយ ក៏ឈ្មោះថា សោមនស្ស ។ ទោមនស្ស ឈ្មោះថា ទោមនស្សិន្ទ្រិយ ទោមនស្សិន្ទ្រិយ ក៏ឈ្មោះថា ទោមនស្ស ។ ឧបេក្ខា ឈ្មោះថា ឧបេក្ខិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ក៏ឈ្មោះថា ឧបេក្ខា ។ សទ្ធា ឈ្មោះថា សទ្ធិន្ទ្រិយ សទ្ធិន្ទ្រិយ ក៏ឈ្មោះថា សទ្ធា ។ វិរិយៈ ឈ្មោះថា វិរិយិន្ទ្រិយ វិរិយិន្ទ្រិយ ក៏ឈ្មោះថា វិរិយៈ ។ សតិ ឈ្មោះថា សតិន្ទ្រិយ សតិន្ទ្រិយ ក៏ឈ្មោះថា សតិ ។ សមាធិ ឈ្មោះថា សមាធិន្ទ្រិយ សមាធិន្ទ្រិយ ក៏ឈ្មោះថា សមាធិ ។ បញ្ញា ឈ្មោះថា បញ្ញិន្ទ្រិយ បញ្ញិន្ទ្រិយ ក៏ឈ្មោះថា បញ្ញា ។ អនញ្ញាតញ្ញស្សាមីតិ ឈ្មោះថា អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ក៏ឈ្មោះថា អនញ្ញា-តញ្ញស្សាមីតិ ។ អញ្ញៈ ឈ្មោះថា អញ្ញិន្ទ្រិយ អញ្ញិន្ទ្រិយ ក៏ឈ្មោះថា អញ្ញៈ ។ អញ្ញាតាវី ឈ្មោះថា អញ្ញាតាវិន្ទ្រិយ អញ្ញាតាវិន្ទ្រិយ ក៏ឈ្មោះថា អញ្ញាតាវី ។

[ ៣ ] មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនចក្ខុន្ទ្រិយ មិនឈ្មោះថា ចក្ខុ ។ មិនមែន សោតៈ មិនឈ្មោះថា សោតិន្ទ្រិយ មិនមែនសោតិន្ទ្រិយ មិនឈ្មោះថា សោតៈ ។ មិនមែន ឃានៈ មិនឈ្មោះថា ឃានិន្ទ្រិយ មិនមែន ឃានិន្ទ្រិយ មិនឈ្មោះថា ឃានៈ ។ មិនមែនជិវ្ហា មិនឈ្មោះថា ជិវ្ហិន្ទ្រិយ មិនមែន ជិវ្ហិន្ទ្រិយ មិនឈ្មោះថា ជិវ្ហា ។ មិនមែន កាយ មិនឈ្មោះថា កាយិន្ទ្រិយ មិនមែន កាយិន្ទ្រិយ មិនឈ្មោះថា កាយ ។ មិន

មែន មនៈ មិនឈ្មោះថា មនិន្ទ្រិយ មិនមែន មនិន្ទ្រិយ មិនឈ្មោះថា មនៈ ។ មិនមែន ឥត្ថី មិនឈ្មោះថា ឥត្ថិន្ទ្រិយ មិនមែន ឥត្ថិន្ទ្រិយ មិនឈ្មោះថា ឥត្ថី ។ មិនមែន បុរិសៈ មិនឈ្មោះថា បុរិសិន្ទ្រិយ មិនមែន បុរិសិន្ទ្រិយ មិនឈ្មោះថា បុរិសៈ ។ មិនមែន ជីវិត មិនឈ្មោះថា ជីវិតិន្ទ្រិយ មិនមែន ជីវិតិន្ទ្រិយ មិនឈ្មោះថា ជីវិត ។ មិនមែន សុខ មិនឈ្មោះថា សុខិន្ទ្រិយ មិនមែន សុខិន្ទ្រិយ មិនឈ្មោះថា សុខ ។ មិនមែន ទុក្ខ មិនឈ្មោះថា ទុក្ខិន្ទ្រិយ មិនមែន ទុក្ខិន្ទ្រិយ មិនឈ្មោះថា ទុក្ខ ។ មិនមែន សោមនស្ស មិនឈ្មោះថា សោមនស្សិន្ទ្រិយ មិនមែន សោមនស្សិន្ទ្រិយ មិនឈ្មោះថា សោមនស្ស ។ មិនមែន ទោមនស្ស មិនឈ្មោះថា ទោមនស្សិន្ទ្រិយ មិនមែន ទោមនស្សិន្ទ្រិយ មិនឈ្មោះថា ទោមនស្ស ។ មិនមែន ឧបេក្ខា មិនឈ្មោះថា ឧបេក្ខិន្ទ្រិយ មិនមែន ឧបេក្ខិន្ទ្រិយ មិនឈ្មោះថា ឧបេក្ខា ។ មិនមែនសទ្ធា មិនឈ្មោះថា សទ្ធិន្ទ្រិយ មិនមែនសទ្ធិន្ទ្រិយ មិនឈ្មោះថា សទ្ធា ។ មិនមែន វីរិយៈ មិនឈ្មោះថា វីរិយិន្ទ្រិយ មិនមែន វីរិយិន្ទ្រិយ មិនឈ្មោះថា វីរិយៈ ។ មិនមែន សតិ មិនឈ្មោះថា សតិន្ទ្រិយ មិនមែនសតិន្ទ្រិយ មិនឈ្មោះថា សតិ ។ មិនមែន សមាធិ មិនឈ្មោះថា សមាធិន្ទ្រិយ មិនមែន សមាធិន្ទ្រិយ មិនឈ្មោះថា សមាធិ ។ មិនមែន បញ្ញា មិនឈ្មោះថា បញ្ញិន្ទ្រិយ មិនមែន បញ្ញិន្ទ្រិយ មិនឈ្មោះថា បញ្ញា ។ មិនមែន អនញ្ញាតញ្ញស្សាមីតិ មិនឈ្មោះថា អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ មិនមែន អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ មិនឈ្មោះថា អនញ្ញាតញ្ញស្សាមីតិ ។ មិនមែន អញ្ញៈ មិនឈ្មោះថា អញ្ញិន្ទ្រិយ

មិនមែន អញ្ញិន្ទ្រិយ មិនឈ្មោះថា អញ្ញៈ ។ មិនមែន អញ្ញាតាវី មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ មិនមែន អញ្ញាតាវិន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវី ។

[ ៤ ] ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សោតិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ឃានិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ជិវ្ហិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា កាយិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា មនិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ឥត្ថិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា បុរិសិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ជីវិតិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សុខិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ទុក្ខិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សោមនស្សិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ទោមនស្សិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ឧបេក្ខិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សទ្ធិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា វីរិយិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សតិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា

សមាធិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា បញ្ញិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ សោតៈ ឈ្មោះថា សោតិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ សោតៈ ឈ្មោះថា សោតិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ ឃានៈ ឈ្មោះថា ឃានិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឃានៈ ឈ្មោះថា ឃានិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ ជិវ្ហា ឈ្មោះថា ជិវ្ហិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ កាយ ឈ្មោះថា កាយិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មនៈ ឈ្មោះថា មនិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ ឥត្ថី ឈ្មោះថា ឥត្ថិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ បុរិសៈ ឈ្មោះថា បុរិសិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ ជីវិត ឈ្មោះថា ជីវិតិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ សុខ ឈ្មោះថា សុខិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ

ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ ទុក្ខ ឈ្មោះថា ទុក្ខិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ សោមនស្ស ឈ្មោះថា សោមនស្សិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ ទោមនស្ស ឈ្មោះថា ទោមនស្សិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ ឧបេក្ខា ឈ្មោះថា ឧបេក្ខិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ សទ្ធា ឈ្មោះថា សទ្ធិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ វិរិយៈ ឈ្មោះថា វិរិយិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ សតិ ឈ្មោះថា សតិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ សមាធិ ឈ្មោះថា សមាធិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ បញ្ញា ឈ្មោះថា បញ្ញិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ អនញ្ញាតញ្ញស្សាមីតិ ឈ្មោះថា អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ អញ្ញៈ ឈ្មោះថា អញ្ញិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា

ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ អញ្ញាតាវី ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញិន្ទ្រិយ ។

[ ៥ ] មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សោតិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ឃានិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ជិវ្ហិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា កាយិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា មនិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ឥត្ថិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា បុរិសិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ជីវិតិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សុខិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ទុក្ខិន្ទ្រិយ ។ មិនមែនចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សោមនស្សិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ទោមនស្សិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ឧបេក្ខិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួក

ឥន្ទ្រិយ មិនឈ្មោះថា សទ្ធិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា វីរិយិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សតិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សមាធិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា បញ្ញិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន សោតៈ មិនឈ្មោះថា សោតិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន ឃានៈ មិនឈ្មោះថា ឃានិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន ជិវ្ហា មិនឈ្មោះថា ជិវ្ហិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន កាយ មិនឈ្មោះថា កាយិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន មនៈ មិនឈ្មោះថា មនិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន ឥត្ថី មិនឈ្មោះថា ឥត្ថិន្ទ្រិយ

មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន បុរិសៈ មិនឈ្មោះថា បុរិសិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន ជីវិត មិនឈ្មោះថា ជីវិតិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន សុខ មិនឈ្មោះថា សុខិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន ទុក្ខ មិនឈ្មោះថា ទុក្ខិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន សោមនស្ស មិនឈ្មោះថា សោមនស្សិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន ទោមនស្ស មិនឈ្មោះថា ទោម-នស្សិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន ឧបេក្ខា មិនឈ្មោះថា ឧបេក្ខិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន សទ្ធា មិនឈ្មោះថា សទ្ធិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន វីរិយៈ មិនឈ្មោះថា វីរិយិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួក

ឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែនសតិ មិនឈ្មោះថា សតិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែនសមាធិ មិនឈ្មោះថា សមាធិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែនបញ្ញា មិនឈ្មោះថា បញ្ញិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន អនញ្ញតញ្ញស្សាមីតិ មិនឈ្មោះថា អនញ្ញតញ្ញស្សាមីតិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន អញ្ញៈ មិនឈ្មោះថា អញ្ញិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែនអញ្ញាតាវី មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញិន្ទ្រិយ ។

[ ៦ ] ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។ សោតៈ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សោតិន្ទ្រិយ ។ ឃានៈ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ឃានិន្ទ្រិយ ។ ជិវ្ហា ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ជិវ្ហិន្ទ្រិយ ។ កាយ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា កាយិន្ទ្រិយ ។ មនៈ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា មនិន្ទ្រិយ ។ ឥត្ថី ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយ

ទាំងឡាយ ឈ្មោះថា ឥត្ថិន្ទ្រិយ ។ បុរិសៈ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា បុរិសិន្ទ្រិយ ។ ជីវិត ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ជីវិតិន្ទ្រិយ ។ សុខ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សុខិន្ទ្រិយ ។ ទុក្ខ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ទុក្ខិន្ទ្រិយ ។ សោមនស្ស ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សោមនស្សិន្ទ្រិយ ។ ទោមនស្ស ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ទោមនស្សិន្ទ្រិយ ។ ឧបេក្ខា ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ឧបេក្ខិន្ទ្រិយ ។ សទ្ធា ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សទ្ធិន្ទ្រិយ ។ វីរិយៈ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា វីរិយិន្ទ្រិយ ។ សតិ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សតិន្ទ្រិយ ។ សមាធិ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សមាធិន្ទ្រិយ ។ បញ្ញា ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា បញ្ញិន្ទ្រិយ ។ អនញ្ញាតញ្ញស្សាមីតិ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ។ អញ្ញៈ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញិន្ទ្រិយ ។ អញ្ញាតាវី ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។

[ ៧ ] មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។ មិនមែន សោតៈ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សោតិន្ទ្រិយ ។ មិនមែន ឃានៈ មិនឈ្មោះថា

ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ឃានិន្ទ្រិយ ។ មិនមែន ជិវ្ហា មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ជិវ្ហិន្ទ្រិយ ។ មិនមែន កាយ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា កាយិន្ទ្រិយ ។ មិនមែន មនៈ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា មនិន្ទ្រិយ ។ មិនមែន ឥត្ថី មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ឥត្ថិន្ទ្រិយ ។ មិនមែន បុរិសៈ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា បុរិសិន្ទ្រិយ ។ មិនមែន ជីវិត មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ជីវិតិន្ទ្រិយ ។ មិនមែន សុខ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សុខិន្ទ្រិយ ។ មិនមែន ទុក្ខ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ទុក្ខិន្ទ្រិយ ។ មិនមែន សោមនស្ស មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សោមនស្សិន្ទ្រិយ ។ មិនមែន ទោមនស្ស មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ទោមនស្សិន្ទ្រិយ ។ មិនមែន ឧបេក្ខា មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ឧបេក្ខិន្ទ្រិយ ។ មិនមែន សទ្ធា មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សទ្ធិន្ទ្រិយ ។ មិនមែន វីរិយៈ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា វីរិយិន្ទ្រិយ ។ មិនមែន សតិ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សតិន្ទ្រិយ ។ មិនមែន សមាធិ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សមាធិន្ទ្រិយ ។ មិនមែន បញ្ញា មិនឈ្មោះ

ថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា បញ្ញិន្ទ្រិយ ។ មិនមែន អនញ្ញ-តញ្ញស្សាមីតិ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អនញ្ញតញ្ញស្សាមីតិន្ទ្រិយ ។ មិនមែន អញ្ញៈ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញិន្ទ្រិយ ។ មិនមែន អញ្ញាតាវី មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។

[ ៨ ] ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សោតិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ឃានិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ជិវ្ហិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា កាយិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា មនិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ឥត្ថិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា បុរិសិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ជីវិតិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សុខិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ទុក្ខិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សោមនស្សិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ទោមនស្សិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ឧបេក្ខិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សទ្ធិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា

វីរិយិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សតិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សមាធិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា បញ្ញិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អនញ្ញ-តញ្ញស្សាមីតិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញិន្ទ្រិយ ។ ចក្ខុ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញា-តាវិន្ទ្រិយ ។ សោតៈ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ ឃានៈ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ ជិវ្ហា ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញា-តាវិន្ទ្រិយ ។ កាយ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មនៈ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ ឥត្ថី ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតា-វិន្ទ្រិយ ។ បុរិសៈ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ ជីវិត ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ

ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ សុខ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ ទុក្ខ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ សោមនស្ស ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ ទោមនស្ស ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ ឧបេក្ខា ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ សទ្ធា ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតា-វិន្ទ្រិយ ។ វីរិយៈ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ សតិ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ សមាធិ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ បញ្ញា ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ អនញ្ញាតញ្ញស្សាមីតិ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ អញ្ញៈ ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ

ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ អញ្ញាតាវី ឈ្មោះថា ឥន្ទ្រិយ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា អញ្ញិន្ទ្រិយ ។

[ ៩ ] មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សោតិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ឃានិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ជិវ្ហិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា កាយិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា មនិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ឥត្ថិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា បុរិសិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ជីវិតិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សុខិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ទុក្ខិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សោមនស្សិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ទោមនស្សិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ឧបេក្ខិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា

សទ្ធិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា វីរិយិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សតិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សមាធិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា បញ្ញិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញិន្ទ្រិយ ។ មិនមែន ចក្ខុ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន សោតៈ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន ឃានៈ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន ជិវ្ហា មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន កាយ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន មនៈ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន ឥត្ថី មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា

ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន បុរិសៈ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន ជីវិត មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន សុខ មិនឈ្មោះ ថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួក ឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន ទុក្ខ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិន ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន សោមនស្ស មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិន ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន ទោមនស្ស មិនឈ្មោះថា ឥន្ទ្រិយ មិន មែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិន ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន ឧបេក្ខា មិនឈ្មោះថា ឥន្ទ្រិយ មិន មែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិន ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន សទ្ធា មិនឈ្មោះថា ឥន្ទ្រិយ មិនមែន ពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន វិរិយៈ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតា-វិន្ទ្រិយ ។ មិនមែន សតិ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិន

ឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន សមាធិ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន បញ្ញា មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន អនញ្ញតញ្ញស្សាមីតិ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន អញ្ញៈ មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។ មិនមែន អញ្ញាតាវី មិនឈ្មោះថា ឥន្ទ្រិយ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយ ។បេ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញិន្ទ្រិយ ។

ឧទ្ទេសវារៈ ចប់

## និទ្ទេសវារៈ

[ ១០ ] ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ចក្ខុន្ទ្រិយ ឈ្មោះថា ចក្ខុឬ ។ អើ ។ សោតៈ ឈ្មោះថា សោតិន្ទ្រិយឬ ។ ទិព្វសោតៈ តណ្ហាសោតៈ ឈ្មោះថា សោតៈ មិនឈ្មោះថា សោតិន្ទ្រិយទេ ឯសោតិន្ទ្រិយ ទើបឈ្មោះថា សោតៈផង សោតិន្ទ្រិយផង ។ សោតិន្ទ្រិយ ឈ្មោះថា សោតៈឬ ។ អើ ។ ឃានៈ ឈ្មោះថា ឃានិន្ទ្រិយឬ ។ អើ ។

ឃានិន្ទ្រិយ ឈ្មោះថា ឃានៈឬ ។ អើ ។ ជិវ្ហា ឈ្មោះថា ជិវ្ហិន្ទ្រិយឬ ។ អើ ។ ជិវ្ហិន្ទ្រិយ ឈ្មោះថា ជិវ្ហាឬ ។ អើ ។ កាយ ឈ្មោះថា កាយិន្ទ្រិយឬ ។ ពួកធម៌ដ៏សេស លើកតែកាយិន្ទ្រិយចេញ ឈ្មោះថា កាយ មិនឈ្មោះថា កាយិន្ទ្រិយទេ ឯកាយិន្ទ្រិយ ទើបឈ្មោះថា កាយផង កាយិន្ទ្រិយផង ។ កាយិន្ទ្រិយ ឈ្មោះថា កាយឬ ។ អើ ។ មនៈ ឈ្មោះថា មនិន្ទ្រិយឬ ។ អើ ។ មនិន្ទ្រិយ ឈ្មោះថា មនៈឬ ។ អើ ។

[ ១១ ] ឥត្ថី ឈ្មោះថា ឥត្ថិន្ទ្រិយឬ ។ មិនមែនទេ ។ ឥត្ថិន្ទ្រិយ ឈ្មោះថា ឥត្ថីឬ ។ មិនមែនទេ ។ បុរិសៈ ឈ្មោះថា បុរិសិន្ទ្រិយឬ ។ មិនមែនទេ ។ បុរិសិន្ទ្រិយ ឈ្មោះថា បុរិសៈឬ ។ មិនមែនទេ ។ ជីវិត ឈ្មោះថា ជីវិតិន្ទ្រិយឬ ។ អើ ។ ជីវិតិន្ទ្រិយ ឈ្មោះថា ជីវិតឬ ។ អើ ។

[ ១២ ] សុខ ឈ្មោះថា សុខិន្ទ្រិយឬ ។ អើ ។ សុខិន្ទ្រិយ ឈ្មោះថា សុខឬ ។ អើ ។ ទុក្ខ ឈ្មោះថា ទុក្ខិន្ទ្រិយឬ ។ អើ ។ ទុក្ខិន្ទ្រិយ ឈ្មោះថា ទុក្ខឬ ។ អើ ។ សោមនស្ស ឈ្មោះថា សោមនស្សិន្ទ្រិយឬ ។ អើ ។ សោមនស្សិន្ទ្រិយ ឈ្មោះថា សោមនស្សឬ ។ អើ ។ ទោមនស្ស ឈ្មោះថា ទោមនស្សិន្ទ្រិយឬ ។ អើ ។ ទោមនស្សិន្ទ្រិយ ឈ្មោះថា ទោមនស្សឬ ។ អើ ។ ឧបេក្ខា ឈ្មោះថា ឧបេក្ខិន្ទ្រិយឬ ។ ពួកធម៌ដ៏សេស លើកតែឧបេក្ខិន្ទ្រិយចេញ ឈ្មោះថា ឧបេក្ខា ឯឧបេក្ខា មិនឈ្មោះថា ឧបេក្ខិន្ទ្រិយទេ ឧបេក្ខិន្ទ្រិយ ទើបឈ្មោះថា ឧបេក្ខាផង ឧបេក្ខិន្ទ្រិយផង ។ ឧបេក្ខិន្ទ្រិយ ឈ្មោះថា ឧបេក្ខាឬ ។ អើ ។

[ ១៣ ] សទ្ធា ឈ្មោះថា សទ្ធិន្ទ្រិយឬ ។ អើ ។ សទ្ធិន្ទ្រិយ ឈ្មោះថា សទ្ធាឬ ។ អើ ។ វីរិយៈ ឈ្មោះថា វីរិយិន្ទ្រិយឬ ។ អើ ។ វីរិយិន្ទ្រិយ ឈ្មោះថា វីរិយៈឬ ។ អើ ។ សតិ ឈ្មោះថា សតិន្ទ្រិយឬ ។ អើ ។ សតិន្ទ្រិយ ឈ្មោះថា សតិឬ ។ អើ ។ សមាធិ ឈ្មោះថា សមាធិន្ទ្រិយឬ ។ អើ ។ សមាធិន្ទ្រិយ ឈ្មោះថា សមាធិឬ ។ អើ ។ បញ្ញា ឈ្មោះថា បញ្ញិន្ទ្រិយឬ ។ អើ ។ បញ្ញិន្ទ្រិយ ឈ្មោះថា បញ្ញាឬ ។ អើ ។

[ ១៤ ] អនញ្ញាតញ្ញស្សាមីតិ ឈ្មោះថា អនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ អើ ។ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ឈ្មោះថា អនញ្ញាតញ្ញស្សាមីតិឬ ។ អើ ។ អញ្ញៈ ឈ្មោះថា អញ្ញិន្ទ្រិយឬ ។ អើ ។ អញ្ញិន្ទ្រិយ ឈ្មោះថា អញ្ញៈឬ ។ អើ ។ អញ្ញាតាវី ឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។ អញ្ញាតាវិន្ទ្រិយ ឈ្មោះថា អញ្ញាតាវីឬ ។ អើ ។

[ ១៥ ] មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែន ចក្ខុន្ទ្រិយ មិនឈ្មោះថា ចក្ខុឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឈ្មោះថា ចក្ខុតែប៉ុណ្ណោះ ពួកធម៌ដ៏សេស វៀរលែងតែចក្ខុ និងចក្ខុន្ទ្រិយចេញ មិនឈ្មោះថា ចក្ខុផង មិនឈ្មោះថា ចក្ខុន្ទ្រិយផង ។ មិនមែនសោតៈ មិនឈ្មោះថា សោតិន្ទ្រិយឬ ។ អើ ។ មិនមែន សោតិន្ទ្រិយ មិនឈ្មោះថា សោតៈឬ ។ ទិព្វសោតៈ តណ្ហាសោតៈ មិនឈ្មោះថា សោតិន្ទ្រិយទេ ឈ្មោះថា សោតៈតែប៉ុណ្ណោះ ពួកធម៌ដ៏សេស វៀរលែងតែសោតៈ និងសោតិន្ទ្រិយចេញ មិនឈ្មោះថា សោតៈផង មិនឈ្មោះថា សោតិន្ទ្រិយផង ។ មិនមែន

ឃានៈ មិនឈ្មោះថា ឃានិន្ទ្រិយឬ ។ អើ ។ មិនមែន ឃានិន្ទ្រិយ មិនឈ្មោះថា ឃានៈឬ ។ អើ ។ មិនមែន ជិវ្ហា មិនឈ្មោះថា ជិវ្ហិន្ទ្រិយឬ ។ អើ ។ មិនមែន ជិវ្ហិន្ទ្រិយ មិនឈ្មោះថា ជិវ្ហាឬ ។ អើ ។ មិនមែន កាយ មិនឈ្មោះថា កាយិន្ទ្រិយឬ ។ អើ ។ មិនមែន កាយិន្ទ្រិយ មិនឈ្មោះថា កាយឬ ។ ពួកធម៌ដ៏សេស វៀរលែងតែកាយិន្ទ្រិយចេញ មិនឈ្មោះថា កាយិន្ទ្រិយទេ ឈ្មោះថា កាយតែប៉ុណ្ណោះ ពួកធម៌ដ៏សេស វៀរលែងតែកាយ និងកាយិន្ទ្រិយចេញ មិនឈ្មោះថា កាយផង មិនឈ្មោះថា កាយិន្ទ្រិយផង ។ មិនមែន មនៈ មិនឈ្មោះថា មនិន្ទ្រិយឬ ។ អើ ។ មិនមែន មនិន្ទ្រិយ មិនឈ្មោះថា មនៈឬ ។ អើ ។

[ ១៦ ] មិនមែន ឥត្ថី មិនឈ្មោះថា ឥត្ថិន្ទ្រិយឬ ។ ឥត្ថិន្ទ្រិយ មិនឈ្មោះថា ឥត្ថីទេ ឈ្មោះថា ឥត្ថិន្ទ្រិយតែប៉ុណ្ណោះ ពួកធម៌ដ៏សេស វៀរលែងតែឥត្ថី និងឥត្ថិន្ទ្រិយចេញ មិនឈ្មោះថា ឥត្ថីផង មិនឈ្មោះថា ឥត្ថិន្ទ្រិយផង ។ មិនមែន ឥត្ថិន្ទ្រិយ មិនឈ្មោះថា ឥត្ថីឬ ។ ឥត្ថី មិនឈ្មោះថា ឥត្ថិន្ទ្រិយទេ ឈ្មោះថា ឥត្ថីតែប៉ុណ្ណោះ ពួកធម៌ដ៏សេស វៀរលែងតែឥត្ថី និងឥត្ថិន្ទ្រិយចេញ មិនឈ្មោះថា ឥត្ថីផង មិនឈ្មោះថា ឥត្ថិន្ទ្រិយផង ។ មិនមែន បុរិសៈ មិនឈ្មោះថា បុរិសិន្ទ្រិយឬ ។ បុរិសិន្ទ្រិយ មិនឈ្មោះថា បុរិសៈទេ ឈ្មោះថា បុរិសិន្ទ្រិយតែប៉ុណ្ណោះ ពួកធម៌ដ៏សេស វៀរលែងតែបុរិសៈ និងបុរិសិន្ទ្រិយចេញ មិនឈ្មោះថា បុរិសៈផង មិនឈ្មោះថា បុរិសិន្ទ្រិយផង ។ មិនមែន បុរិសិន្ទ្រិយ មិនឈ្មោះថា បុរិសៈឬ ។ បុរិសៈ មិនឈ្មោះថា បុរិសិន្ទ្រិយទេ

ឈ្មោះថា បុរិសៈតែប៉ុណ្ណោះ ពួកធម៌ដ៏សេស វៀរលែងតែបុរិសៈ និងបុរិ-សិន្ទ្រិយចេញ មិនឈ្មោះថា បុរិសៈផង មិនឈ្មោះថា បុរិសិន្ទ្រិយផង ។ មិនមែន ជីវិត មិនឈ្មោះថា ជីវិតិន្ទ្រិយឬ ។ អើ ។ មិនមែន ជីវិតិន្ទ្រិយ មិនឈ្មោះថា ជីវិតឬ ។ អើ ។

[ ១៧ ] មិនមែន សុខ មិនឈ្មោះថា សុខិន្ទ្រិយឬ ។ អើ ។ មិនមែន សុខិន្ទ្រិយ មិនឈ្មោះថា សុខឬ ។ អើ ។ មិនមែន ទុក្ខ មិនឈ្មោះថា ទុក្ខិន្ទ្រិយឬ ។ អើ ។ មិនមែន ទុក្ខិន្ទ្រិយ មិនឈ្មោះថា ទុក្ខឬ ។ អើ ។ មិនមែនសោមនស្ស មិនឈ្មោះថា សោមនស្សិន្ទ្រិយឬ ។ អើ ។ មិនមែន សោមនស្សិន្ទ្រិយ មិនឈ្មោះថា សោមនស្សឬ ។ អើ ។ មិនមែនទោមនស្ស មិនឈ្មោះថា ទោមនស្សិន្ទ្រិយឬ ។ អើ ។ មិនមែន ទោមនស្សិន្ទ្រិយ មិនឈ្មោះថា ទោមនស្សឬ ។ អើ ។ មិនមែន ឧបេក្ខា មិនឈ្មោះថា ឧបេក្ខិន្ទ្រិយឬ ។ អើ ។ មិនមែន ឧបេក្ខិន្ទ្រិយ មិនឈ្មោះថា ឧបេក្ខាឬ ។ ពួកធម៌ដ៏សេស វៀរលែងតែឧបេក្ខិន្ទ្រិយចេញ មិនឈ្មោះថា ឧបេក្ខិន្ទ្រិយទេ ឈ្មោះថា ឧបេក្ខាតែប៉ុណ្ណោះ ពួកធម៌ដ៏សេស វៀរលែងតែឧបេក្ខា និងឧបេក្ខិន្ទ្រិយចេញ មិនឈ្មោះថា ឧបេក្ខាផង មិនឈ្មោះថា ឧបេក្ខិន្ទ្រិយផង ។

[ ១៨ ] មិនមែន សទ្ធា មិនឈ្មោះថា សទ្ធិន្ទ្រិយឬ ។ អើ ។ មិនមែន សទ្ធិន្ទ្រិយ មិនឈ្មោះថា សទ្ធាឬ ។ អើ ។ មិនមែន វីរិយៈ មិនឈ្មោះថា វីរិយិន្ទ្រិយឬ ។ អើ ។ មិនមែន វីរិយិន្ទ្រិយ មិនឈ្មោះថា វីរិយៈឬ ។ អើ ។ មិនមែន សតិ មិនឈ្មោះថា សតិន្ទ្រិយឬ ។ អើ ។ មិនមែន សតិន្ទ្រិយ

មិនឈ្មោះថា សតិឬ ។ អើ ។ មិនមែន សមាធិ មិនឈ្មោះថា សមាធិន្ទ្រិយ ឬ ។ អើ ។ មិនមែន សមាធិន្ទ្រិយ មិនឈ្មោះថា សមាធិឬ ។ អើ ។ មិនមែនបញ្ញា មិនឈ្មោះថា បញ្ញិន្ទ្រិយឬ ។ អើ ។ មិនមែន បញ្ញិន្ទ្រិយ មិនឈ្មោះថា បញ្ញាឬ ។ អើ ។

[ ១៩ ] មិនមែន អនញ្ញាតញ្ញស្សាមីតិ មិនឈ្មោះថា អនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ អើ ។ មិនមែន អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ មិនឈ្មោះថា អនញ្ញាតញ្ញស្សាមីតិឬ ។ អើ ។ មិនមែន អញ្ញៈ មិនឈ្មោះថា អញ្ញិន្ទ្រិយឬ ។ អើ ។ មិនមែន អញ្ញិន្ទ្រិយ មិនឈ្មោះថា អញ្ញៈឬ ។ អើ ។ មិនមែន អញ្ញាតាវី មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។ មិនមែន អញ្ញាតាវិន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវីឬ ។ អើ ។

[ ២០ ] ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា សោតិន្ទ្រិយឬ ។ សោតិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង សោតិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា សោតិន្ទ្រិយទេ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ឃានិន្ទ្រិយឬ ។ ឃានិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ឃានិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ឃានិន្ទ្រិយទេ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ

ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ជិវ្ហិន្ទ្រិយឬ ។ ជិវ្ហិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ឈ្មោះថា ជិវ្ហិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ជិវ្ហិន្ទ្រិយទេ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា កាយិន្ទ្រិយឬ ។ កាយិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង កាយិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា កាយិន្ទ្រិយទេ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា មនិន្ទ្រិយឬ ។ មនិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង មនិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា មនិន្ទ្រិយទេ ។

[ ២១ ] ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា ឥត្ថិន្ទ្រិយឬ ។ ឥត្ថិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ឥត្ថិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ឥត្ថិន្ទ្រិយទេ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ឥន្ទ្រិយទាំងឡាយ ឈ្មោះថា បុរិសិន្ទ្រិយឬ ។ បុរិសិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយ

ផង បុរិសិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា បុរិសិន្ទ្រិយទេ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា ជីវិតិន្ទ្រិយឬ ។ ជីវិតិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ជីវិតិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ជីវិតិន្ទ្រិយទេ ។

[ ២២ ] ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា សុខិន្ទ្រិយឬ ។ សុខិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង សុខិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា សុខិន្ទ្រិយទេ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា ទុក្ខិន្ទ្រិយឬ ។ ទុក្ខិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ទុក្ខិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ទុក្ខិន្ទ្រិយទេ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា សោមនស្សិន្ទ្រិយឬ ។ សោមនស្សិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង សោមនស្សិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា សោមនស្សិន្ទ្រិយទេ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ

បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា ទោមនស្សិន្ទ្រិយឬ ។ ទោមនស្សិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ទោមនស្សិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ទោមនស្សិន្ទ្រិយទេ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា ឧបេក្ខិន្ទ្រិយឬ ។ ឧបេក្ខិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ឧបេក្ខិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ឧបេក្ខិន្ទ្រិយទេ ។

[ ២៣ ] ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា សទ្ធិន្ទ្រិយឬ ។ សទ្ធិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង សទ្ធិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា សទ្ធិន្ទ្រិយទេ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា វីរិយិន្ទ្រិយឬ ។ វីរិយិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង វីរិយិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា វីរិយិន្ទ្រិយទេ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា សតិន្ទ្រិយឬ ។ សតិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយ

ផង សតិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា សតិន្ទ្រិយទេ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា សមាធិន្ទ្រិយឬ ។ សមាធិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង សមាធិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា សមាធិន្ទ្រិយទេ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា បញ្ញិន្ទ្រិយឬ ។ បញ្ញិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង បញ្ញិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា បញ្ញិន្ទ្រិយទេ ។

[ ២៤ ] ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា អនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង អនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា អនញ្ញាតញ្ញស្សាមីតិន្ទ្រិយទេ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា អញ្ញិន្ទ្រិយឬ ។ អញ្ញិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង អញ្ញិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា អញ្ញិន្ទ្រិយ

ទេ ។ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ឈ្មោះថា ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ឯចក្ខុន្ទ្រិយ ទើបឈ្មោះថា ចក្ខុផង ចក្ខុន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អញ្ញាតាវិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង អញ្ញាតាវិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយទេ ។

[ ២៥ ] សោតៈ ឈ្មោះថា សោតិន្ទ្រិយឬ ។ ទិព្វសោតៈ តណ្ហាសោតៈ ឈ្មោះថា សោតៈ មិនឈ្មោះថា សោតិន្ទ្រិយទេ ឯសោតិន្ទ្រិយ ទើបឈ្មោះថា សោតៈផង សោតិន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ចក្ខុន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ចក្ខុន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ។បេ។ សោតៈ ឈ្មោះថា សោតិន្ទ្រិយឬ ។ ទិព្វសោតៈ តណ្ហាសោតៈ ឈ្មោះថា សោតៈ មិនឈ្មោះថា សោតិន្ទ្រិយទេ ឯសោតិន្ទ្រិយ ទើបឈ្មោះថា សោតៈផង សោតិន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អញ្ញាតាវិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង អញ្ញាតាវិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយទេ ។

[ ២៦ ] ឃានៈ ឈ្មោះថា ឃានិន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ចក្ខុន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ចក្ខុន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ។បេ។ ឃានៈ ឈ្មោះថា ឃានិន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។

អញ្ញាតាវិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង អញ្ញាតាវិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយទេ ។

[ ២៧ ] ជិវ្ហា ឈ្មោះថា ជិវ្ហិន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ចក្ខុន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ចក្ខុន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ។បេ។ ជិវ្ហា ឈ្មោះថា ជិវ្ហិន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អញ្ញាតាវិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង អញ្ញាតាវិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយទេ ។

[ ២៨ ] កាយ ឈ្មោះថា កាយិន្ទ្រិយឬ ។ ពួកធម៌ដ៏សេស វៀរលែងតែកាយិន្ទ្រិយចេញ ឈ្មោះថា កាយ មិនឈ្មោះថា កាយិន្ទ្រិយទេ ឯកាយិន្ទ្រិយ ទើបឈ្មោះថា កាយផង កាយិន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ចក្ខុន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ចក្ខុន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ។បេ។ កាយ ឈ្មោះថា កាយិន្ទ្រិយឬ ។ ពួកធម៌ដ៏សេស វៀរលែងតែកាយិន្ទ្រិយចេញ ឈ្មោះថា កាយ មិនឈ្មោះថា កាយិន្ទ្រិយទេ ឯកាយិន្ទ្រិយ ទើបឈ្មោះថា កាយផង កាយិន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អញ្ញាតាវិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង អញ្ញាតាវិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយទេ ។

[ ២៩ ] មនៈ ឈ្មោះថា មនិន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា

ចក្ខុន្ទ្រិយឬ ។ ចក្ខុន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ចក្ខុន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ។បេ។ មនៈ ឈ្មោះថា មនិន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អញ្ញាតាវិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង អញ្ញាតាវិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយទេ ។

[ ៣០ ] ឥត្ថី ឈ្មោះថា ឥត្ថិន្ទ្រិយឬ ។ មិនមែនទេ ។ ពួកឥន្ទ្រិយ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ចក្ខុន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ចក្ខុន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ។បេ។ ឥត្ថី ឈ្មោះថា ឥត្ថិន្ទ្រិយឬ ។ មិនមែនទេ ។ ពួកឥន្ទ្រិយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អញ្ញាតាវិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង អញ្ញាតាវិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយទេ ។

[ ៣១ ] បុរិសៈ ឈ្មោះថា បុរិសិន្ទ្រិយឬ ។ មិនមែនទេ ។ ពួកឥន្ទ្រិយ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ចក្ខុន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ចក្ខុន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ។បេ។ បុរិសៈ ឈ្មោះថា បុរិសិន្ទ្រិយឬ ។ មិនមែនទេ ។ ពួកឥន្ទ្រិយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អញ្ញាតាវិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង អញ្ញាតាវិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយទេ ។

[ ៣២ ] ជីវិត ឈ្មោះថា ជីវិតិន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ចក្ខុន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ចក្ខុន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស

ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ។បេ។ ជីវិត ឈ្មោះថា ជីវិតិន្ទ្រិយ ឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អញ្ញាតាវិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង អញ្ញាតាវិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយទេ ។

[ ៣៣ ] សុខ ឈ្មោះថា សុខិន្ទ្រិយឬ ។ អើ ។បេ។ ទុក្ខ ឈ្មោះថា ទុក្ខិន្ទ្រិយឬ ។ អើ ។បេ។ សោមនស្ស ឈ្មោះថា សោមនស្សិន្ទ្រិយឬ ។ អើ ។បេ។ ទោមនស្ស ឈ្មោះថា ទោមនស្សិន្ទ្រិយឬ ។ អើ ។បេ។ ឧបេក្ខា ឈ្មោះថា ឧបេក្ខិន្ទ្រិយឬ ។ ពួកឧបេក្ខាដ៏សេស វៀរលែងតែឧបេក្ខិន្ទ្រិយចេញ ឈ្មោះថា ឧបេក្ខា មិនឈ្មោះថា ឧបេក្ខិន្ទ្រិយទេ ឯឧបេក្ខិន្ទ្រិយ ទើបឈ្មោះថា ឧបេក្ខាផង ឧបេក្ខិន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ចក្ខុន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ចក្ខុន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ។បេ។ ឧបេក្ខា ឈ្មោះថា ឧបេក្ខិន្ទ្រិយឬ ។ ពួកឧបេក្ខាដ៏សេស វៀរលែងតែឧបេក្ខិន្ទ្រិយចេញ ឈ្មោះថា ឧបេក្ខា មិនឈ្មោះថា ឧបេក្ខិន្ទ្រិយទេ ឯឧបេក្ខិន្ទ្រិយ ទើបឈ្មោះថា ឧបេក្ខាផង ឧបេក្ខិន្ទ្រិយផង ។ ពួកឥន្ទ្រិយ ឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អញ្ញាតាវិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង អញ្ញាតាវិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយទេ ។

[ ៣៤ ] សទ្ធា ឈ្មោះថា សទ្ធិន្ទ្រិយឬ ។ អើ ។បេ។ វីរិយៈ ឈ្មោះថា វីរិយិន្ទ្រិយឬ ។ អើ ។បេ។ សតិ ឈ្មោះថា សតិន្ទ្រិយឬ ។ អើ ។បេ។ សមាធិ

ឈ្មោះថា សមាធិន្ទ្រិយឬ ។ អើ ។បេ។ បញ្ញា ឈ្មោះថា បញ្ញិន្ទ្រិយឬ ។ អើ ។បេ។

[ ៣៥ ] អនញ្ញាតញ្ញស្សាមីតិ ឈ្មោះថា អនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ អើ ។បេ។ អញ្ញៈ ឈ្មោះថា អញ្ញិន្ទ្រិយឬ ។ អើ ។បេ។ អញ្ញាតាវី ឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ចក្ខុន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ចក្ខុន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ។បេ។ អញ្ញាតាវី ឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា អញ្ញិន្ទ្រិយឬ ។ អញ្ញិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង អញ្ញិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា អញ្ញិន្ទ្រិយទេ ។

[ ៣៦ ] មិនមែនចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សោតិន្ទ្រិយឬ ។ អើ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ឃានិន្ទ្រិយឬ ។ អើ ។ មិនមែនចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ជិវ្ហិន្ទ្រិយឬ ។ អើ ។ មិនមែនចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា កាយិន្ទ្រិយឬ ។ អើ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា មនិន្ទ្រិយឬ ។ អើ ។

[ ៣៧ ] មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែន

ពួកឥន្ទ្រិយ មិនឈ្មោះថា ឥត្ថិន្ទ្រិយឬ ។ អើ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា បុរិសិន្ទ្រិយឬ ។ អើ ។ មិនមែនចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ជីវិតិន្ទ្រិយឬ ។ អើ ។

[ ៣៨ ] មិនមែនចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សុខិន្ទ្រិយឬ ។ អើ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ទុក្ខិន្ទ្រិយឬ ។ អើ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សោមនស្សិន្ទ្រិយឬ ។ អើ ។ មិនមែនចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ទោមនស្សិន្ទ្រិយឬ ។ អើ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ឧបេក្ខិន្ទ្រិយឬ ។ អើ ។

[ ៣៩ ] មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សទ្ធិន្ទ្រិយឬ ។ អើ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា វីរិយិន្ទ្រិយឬ ។ អើ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សតិន្ទ្រិយឬ ។ អើ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា សមាធិន្ទ្រិយឬ ។ អើ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា

បញ្ញិន្ទ្រិយឬ ។ អើ ។

[ ៤០ ] មិនមែនចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ អើ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញិន្ទ្រិយឬ ។ អើ ។ មិនមែន ចក្ខុ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។

[ ៤១ ] មិនមែន សោតៈ មិនឈ្មោះថា សោតិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន សោតៈ មិនឈ្មោះថា សោតិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។

[ ៤២ ] មិនមែន ឃានៈ មិនឈ្មោះថា ឃានិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន ឃានៈ មិនឈ្មោះថា ឃានិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។

[ ៤៣ ] មិនមែន ជិវ្ហា មិនឈ្មោះថា ជិវ្ហិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន ជិវ្ហា មិនឈ្មោះថា ជិវ្ហិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញា-តាវិន្ទ្រិយឬ ។ អើ ។

[ ៤៤ ] មិនមែន កាយ មិនឈ្មោះថា កាយិន្ទ្រិយឬ ។ អើ ។ មិន

មែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន កាយ មិនឈ្មោះថា កាយិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។

[ ៤៥ ] មិនមែន មនៈ មិនឈ្មោះថា មនិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន មនៈ មិនឈ្មោះថា មនិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។

[ ៤៦ ] មិនមែន ឥត្ថី មិនឈ្មោះថា ឥត្ថិន្ទ្រិយឬ ។ ឥត្ថិន្ទ្រិយ មិនឈ្មោះថា ឥត្ថីទេ ឈ្មោះថា ឥត្ថិន្ទ្រិយ ពួកធម៌ដ៏សេស វៀរលែងតែឥត្ថី និងឥត្ថិន្ទ្រិយចេញ មិនឈ្មោះថា ឥត្ថីផង មិនឈ្មោះថា ឥត្ថិន្ទ្រិយផង ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន ឥត្ថី មិនឈ្មោះថា ឥត្ថិន្ទ្រិយឬ ។ ឥត្ថិន្ទ្រិយ មិនឈ្មោះថា ឥត្ថីទេ ឈ្មោះថា ឥន្ទ្រិយ ពួកធម៌ដ៏សេស វៀរលែងតែឥត្ថី និងឥត្ថិន្ទ្រិយចេញ មិនឈ្មោះថា ឥត្ថីផង មិនឈ្មោះថា ឥត្ថិន្ទ្រិយផង ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។

[ ៤៧ ] មិនមែន បុរិសៈ មិនឈ្មោះថា បុរិសិន្ទ្រិយឬ ។ បុរិសិន្ទ្រិយ មិនឈ្មោះថា បុរិសៈទេ ឈ្មោះថា បុរិសិន្ទ្រិយ ពួកធម៌ដ៏សេស វៀរលែងតែបុរិសៈ និងបុរិសិន្ទ្រិយចេញ មិនឈ្មោះថា បុរិសៈផង មិនឈ្មោះថា បុរិសិន្ទ្រិយផង ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។

មិនមែន បុរិសៈ មិនឈ្មោះថា បុរិសិន្ទ្រិយឬ ។ បុរិសិន្ទ្រិយ មិនឈ្មោះថា បុរិសៈទេ ឈ្មោះថា បុរិសិន្ទ្រិយ ពួកធម៌ដ៏សេស វៀរលែងតែបុរិសៈ និង បុរិសិន្ទ្រិយចេញ មិនឈ្មោះថា បុរិសៈផង មិនឈ្មោះថា បុរិសិន្ទ្រិយផង ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។

[ ៤៨ ] មិនមែន ជីវិត មិនឈ្មោះថា ជីវិតិន្ទ្រិយឬ ។ អើ ។ មិនមែន ពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន ជីវិត មិន ឈ្មោះថា ជីវិតិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។

[ ៤៩ ] មិនមែន សុខ មិនឈ្មោះថា សុខិន្ទ្រិយឬ ។ អើ ។ មិនមែន ពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន សុខ មិន ឈ្មោះថា សុខិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញា-តាវិន្ទ្រិយឬ ។ អើ ។

[ ៥០ ] មិនមែនទុក្ខ មិនឈ្មោះថា ទុក្ខិន្ទ្រិយឬ ។ អើ ។ មិនមែនពួក ឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន ទុក្ខ មិនឈ្មោះថា ទុក្ខិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។

[ ៥១ ] មិនមែន សោមនស្ស មិនឈ្មោះថា សោមនស្សិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន សោមនស្ស មិនឈ្មោះថា សោមនស្សិន្ទ្រិយឬ ។ អើ ។ មិនមែនពួក

ឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។

[ ៥២ ] មិនមែន ទោមនស្ស មិនឈ្មោះថា ទោមនស្សិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន ទោមនស្ស មិនឈ្មោះថា ទោមនស្សិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។

[ ៥៣ ] មិនមែន ឧបេក្ខា មិនឈ្មោះថា ឧបេក្ខិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន ឧបេក្ខា មិនឈ្មោះថា ឧបេក្ខិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។

[ ៥៤ ] មិនមែន សទ្ធា មិនឈ្មោះថា សទ្ធិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន សទ្ធា មិនឈ្មោះថា សទ្ធិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។

[ ៥៥ ] មិនមែន វីរិយៈ មិនឈ្មោះថា វីរិយិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន វីរិយៈ មិនឈ្មោះថា វីរិយិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។

[ ៥៦ ] មិនមែន សតិ មិនឈ្មោះថា សតិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន សតិ មិន

ឈ្មោះថា សតិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញា-តាវិន្ទ្រិយឬ ។ អើ ។

[ ៥៧ ] មិនមែន សមាធិ មិនឈ្មោះថា សមាធិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន សមាធិ មិនឈ្មោះថា សមាធិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។

[ ៥៨ ] មិនមែន បញ្ញា មិនឈ្មោះថា បញ្ញិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន បញ្ញា មិនឈ្មោះថា បញ្ញិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញា-តាវិន្ទ្រិយឬ ។ អើ ។

[ ៥៩ ] មិនមែន អនញ្ញាតញ្ញស្សាមីតិ មិនឈ្មោះថា អនញ្ញាតញ្ញស្សា-មីតិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន អនញ្ញាតញ្ញស្សាមីតិ មិនឈ្មោះថា អនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។

[ ៦០ ] មិនមែន អញ្ញៈ មិនឈ្មោះថា អញ្ញិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែន អញ្ញៈ មិនឈ្មោះថា អញ្ញិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញា-តាវិន្ទ្រិយឬ ។ អើ ។

[ ៦១ ] មិនមែន អញ្ញាតាវី មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។

មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយឬ ។ អើ ។បេ។ មិនមែនអញ្ញាតាវី មិនឈ្មោះថា អញ្ញាតាវិន្ទ្រិយឬ ។ អើ ។ មិនមែនពួកឥន្ទ្រិយ មិនឈ្មោះថា អញ្ញិន្ទ្រិយឬ ។ អើ ។

[ ៦២ ] ចក្ខុ ឈ្មោះថា ឥន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា ចក្ខុន្ទ្រិយឬ ។ ចក្ខុន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ចក្ខុន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ចក្ខុន្ទ្រិយទេ ។ សោតៈ ឈ្មោះថា ឥន្ទ្រិយឬ ។ ធម្មជាតណា ឈ្មោះថា សោតៈ ឥន្ទ្រិយធម្មជាតនោះ ឈ្មោះថា សោតៈផង ឥន្ទ្រិយផង សោតៈដ៏សេស មិនឈ្មោះថា ឥន្ទ្រិយទេ ។ ពួកឥន្ទ្រិយ ឈ្មោះថា សោតិន្ទ្រិយឬ ។ សោតិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង សោតិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា សោតិន្ទ្រិយទេ ។ ឃានៈ ឈ្មោះថា ឥន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា ឃានិន្ទ្រិយឬ ។ ឃានិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ឃានិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ឃានិន្ទ្រិយទេ ។ ជិវ្ហា ឈ្មោះថា ឥន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា ជិវ្ហិន្ទ្រិយឬ ។ ជិវ្ហិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ជិវ្ហិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ជិវ្ហិន្ទ្រិយទេ ។ កាយ ឈ្មោះថា ឥន្ទ្រិយឬ ។ កាយណា ឈ្មោះថា ឥន្ទ្រិយ កាយនោះ ឈ្មោះថា កាយផង ឥន្ទ្រិយផង កាយដ៏សេស មិនឈ្មោះថា ឥន្ទ្រិយទេ ។ ពួកឥន្ទ្រិយ ឈ្មោះថា កាយិន្ទ្រិយឬ ។ កាយិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង កាយិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ

មិនឈ្មោះថា កាយិន្ទ្រិយទេ ។ មនៈ ឈ្មោះថា ឥន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា មនិន្ទ្រិយឬ ។ មនិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង មនិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា មនិន្ទ្រិយទេ ។

[ ៦៣ ] ឥត្ថី ឈ្មោះថា ឥន្ទ្រិយឬ ។ មិនមែនទេ ។ ពួកឥន្ទ្រិយ ឈ្មោះថា ឥត្ថិន្ទ្រិយឬ ។ ឥត្ថិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ឥត្ថិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ឥត្ថិន្ទ្រិយទេ ។ បុរិសៈ ឈ្មោះថា ឥន្ទ្រិយឬ ។ មិនមែនទេ ។ ពួកឥន្ទ្រិយ ឈ្មោះថា បុរិសិន្ទ្រិយឬ ។ បុរិសិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង បុរិសិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា បុរិសិន្ទ្រិយទេ ។ ជីវិត ឈ្មោះថា ឥន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា ជីវិតិន្ទ្រិយឬ ។ ជីវិតិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ជីវិតិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ជីវិតិន្ទ្រិយទេ ។

[ ៦៤ ] សុខ ឈ្មោះថា ឥន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា សុខិន្ទ្រិយឬ ។ សុខិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង សុខិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា សុខិន្ទ្រិយទេ ។ ទុក្ខ ឈ្មោះថា ឥន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា ទុក្ខិន្ទ្រិយ ទុក្ខិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ទុក្ខិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ទុក្ខិន្ទ្រិយទេ ។ សោមនស្ស ឈ្មោះថា ឥន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា សោមនស្សិន្ទ្រិយឬ ។ សោមនស្សិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង

សោមនស្សិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា សោមនស្សិន្ទ្រិយទេ ។ ទោមនស្ស ឈ្មោះថា ឥន្ទ្រិយឬ ។ អើ ។ ពួកឥន្ទ្រិយ ឈ្មោះថា ទោមនស្សិន្ទ្រិយឬ ។ ទោមនស្សិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ទោមនស្សិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ទោមនស្សិន្ទ្រិយទេ ។ ឧបេក្ខា ឈ្មោះថា ឥន្ទ្រិយឬ ។ ឧបេក្ខាណា ឈ្មោះថា ឥន្ទ្រិយ ឧបេក្ខានោះ ឈ្មោះថា ឧបេក្ខាផង ឥន្ទ្រិយផង ឧបេក្ខាដ៏សេស មិនឈ្មោះថា ឥន្ទ្រិយទេ ។ ពួកឥន្ទ្រិយ ឈ្មោះថា ឧបេក្ខិន្ទ្រិយឬ ។ ឧបេក្ខិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយផង ឧបេក្ខិន្ទ្រិយផង ពួកឥន្ទ្រិយដ៏សេស ឈ្មោះថា ឥន្ទ្រិយ មិនឈ្មោះថា ឧបេក្ខិន្ទ្រិយទេ ។

[ ១០៣ ] ចក្ខុន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា ឃានិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ចក្ខុន្ទ្រិយ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព កាលចូលទៅកាន់រូបាវចរភព កើតឡើងក្នុងទីនោះ ឯឃានិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខុន្ទ្រិយ របស់សត្វអ្នកមានចក្ខុទាំងនោះ ក្រៅនេះ កាលចូលទៅកាន់កាមាវចរភព កើតឡើងផង ឃានិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ឃានិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខុន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ឃានិន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព នឹងកើតឡើង ក្នុងទីនោះ ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ឃានិន្ទ្រិយ របស់សត្វអ្នកមានចក្ខុ ទាំងនោះ កាលចូលទៅកាន់កាមាវចរភព នឹងកើតឡើងផង ចក្ខុន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១០៤ ] ចក្ខុន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា ឥត្ថិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បណ្ដាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព កាលចូលទៅកាន់រូបាវចរភព ពួកបុរសណា សម្ដែងនូវភពពីរ-បី ដោយបុរិសភាពនុ៎ះឯង ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់បដិសន្ធិ ចក្ខុន្ទ្រិយ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ ឯឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខុន្ទ្រិយ របស់សត្វអ្នកមានចក្ខុទាំងនោះ ក្រៅនេះ កាលចូលទៅកាន់កាមា-វចរភព កើតឡើងផង ឥត្ថិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ឥត្ថិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខុន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ឥត្ថិន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព នឹងកើតឡើង ក្នុងទីនោះ ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ឥត្ថិន្ទ្រិយ របស់សត្វអ្នកមានចក្ខុទាំងនោះ កាលចូលទៅកាន់កាមា-វចរភព នឹងកើតឡើងផង ចក្ខុន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១០៥ ] ចក្ខុន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា បុរិសិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បណ្ដាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព កាលចូលទៅកាន់រូបាវចរភព ពួកស្ត្រីណា សម្ដែងនូវភពពីរ-បី ដោយឥត្ថីភាពនុ៎ះឯង ហើយនឹងបរិនិព្វាន កាលស្ត្រីទាំងនោះ ចាប់បដិសន្ធិ ចក្ខុន្ទ្រិយ របស់សត្វទាំងនោះ កើតឡើង ក្នុងទី

នោះ ឯបុរិសិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខុន្ទ្រិយ របស់សត្វអ្នកមានចក្ខុទាំងនោះ ក្រៅនេះ កាលចូលទៅកាន់កាមាវចរភព កើតឡើងផង បុរិសិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត បុរិសិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខុន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ បុរិសិន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព នឹងកើតឡើង ក្នុងទីនោះ ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ បុរិសិន្ទ្រិយ របស់សត្វអ្នកមានចក្ខុទាំងនោះ កាលចូលទៅកាន់កាមាវចរភព នឹងកើតឡើងផង ចក្ខុន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១០៦ ] ចក្ខុន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា ជីវិតិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ចក្ខុន្ទ្រិយ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព កើតឡើងក្នុងទីនោះ ឯជីវិតិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខុន្ទ្រិយ របស់សត្វអ្នកមានចក្ខុទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង ជីវិតិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ជីវិតិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខុន្ទ្រិយ របស់សត្វនោះ កើតឡើងក្នុងទីនោះឬ ។ ជីវិតិន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ នឹងកើតឡើង ក្នុងទីនោះ ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ជីវិតិន្ទ្រិយ របស់សត្វអ្នកមានចក្ខុទាំងនោះ កាល

ចាប់បដិសន្ធិ នឹងកើតឡើងផង ចក្ខុន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១០៧ ] ចក្ខុន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា សោមនស្សិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បណ្ដាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ប្រកប ដោយចក្ខុ កើតឡើង ដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់បដិសន្ធិ ចក្ខុន្ទ្រិយ របស់សត្វទាំងនោះ កើតឡើងក្នុងទីនោះ ឯសោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខុន្ទ្រិយ របស់សត្វអ្នកមានចក្ខុទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង សោមនស្សិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត សោមនស្សិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខុន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ សោមនស្សិន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងនោះ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព នឹងកើតឡើង ក្នុងទីនោះ ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ សោមនស្សិន្ទ្រិយ របស់សត្វអ្នកមានចក្ខុទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង ចក្ខុន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១០៨ ] ចក្ខុន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា ឧបេក្ខិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បណ្ដាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ប្រកបដោយចក្ខុ កើតឡើង ដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់

បដិសន្ធិ ចក្ខុន្ទ្រិយ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខុន្ទ្រិយ របស់សត្វអ្នកមានចក្ខុទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង ឧបេក្ខិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ឧបេក្ខិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខុន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ឧបេក្ខិន្ទ្រិយ របស់ពួកសត្វអ្នកមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព និងពួកអរូបព្រហ្មនោះ នឹងកើតឡើង ក្នុងទីនោះ ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ឧបេក្ខិន្ទ្រិយ របស់សត្វអ្នកមានចក្ខុទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង ចក្ខុន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១០៩ ] ចក្ខុន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា សទ្ធិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ចក្ខុន្ទ្រិយ របស់ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព កើតឡើង ក្នុងទីនោះ ឯសទ្ធិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខុន្ទ្រិយ របស់សត្វអ្នកមានចក្ខុទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង សទ្ធិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត សទ្ធិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខុន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ សទ្ធិន្ទ្រិយ របស់ពួកសត្វអ្នកមិនមានចក្ខុ កាលច្យុតចាកបញ្ច-វោការភព កាលចូលទៅកាន់កាមាវចរភព និងពួកអរូបព្រហ្មនោះ នឹងកើត

ឡើង ក្នុងទីនោះ ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ សទ្ធិន្ទ្រិយ របស់សត្វអ្នកមានចក្ខុទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង ចក្ខុន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១១០ ] ចក្ខុន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា បញ្ញិន្ទ្រិយ ។បេ។ មនិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ចក្ខុន្ទ្រិយ របស់ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព កើតឡើង ក្នុងទីនោះ ឯមនិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខុន្ទ្រិយ របស់សត្វអ្នកមានចក្ខុទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង មនិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខុន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ មនិន្ទ្រិយ របស់ពួកសត្វអ្នកមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព និងពួកអរូបព្រហ្មនោះ នឹងកើតឡើង ក្នុងទីនោះ ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ មនិន្ទ្រិយ របស់សត្វអ្នកមានចក្ខុទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង ចក្ខុន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១១១ ] ឃានិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា ឥត្ថិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ពួកបុរសណា សម្តែងនូវភពពីរបី ដោយបុរិសភាពទុំះឯង ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់

បដិសន្ធិ ឃានិន្ទ្រិយ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ ឯឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឃានិន្ទ្រិយ របស់សត្វអ្នកមានឃានៈទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង ឥត្ថិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ឥត្ថិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឃានិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ឥត្ថិន្ទ្រិយ របស់សត្វអ្នកមិនមានឃានៈទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព នឹងកើតឡើង ក្នុងទីនោះ ឯឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ឥត្ថិន្ទ្រិយ របស់សត្វអ្នកមានឃានៈទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង ឃានិន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១១២ ] ឃានិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា បុរិសិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ពួកស្រ្តីណា សម្រេចនូវភពពីរបី ដោយឥត្ថីភាពនុ៎ះឯង ហើយនឹងបរិនិព្វាន កាលស្រ្តីទាំងនោះចាប់បដិសន្ធិ ឃានិន្ទ្រិយ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ ឯបុរិសិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឃានិន្ទ្រិយ របស់សត្វអ្នកមានឃានៈទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង បុរិសិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត បុរិសិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឃានិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។

បុរិសិន្ទ្រិយ របស់សត្វអ្នកមិនមានឈានៈទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព នឹងកើតឡើង ក្នុងទីនោះ ឯឈានិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ បុរិសិន្ទ្រិយ របស់សត្វអ្នកមានឈានៈទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង ឈានិន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១១៣ ] ឈានិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា ជីវិតិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ឈានិន្ទ្រិយ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព កើតឡើង ក្នុងទីនោះ ឯជីវិតិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឈានិន្ទ្រិយ របស់សត្វអ្នកមានឈានៈទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង ជីវិតិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ជីវិតិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឈានិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ជីវិតិន្ទ្រិយ របស់សត្វអ្នកមិនមានឈានៈទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ នឹងកើតឡើង ក្នុងទីនោះ ឯឈានិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ជីវិតិន្ទ្រិយ របស់សត្វអ្នកមានឈានៈទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង ឈានិន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១១៤ ] ឈានិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា សោមនស្សិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកសត្វ

ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ពួកសត្វណា អ្នកមានឈានៈ កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់បដិសន្ធិ ឈានិន្ទ្រិយ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ ឯសោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឈានិន្ទ្រិយ របស់សត្វអ្នកមានឈានៈទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង សោមនស្សិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត សោមនស្សិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឈានិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ សោមនស្សិន្ទ្រិយ របស់ពួកសត្វអ្នកមិនមានឈានៈ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួករូបាវចរសត្វនោះ នឹងកើតឡើង ក្នុងទីនោះ ឯឈានិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ សោមនស្សិន្ទ្រិយ របស់សត្វអ្នកមានឈានៈទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង ឈានិន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១១៥ ] ឈានិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា ឧបេក្ខិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ពួកសត្វណា អ្នកមានឈានៈ កើតឡើង ដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់បដិសន្ធិ ឈានិន្ទ្រិយ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឈានិន្ទ្រិយ របស់សត្វ

អ្នកមានឈានៈទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង ឧបេក្ខិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ឧបេក្ខិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឈានិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ឧបេក្ខិន្ទ្រិយ របស់ពួកសត្វអ្នកមិនមានឈានៈ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វនោះ នឹងកើតឡើង ក្នុងទីនោះ ឯឈានិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ឧបេក្ខិន្ទ្រិយ របស់សត្វអ្នកមានឈានៈទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង ឈានិន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១១៦ ] ឈានិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា សទ្ធិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ឈានិន្ទ្រិយ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភពនោះ កាលចូលទៅកាន់កាមាវចរភព កើតឡើង ក្នុងទីនោះ ឯសទ្ធិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឈានិន្ទ្រិយ របស់សត្វអ្នកមានឈានៈទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង សទ្ធិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត សទ្ធិន្ទ្រិយរបស់សត្វណា នឹងកើតឡើង ក្នុងទីណា ឈានិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ សទ្ធិន្ទ្រិយ របស់ពួកសត្វអ្នកមិនមានឈានៈ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វនោះ នឹងកើតឡើង ក្នុងទីនោះ ឯឈានិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ សទ្ធិន្ទ្រិយ របស់សត្វអ្នកមានឈានៈទាំងនោះ

កាលចាប់បដិសន្ធិ នឹងកើតឡើងផង ឈានិន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១១៧ ] ឈានិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា បញ្ញិន្ទ្រិយ ។បេ។ មនិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ឈានិន្ទ្រិយ របស់ពួកសត្វ ដែលកើតក្នុងបច្ឆិមភពនោះ កាលចូលទៅកាន់កាមាវចរភព កើតឡើង ក្នុងទីនោះ ឯមនិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឈានិន្ទ្រិយ របស់សត្វអ្នកមានឈានៈទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង មនិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឈានិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ មនិន្ទ្រិយ របស់ពួកសត្វអ្នកមិនមានឈានៈ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វនោះ នឹងកើតឡើងក្នុងទីនោះ ឯឈានិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ មនិន្ទ្រិយ របស់សត្វអ្នកមានឈានៈទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង ឈានិន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១១៨ ] ឥត្ថិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា បុរិសិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកស្ត្រី ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ពួកស្ត្រីណា សម្រេចនូវភពពីរ-បី ដោយឥត្ថីភាពទុះឯង ហើយនឹងបរិនិព្វាន កាលពួកស្ត្រីទាំងនោះ ចាប់បដិសន្ធិ ឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ កើតឡើង ក្នុងទីណា ឯបុរិសិន្ទ្រិយ របស់ស្ត្រីទាំងនោះ

នឹងមិនកើតឡើង ក្នុងទីនោះទេ ឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង បុរិសិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត បុរិសិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឥត្ថិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ បុរិសិន្ទ្រិយ របស់សត្វទាំងនោះ ដែលមិនមែនជាស្ត្រី កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព នឹងកើតឡើង ក្នុងទីនោះ ឯឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ បុរិសិន្ទ្រិយ របស់ស្ត្រីទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង ឥត្ថិន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១១៩ ] ឥត្ថិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា ជីវិតិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ កើតឡើង ក្នុងទីនោះ ឯជីវិតិន្ទ្រិយ របស់ស្ត្រីទាំងនោះ នឹងមិនកើតឡើងក្នុងទីនោះទេ ឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង ជីវិតិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ជីវិតិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឥត្ថិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ជីវិតិន្ទ្រិយ របស់ពួកសត្វមិនមែនជាស្ត្រី កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួករូបាវចរសត្វ និងពួកអរូបាវចរសត្វនោះ នឹងកើតឡើង ក្នុងទីនោះ ឯឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ជីវិតិន្ទ្រិយ របស់ស្ត្រីទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង ឥត្ថិន្ទ្រិយ

កើតឡើងផង ក្នុងទីនោះ ។

[ ១២០ ] ឥត្ថិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា សោមនស្សិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកស្ត្រី ដែលកើតក្នុងបច្ចិមភព កាលចាប់បដិសន្ធិ ពួកស្ត្រីណា កើតឡើង ដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលស្ត្រីទាំងនោះ ចាប់បដិសន្ធិ ឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ កើតឡើង ក្នុងទីនោះ ឯសោមនស្សិន្ទ្រិយ របស់ស្ត្រីទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង សោមនស្សិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត សោមនស្សិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឥត្ថិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ សោមនស្សិន្ទ្រិយ របស់ពួកសត្វមិនមែនជាស្ត្រី កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួករូបាវចរសត្វនោះ នឹងកើតឡើង ក្នុងទីនោះ ឯឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ សោមនស្សិន្ទ្រិយ របស់ស្ត្រីទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង ឥត្ថិន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១២១ ] ឥត្ថិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា ឧបេក្ខិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកស្ត្រី ដែលកើតក្នុងបច្ចិមភព កាលចាប់បដិសន្ធិ ពួកស្ត្រីណា កើតឡើង ដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលស្ត្រីទាំងនោះ ចាប់បដិសន្ធិ ឥត្ថិន្ទ្រិយ របស់ស្ត្រី

ទាំងនោះ កើតឡើង ក្នុងទីនោះ ឯឧបេក្ខិន្ទ្រិយ របស់ស្ត្រីទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង ឧបេក្ខិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ឧបេក្ខិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឥត្ថិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ឧបេក្ខិន្ទ្រិយ របស់ពួកសត្វមិនមែនជាស្ត្រី កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួករូបាវចរសត្វ និងពួកអរូបាវចរសត្វនោះ នឹងកើតឡើង ក្នុងទីនោះ ឯឥត្ថិន្ទ្រិយរបស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ឧបេក្ខិន្ទ្រិយ របស់ស្ត្រីទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង ឥត្ថិន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១២២ ] ឥត្ថិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា សទ្ធិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ កើតឡើង ក្នុងទីនោះ ឯសទ្ធិន្ទ្រិយ របស់ស្ត្រីទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង សទ្ធិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត សទ្ធិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឥត្ថិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ សទ្ធិន្ទ្រិយ របស់ពួកសត្វមិនមែនជាស្ត្រី កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួករូបាវចរសត្វ និងពួកអរូបាវចរសត្វនោះ នឹងកើតឡើង ក្នុងទី

នោះ ឯឥត្ថិន្ទ្រិយ របស់សត្វទាំងនេះ មិនកើតឡើង ក្នុងទីនោះទេ សទ្ធិន្ទ្រិយ របស់ស្ត្រីទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង ឥត្ថិន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១២៣ ] ឥត្ថិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា បញ្ញិន្ទ្រិយ ។បេ។ មនិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ កើតឡើង ក្នុងទីនោះ ឯមនិន្ទ្រិយ របស់ស្ត្រីទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង មនិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឥត្ថិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ មនិន្ទ្រិយរបស់ពួកសត្វ មិនមែនជាស្ត្រី កាលច្យុតចាកកាមាវចរ-ភព កាលចូលទៅកាន់កាមាវចរភព និងពួករូបាវចរសត្វ និងពួកអរូបាវចរ-សត្វនោះ នឹងកើតឡើង ក្នុងទីនោះ ឯឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ មនិន្ទ្រិយ របស់ស្ត្រីទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង ឥត្ថិន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១២៤ ] បុរិសិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា ជីវិតិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បុរិសិន្ទ្រិយ របស់បុរសទាំងនោះ ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ កើតឡើង ក្នុងទីនោះ ឯជីវិតិន្ទ្រិយ របស់បុរសទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ បុរិសិន្ទ្រិយ

របស់បុរសទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង ជីវិតិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ជីវិតិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា បុរិសិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ជីវិតិន្ទ្រិយ របស់ពួកសត្វមិនមែនជាបុរស កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួករូបាវចរសត្វ និងពួកអរូបាវចរសត្វនោះ នឹងកើតឡើង ក្នុងទីនោះ ឯបុរិសិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ជីវិតិន្ទ្រិយ របស់បុរសទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង បុរិសិន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១២៥ ] បុរិសិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា សោមនស្សិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកបុរសដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ពួកបុរសណា កើតឡើង ដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់បដិសន្ធិ បុរិសិន្ទ្រិយ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ ឯសោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ បុរិសិន្ទ្រិយ របស់បុរសទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង សោមនស្សិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត សោមនស្សិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា បុរិសិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ សោមនស្សិន្ទ្រិយ របស់ពួកសត្វមិនមែនជាបុរស កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួករូបាវចរសត្វនោះ នឹងកើត

ឡើង ក្នុងទីនោះ ឯបុរិសិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ សោមនស្សិន្ទ្រិយ របស់បុរសទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង បុរិសិន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១២៦ ] បុរិសិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា ឧបេក្ខិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកបុរសដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ពួកបុរសណា កើតឡើង ដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់បដិសន្ធិ បុរិសិន្ទ្រិយ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ បុរិសិន្ទ្រិយ របស់បុរសទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង ឧបេក្ខិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ឧបេក្ខិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា បុរិសិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ឧបេក្ខិន្ទ្រិយ របស់ពួកសត្វមិនមែនជាបុរស កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួករូបាវចរសត្វ និងពួកអរូបាវចរសត្វនោះ នឹងកើតឡើង ក្នុងទីនោះ ឯបុរិសិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ឧបេក្ខិន្ទ្រិយ របស់បុរសទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង បុរិសិន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១២៧ ] បុរិសិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា សទ្ធិន្ទ្រិយ ។បេ។ បញ្ញិន្ទ្រិយ មនិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។

បុរិសិន្ទ្រិយ របស់បុរសទាំងនោះ ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ កើតឡើង ក្នុងទីនោះ ឯមនិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ បុរិសិន្ទ្រិយ របស់បុរសទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង មនិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា បុរិសិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ មនិន្ទ្រិយ របស់ពួកសត្វមិនមែនជាបុរស កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួករូបាវចរសត្វ និងពួកអរូបាវចរសត្វនោះ នឹងកើតឡើង ក្នុងទីនោះ ឯបុរិសិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ មនិន្ទ្រិយ របស់បុរសទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង បុរិសិន្ទ្រិយ កើតឡើងផង ក្នុងទីនោះ ។

[ ១២៨ ] ជីវិតិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា សោមនស្សិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខា ក្នុងលំដាប់នៃចិត្តណា នឹងកើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ជីវិតិន្ទ្រិយ របស់សត្វទាំងនោះ កាលចូលទៅកាន់អសញ្ញសត្វ កើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ក្នុងទីនោះ ឯសោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ជីវិតិន្ទ្រិយ របស់សត្វទាំងនោះ ក្រៅនេះ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព កើតឡើងផង សោមនស្សិន្ទ្រិយ នឹងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ក្នុងទីនោះ ។ មួយទៀត សោមនស្សិន្ទ្រិយ របស់សត្វណា នឹងកើតឡើង

ក្នុងទីណា ជីវិតិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព នឹងកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ក្នុងទីនោះ ឯជីវិតិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព នឹងកើតឡើងផង ជីវិតិន្ទ្រិយ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ក្នុងទីនោះ ។

[ ១២៩ ] ជីវិតិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា ឧបេក្ខិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បច្ឆិមចិត្តដែលប្រកបដោយសោមនស្ស ក្នុងលំដាប់នៃចិត្តណា នឹងកើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ជីវិតិន្ទ្រិយ របស់សត្វទាំងនោះ កាលចូលទៅកាន់អសញ្ញសត្វ កើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ក្នុងទីនោះ ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ជីវិតិន្ទ្រិយ របស់សត្វទាំងនោះ ក្រៅនេះ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព កើតឡើងផង ឧបេក្ខិន្ទ្រិយ នឹងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ក្នុងទីនោះ ។ មួយទៀត ឧបេក្ខិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ជីវិតិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព នឹងកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ក្នុងទីនោះ ឯជីវិតិន្ទ្រិយ របស់សត្វ

ទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ។ ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព នឹងកើតឡើងផង ជីវិ-តិន្ទ្រិយ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ក្នុងទីនោះ ។

[ ១៣០ ] ជីវិតិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា សទ្ធិន្ទ្រិយ ។បេ។ បញ្ញិន្ទ្រិយ មនិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ជីវិតិន្ទ្រិយ របស់សត្វទាំងនោះ កាលចូលទៅកាន់អសញ្ញសត្វ កើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ក្នុងទីនោះ ឯមនិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ជីវិតិន្ទ្រិយ របស់សត្វទាំងនោះ ក្រៅនេះ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព កើតឡើងផង មនិន្ទ្រិយ នឹងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ក្នុងទីនោះ ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ជីវិតិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ មនិន្ទ្រិយ របស់សត្វទាំងនោះ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព នឹងកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ក្នុងទីនោះ ឯជីវិតិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ មនិន្ទ្រិយ របស់សត្វទាំងនោះ កាលចូលទៅកាន់ចតុ-វោការភព និងបញ្ចវោការភព នឹងកើតឡើងផង ជីវិតិន្ទ្រិយ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ក្នុងទីនោះ ។

[ ១៣១ ] សោមនស្សិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា ឧបេក្ខិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បច្ឆិមចិត្ត ដែល

ប្រកបដោយសោមនស្សិន្ទ្រិយ ក្នុងលំដាប់នៃចិត្តណា នឹងកើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ដែលប្រកបដោយសោមនស្ស សោមនស្សិន្ទ្រិយរបស់សត្វទាំងនោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ក្នុងទីនោះ ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ ដោយសោមនស្ស កើតឡើងផង ឧបេក្ខិន្ទ្រិយ នឹងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រកបដោយសោមនស្ស ក្នុងបវត្តិកាល ក្នុងទីនោះ ។ មួយទៀតឧបេក្ខិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា សោមនស្សិន្ទ្រិយរបស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ឧបេក្ខិន្ទ្រិយ របស់សត្វទាំងអស់នោះ នឹងកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកសោមនស្ស ឯសោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ កាលចាប់បដិសន្ធិដោយសោមនស្ស នឹងកើតឡើងផង សោមនស្សិន្ទ្រិយ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រកបដោយសោមនស្ស ក្នុងបវត្តិកាល ក្នុងទីនោះ ។

[ ១៣២ ] សោមនស្សិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា សទ្ធិន្ទ្រិយ ។បេ។ បញ្ញិន្ទ្រិយ មនិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ដែលប្រកបដោយសោមនស្ស ក្នុងទីនោះ ឯមនិន្ទ្រិយ

របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ ដោយសោមនស្ស កើតឡើងផង មនិន្ទ្រិយ នឹងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រកបដោយសោម-នស្ស ក្នុងបវត្តិកាល ក្នុងទីនោះ ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា សោមនស្សិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ មនិន្ទ្រិយ របស់សត្វទាំងអស់នោះ នឹងកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកសោមនស្ស ក្នុងទីនោះ ឯសោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ មនិន្ទ្រិយ របស់សត្វទាំងនោះ កាលចាប់បដិសន្ធិ ដោយសោមនស្ស នឹងកើតឡើងផង សោមនស្សិន្ទ្រិយ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រកបដោយសោមនស្ស ក្នុងបវត្តិកាល ក្នុងទីនោះ ។

[ ១៣៣ ] ឧបេក្ខិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា សទ្ធិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខា ក្នុងទីនោះ ឯសទ្ធិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ ដោយឧបេក្ខា កើតឡើងផង សទ្ធិន្ទ្រិយ នឹងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រកបដោយឧបេក្ខា ក្នុងបវត្តិកាល ក្នុងទីនោះ ។ មួយទៀត សទ្ធិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឧបេក្ខិន្ទ្រិយ របស់សត្វនោះ កើត

ឡើង ក្នុងទីនោះឬ ។ សទ្ធិន្ទ្រិយ របស់សត្វទាំងអស់នោះ នឹងកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកឧបេក្ខា ក្នុងទីនោះ ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ សទ្ធិន្ទ្រិយ របស់សត្វទាំងនោះ កាលចាប់បដិសន្ធិ ដោយឧបេក្ខា នឹងកើតឡើងផង ឧបេក្ខិន្ទ្រិយ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រកបដោយឧបេក្ខា ក្នុងបវត្តិកាល ក្នុងទីនោះ ។

[ ១៣៤ ] ឧបេក្ខិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា បញ្ញិន្ទ្រិយ ។បេ។ មនិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខា ក្នុងទីនោះ ឯមនិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ ដោយឧបេក្ខា កើតឡើងផង មនិន្ទ្រិយ នឹងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រកបដោយឧបេក្ខា ក្នុងបវត្តិកាល ក្នុងទីនោះ ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឧបេក្ខិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ មនិន្ទ្រិយ របស់សត្វទាំងអស់នោះ នឹងកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកឧបេក្ខា ក្នុងទីនោះ ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ មនិន្ទ្រិយ របស់សត្វទាំងនោះ កាលចាប់បដិសន្ធិ ដោយឧបេក្ខា នឹងកើតឡើងផង ឧបេក្ខិន្ទ្រិយ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែល

ប្រកបដោយឧបេក្ខា ក្នុងបវត្តិកាល ក្នុងទីនោះ ។

[ ១៣៥ ] សទ្ធិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា បញ្ញិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ សទ្ធិន្ទ្រិយ របស់សត្វទាំងនោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ក្នុងទីនោះ ឯបញ្ញិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ សទ្ធិន្ទ្រិយ របស់សត្វដែលប្រកបដោយហេតុទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង បញ្ញិន្ទ្រិយ នឹងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រកបដោយសទ្ធា ក្នុងបវត្តិកាល ក្នុងទីនោះ ។ មួយទៀត បញ្ញិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា សទ្ធិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ បញ្ញិន្ទ្រិយ របស់សត្វទាំងអស់នោះ នឹងកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកសទ្ធា ក្នុងទីនោះ ឯសទ្ធិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ បញ្ញិន្ទ្រិយ របស់សត្វដែលប្រកបដោយហេតុទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង សទ្ធិន្ទ្រិយ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រកបដោយសទ្ធា ក្នុងបវត្តិកាល ក្នុងទីនោះ ។

[ ១៣៦ ] សទ្ធិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា មនិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ សទ្ធិន្ទ្រិយ របស់សត្វទាំងនោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ក្នុងទីនោះ ឯមនិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ សទ្ធិន្ទ្រិយ របស់សត្វដែលប្រកប

ដោយហេតុទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង មនិន្ទ្រិយ នឹងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រកបដោយសទ្ធា ក្នុងបវត្តិកាល ក្នុងទីនោះ ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា សទ្ធិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ មនិន្ទ្រិយ របស់សត្វទាំងអស់នោះ នឹងកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកសទ្ធា ក្នុងទីនោះ ឯសទ្ធិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ មនិន្ទ្រិយ របស់សត្វដែលប្រកបដោយហេតុទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង សទ្ធិន្ទ្រិយ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រកបដោយសទ្ធា ក្នុងបវត្តិកាល ក្នុងទីនោះ ។

[ ១៣៧ ] បញ្ញិន្ទ្រិយ របស់សត្វណា កើតឡើង ក្នុងទីណា មនិន្ទ្រិយ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ បញ្ញិន្ទ្រិយ របស់សត្វទាំងនោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ក្នុងទីនោះ ឯមនិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ បញ្ញិន្ទ្រិយ របស់សត្វជាញាណសម្បយុត្តទាំងនោះ ក្រៅនេះ កាលចាប់បដិសន្ធិ កើតឡើងផង មនិន្ទ្រិយ នឹងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រកបដោយញាណ ក្នុងបវត្តិកាល ក្នុងទីនោះ ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងកើតឡើង ក្នុងទីណា បញ្ញិន្ទ្រិយ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ មនិន្ទ្រិយ របស់សត្វទាំងអស់នោះ នឹងកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកញាណ ក្នុងទីនោះ ឯបញ្ញិន្ទ្រិយ របស់សត្វ

ទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ មនិន្ទ្រិយ របស់សត្វជាញាណសម្បយុត្តទាំងនោះ កាលចាប់បដិសន្ធិ នឹងកើតឡើងផង បញ្ញិន្ទ្រិយ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រកបដោយញាណ ក្នុងបវត្តិកាល ក្នុងទីនោះ ។

[ ១៣៨ ] ចក្ខុន្ទ្រិយ របស់សត្វណា មិនកើតឡើង សោតិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ចក្ខុន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯសោតិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្តាពួកសត្វ ដែលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់អរូបភព ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង សោតិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត សោតិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ចក្ខុន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ចូលទៅកាន់អរូបភព ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់បដិសន្ធិ សោតិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្តាពួកសត្វដែលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់អរូបភព ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត សោតិន្ទ្រិយ របស់សត្វទាំងនោះ នឹង

មិនកើតឡើងផង ចក្ខុន្ទ្រិយ មិនកើតឡើងផង ។

[ ១៣៩ ] ចក្ខុន្ទ្រិយ របស់សត្វណា មិនកើតឡើង ឃានិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ចក្ខុន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង ឃានិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត ឃានិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ចក្ខុន្ទ្រិយរបស់សត្វនោះ មិនកើតឡើងឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់បដិសន្ធិ ឃានិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ឯចក្ខុន្ទ្រិយរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្តាពួកសត្វដែលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ឃានិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខុន្ទ្រិយ មិនកើតឡើងផង ។

[ ១៤០ ] ចក្ខុន្ទ្រិយ របស់សត្វណា មិនកើតឡើង ឥត្ថិន្ទ្រិយ របស់

សត្វនោះ នឹងមិនកើតឡើងឬ ។ ចក្ខុន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វាន ពួកបុរសណា សម្តែងនូវភពពីរ-បី ដោយបុរិសភាពនុ៎ះឯង ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង ឥត្ថិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត ឥត្ថិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ចក្ខុន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វានក្តី ពួកបុរសណា សម្តែងនូវភពពីរ-បី ដោយបុរិសភាពនុ៎ះឯង ហើយនឹងបរិនិព្វានក្តី កាលសត្វទាំងនោះ ចាប់បដិសន្ធិ ឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្តាពួកសត្វដែលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វានក្តី ពួកបុរសណា សម្តែងនូវភពពីរ-បី ដោយបុរិសភាពនុ៎ះឯង ហើយនឹងបរិនិព្វានក្តី កាលសត្វទាំងនោះច្យុត ឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខុន្ទ្រិយ មិនកើតឡើងផង ។

[ ១៤១ ] ចក្ខុន្ទ្រិយ របស់សត្វណា មិនកើតឡើង បុរិសិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ចក្ខុន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯបុរិសិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្តាពួកសត្វ ដែលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វានក្តី ពួកស្ត្រីណា សម្តែងនូវភពពីរ-បី ដោយឥត្ថីភាពទុំះឯង ហើយនឹងបរិនិព្វានក្តី កាលសត្វទាំងនោះច្យុត ចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង បុរិសិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត បុរិសិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ចក្ខុន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វានក្តី ពួកស្ត្រីណា សម្តែងនូវភពពីរ-បី ដោយឥត្ថីភាពទុំះឯង ហើយនឹងបរិនិព្វានក្តី កាលសត្វទាំងនោះ ចាប់បដិសន្ធិ បុរិសិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្តាពួកសត្វដែលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វានក្តី ពួកស្ត្រីណា សម្តែងនូវភពពីរ-បី ដោយឥត្ថីភាពទុំះឯង ហើយនឹងបរិនិព្វានក្តី កាលសត្វទាំងនោះ

ច្យុត បុរិសិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខុន្ទ្រិយ មិនកើតឡើងផង ។

[ ១៤២ ] ចក្ខុន្ទ្រិយ របស់សត្វណា មិនកើតឡើង ជីវិតិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ចក្ខុន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯជីវិតិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ចក្ខុន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភពនោះ មិនកើតឡើងផង ជីវិតិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត ជីវិតិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ចក្ខុន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ ជីវិតិន្ទ្រិយ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភពនោះ នឹងមិនកើតឡើង ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ជីវិតិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភពនោះ នឹងមិនកើតឡើងផង ចក្ខុន្ទ្រិយ មិនកើតឡើងផង ។

[ ១៤៣ ] ចក្ខុន្ទ្រិយ របស់សត្វណា មិនកើតឡើង សោមនស្សិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ចក្ខុន្ទ្រិយ របស់ពួកសត្វអ្នកមិនមានចក្ខុទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯសោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្ដាពួកសត្វដែលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព

ក្នុងអរូបភព ពួកសត្វណា កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង សោមនស្សិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត សោមនស្សិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ចក្ខុន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណាអ្នកមានចក្ខុ កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់បដិសន្ធិ សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្តាពួកសត្វដែលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមក្នុងអរូបភព ពួកសត្វណា កើតឡើង ដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខុន្ទ្រិយ មិនកើតឡើងផង ។

[ ១៨៤ ] ចក្ខុន្ទ្រិយ របស់សត្វណា មិនកើតឡើង ឧបេក្ខិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ចក្ខុន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា កើតឡើង ដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង ឧបេក្ខិន្ទ្រិយ នឹងមិន

កើតឡើងផង ។ មួយទៀត ឧបេក្ខិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ចក្ខុន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ជាអ្នកមានចក្ខុ កើតឡើង ដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់បដិសន្ធិ ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្តាពួកសត្វ ដែលបរិ-និព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខុន្ទ្រិយ មិនកើតឡើងផង ។

[ ១៤៥ ] ចក្ខុន្ទ្រិយ របស់សត្វណា មិនកើតឡើង សទ្ធិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ចក្ខុន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯសទ្ធិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ចក្ខុន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភពនោះ មិនកើតឡើងផង សទ្ធិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត សទ្ធិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ចក្ខុន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ សទ្ធិន្ទ្រិយ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភពនោះ នឹងមិនកើតឡើង ឯចក្ខុន្ទ្រិយ របស់សត្វទាំង

នោះ មិនមែនជាមិនកើតឡើងទេ សទ្ធិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមកភព ក្នុងអរូបភពនោះ នឹងមិនកើតឡើងផង ចក្ខុន្ទ្រិយ មិនកើតឡើងផង ។

[ ១៤៦ ] ចក្ខុន្ទ្រិយ របស់សត្វណា មិនកើតឡើង បញ្ញិន្ទ្រិយ ។បេ។ មនិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ចក្ខុន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯមនិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ចក្ខុន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមកភព ក្នុងអរូបភពនោះ មិនកើតឡើងផង មនិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ចក្ខុន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ មនិន្ទ្រិយ របស់ពួកសត្វដែលកើតក្នុងបច្ឆិមកភព កាលចូលទៅកាន់បញ្ចវោការភពនោះ នឹងមិនកើតឡើង ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ មនិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វាន ក្នុងបញ្ច-វោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមកភព ក្នុងអរូបភពនោះ នឹងមិនកើតឡើងផង ចក្ខុន្ទ្រិយ មិនកើតឡើងផង ។

[ ១៤៧ ] ឃានិន្ទ្រិយ របស់សត្វណា មិនកើតឡើង ឥត្ថិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ឃានិន្ទ្រិយ របស់សត្វអ្នកមិនមានឃានៈទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្តាពួកសត្វដែលបរិនិព្វាន

ក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបា-វចរភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វានក្តី ពួកបុរសណា សម្តែងនូវភពពីរ-បី ដោយបុរិសភាពទុំះឯង ហើយនឹងបរិនិព្វានក្តី កាលសត្វទាំងនោះច្យុត ឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង ឥត្ថិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត ឥត្ថិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ឃានិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វានក្តី ពួកបុរសណា សម្តែងនូវភពពីរ-បី ដោយបុរិសភាពទុំះឯង ហើយនឹងបរិ-និព្វានក្តី កាលសត្វទាំងនោះ ចាប់បដិសន្ធិ ឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ឯឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វានក្តី ពួកបុរសណា សម្តែងនូវភពពីរ-បី ដោយបុរិសភាពទុំះឯង ហើយនឹងបរិនិព្វានក្តី កាលសត្វទាំងនោះច្យុត ឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ឃានិន្ទ្រិយ មិនកើតឡើងផង ។

[ ១៤៨ ] ឃានិន្ទ្រិយ របស់សត្វណា មិនកើតឡើង បុរិសិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ឃានិន្ទ្រិយ របស់សត្វអ្នកមិនមានឃានៈ

ទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯបុរិសិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្តាពួកសត្វដែលបរិនិព្វាន ក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វានក្តី ពួកស្ត្រីណា សម្តែងនូវភពពីរ-បី ដោយឥត្ថីភាពនុ៎ះឯង ហើយនឹងបរិនិព្វានក្តី កាលសត្វទាំងនោះច្យុត យានិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង បុរិសិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត បុរិសិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង យានិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វានក្តី ពួកស្ត្រីណា សម្តែងនូវភពពីរ-បី ដោយឥត្ថីភាពនុ៎ះឯង ហើយនឹងបរិនិព្វានក្តី កាលសត្វទាំងនោះ ចាប់បដិសន្ធិ បុរិសិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ឯយានិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្តាពួកសត្វ ដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វានក្តី ពួកស្ត្រីណា សម្តែងនូវភពពីរ-បី ដោយឥត្ថីភាពនុ៎ះឯង ហើយនឹងបរិនិព្វានក្តី កាលស្ត្រីទាំងនោះច្យុត បុរិសិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង យានិន្ទ្រិយ មិនកើតឡើងផង ។

[ ១៤៩ ] ឃានិន្ទ្រិយ របស់សត្វណា មិនកើតឡើង ជីវិតិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ឃានិន្ទ្រិយ របស់សត្វអ្នកមិនមានឃានៈទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯជីវិតិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ឃានិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភពនោះ មិនកើតឡើងផង ជីវិតិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត ជីវិតិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ឃានិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ ជីវិតិន្ទ្រិយ របស់ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភពនោះ នឹងមិនកើតឡើង ឯឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ជីវិតិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភពនោះ នឹងមិនកើតឡើងផង ឃានិន្ទ្រិយ មិនកើតឡើងផង ។

[ ១៥០ ] ឃានិន្ទ្រិយ របស់សត្វណា មិនកើតឡើង សោមនស្សិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ឃានិន្ទ្រិយ របស់សត្វអ្នកមិនមានឃានៈទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯសោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព ពួកសត្វណា កើតឡើងដោយឧបេក្ខា ហើយ

នឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង សោមនស្សិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត សោមនស្សិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ឃានិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ពួកសត្វណា ជាអ្នកមានឃានៈ កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់បដិសន្ធិ សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ឯឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្តាពួកសត្វ ដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព ពួកសត្វណា កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ឃានិន្ទ្រិយ មិនកើតឡើងផង ។

[ ១៥១ ] ឃានិន្ទ្រិយ របស់សត្វណា មិនកើតឡើង ឧបេក្ខិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ឃានិន្ទ្រិយ របស់សត្វអ្នកមិនមានឃានៈទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព ពួកសត្វណា កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង

ឧបេក្ខិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត ឧបេក្ខិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ឃានិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ពួកសត្វណាជាអ្នកមានឃានៈ កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់បដិសន្ធិ ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ឯឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្តាពួកសត្វ ដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភពក្នុងរូបាវចរភព និងអរូបាវចរភព ពួកសត្វណា កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ឃានិន្ទ្រិយ មិនកើតឡើងផង ។

[ ១៥២ ] ឃានិន្ទ្រិយ របស់សត្វណា មិនកើតឡើង សទ្ធិន្ទ្រិយ ។បេ។ បញ្ញិន្ទ្រិយ មនិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ឃានិន្ទ្រិយ របស់សត្វអ្នកមិនមានឃានៈទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯមនិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ឃានិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វាន ក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព មិនកើតឡើងផង មនិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ឃានិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ មនិន្ទ្រិយ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភពនោះ នឹងមិនកើត

ឡើង ឯឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ មនិន្ទ្រិយ របស់ពួកសត្វ ដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភពនោះ នឹងមិនកើតឡើងផង ឃានិន្ទ្រិយ មិនកើតឡើងផង ។

[ ១៥៣ ] ឥត្ថិន្ទ្រិយ របស់សត្វណា មិនកើតឡើង បុរិសិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ឥត្ថិន្ទ្រិយ របស់ពួកសត្វមិនមែនជាស្ត្រីទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯបុរិសិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបា-វចរភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វានក្តី ពួកស្ត្រីណា សម្រេចនូវភពពីរ-បី ដោយឥត្ថីភាពទុំ៎ះឯង ហើយនឹងបរិនិព្វានក្តី កាលសត្វទាំងនោះច្យុត ឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង បុរិសិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត បុរិសិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ឥត្ថិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ បណ្តាពួកស្ត្រី ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ពួកស្ត្រីណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វានក្តី ពួកស្ត្រីណា សម្រេចនូវភពពីរ-បី ដោយឥត្ថីភាពទុំ៎ះឯង ហើយនឹងបរិនិព្វានក្តី កាលស្ត្រីទាំងនោះ ចាប់បដិសន្ធិ បុរិសិន្ទ្រិយ របស់ស្ត្រីទាំងនោះ នឹងមិនកើតឡើង ឯឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្តាពួកសត្វ

ដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភព ហើយនឹងបរិនិព្វានក្តី ពួកស្ត្រីណា សម្តែងនូវភពពីរ-បី ដោយឥត្ថីភាពនុ៎ះឯង ហើយនឹងបរិនិព្វានក្តី កាលសត្វទាំងនោះច្យុត បុរិសិន្ទ្រិយរបស់សត្វទាំងនោះ នឹងមិនកើតឡើងផង ឥត្ថិន្ទ្រិយ មិនកើតឡើងផង ។

[ ១៥៤ ] ឥត្ថិន្ទ្រិយ របស់សត្វណា មិនកើតឡើង ជីវិតិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ឥត្ថិន្ទ្រិយ របស់ពួកសត្វមិនមែនជាស្ត្រីទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯជីវិតិន្ទ្រិយរបស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ឥត្ថិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភពនោះ មិនកើតឡើងផង ជីវិតិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត ជីវិតិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ឥត្ថិន្ទ្រិយរបស់សត្វនោះ មិនកើតឡើងឬ ។ ជីវិតិន្ទ្រិយ របស់ពួកស្ត្រីដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិនោះ នឹងមិនកើតឡើង ឯឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ មិនមែនជាមិនកើតឡើងទេ ជីវិតិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព នឹងមិនកើតឡើងផង ឥត្ថិន្ទ្រិយ មិនកើតឡើងផង ។

[ ១៥៥ ] ឥត្ថិន្ទ្រិយ របស់សត្វណា មិនកើតឡើង សោមនស្សិន្ទ្រិយរបស់សត្វនោះ នឹងមិនកើតឡើងឬ ។ ឥត្ថិន្ទ្រិយ របស់ពួកសត្វមិនមែនជា

ស្រ្តីទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯសោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព ពួកសត្វណា កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង សោមនស្សិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត សោមនស្សិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ឥត្ថិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ បណ្តាពួកស្ត្រី ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ពួកស្ត្រីណា កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលស្ត្រីទាំងនោះចាប់បដិសន្ធិ សោមនស្សិន្ទ្រិយ របស់ស្ត្រីទាំងនោះ នឹងមិនកើតឡើង ឯឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្តាពួកសត្វដែលបរិនិព្វាន ក្នុងកាមាវចរភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព ពួកសត្វណា កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះនឹងមិនកើតឡើងផង ឥត្ថិន្ទ្រិយ មិនកើតឡើងផង ។

[ ១៥៦ ] ឥត្ថិន្ទ្រិយ របស់សត្វណា មិនកើតឡើង ឧបេក្ខិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ឥត្ថិន្ទ្រិយ របស់ពួកសត្វមិនមែនជាស្ត្រីទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្តាពួកសត្វ ដែល

បរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព ពួកសត្វណា កើតឡើងដោយសោមនស្ស ហើយនឹងបរិ-និព្វាន កាលសត្វទាំងនោះច្យុត ឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង ឧបេក្ខិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត ឧបេក្ខិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ឥត្ថិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ បណ្ដាពួកស្ត្រី ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ពួកស្ត្រីណា កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលស្ត្រីទាំងនោះ ចាប់បដិសន្ធិ ឧបេក្ខិន្ទ្រិយ របស់ស្ត្រីទាំងនោះ នឹងមិនកើតឡើង ឯឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្ដាពួកសត្វ ដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព ពួកសត្វណា កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ឥត្ថិន្ទ្រិយ មិនកើតឡើងផង ។

[ ១៥៧ ] ឥត្ថិន្ទ្រិយ របស់សត្វណា មិនកើតឡើង សទ្ធិន្ទ្រិយ ។បេ។ បញ្ញិន្ទ្រិយ មនិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ឥត្ថិន្ទ្រិយ របស់ពួកសត្វមិនមែនជាស្ត្រីទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯមនិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ឥត្ថិន្ទ្រិយ របស់ពួកសត្វ ដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភពនោះ មិនកើតឡើងផង មនិន្ទ្រិយ

នឹងមិនកើតឡើងផង ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ឥត្ថិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ មនិន្ទ្រិយ របស់ពួកស្រ្តីដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ នឹងមិនកើតឡើង ឯឥត្ថិន្ទ្រិយរបស់ស្រ្តីទាំងនោះ មិនមែនជាមិនកើតឡើងទេ មនិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភពនោះ នឹងមិនកើតឡើងផង ឥត្ថិន្ទ្រិយ មិនកើតឡើងផង ។

[ ១៥៨ ] បុរិសិន្ទ្រិយ របស់សត្វណា មិនកើតឡើង ជីវិតិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ បុរិសិន្ទ្រិយ របស់ពួកសត្វ មិនមែនជាបុរសទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯជីវិតិន្ទ្រិយរបស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បុរិសិន្ទ្រិយ របស់ពួកសត្វ ដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភពក្នុងរូបាវចរភព និងអរូបាវចរភពនោះ មិនកើតឡើងផង ជីវិតិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត ជីវិតិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង បុរិសិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ ជីវិតិន្ទ្រិយ របស់ពួកបុរសដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិនោះ នឹងមិនកើតឡើង ឯបុរិសិន្ទ្រិយរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ជីវិតិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភពនោះ និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព នឹងមិនកើតឡើងផង បុរិសិន្ទ្រិយ មិនកើត

ឡើងផង ។

[ ១៥៩ ] បុរិសិន្ទ្រិយ របស់សត្វណា មិនកើតឡើង សោមនស្សិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ បុរិសិន្ទ្រិយ របស់ពួកសត្វមិនមែនជាបុរសទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯសោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្ដាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភពក្នុងរូបាវចរភព និងអរូបាវចរភព ពួកសត្វណា កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត បុរិសិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង សោមនស្សិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត សោមនស្សិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង បុរិសិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ បណ្ដាពួកបុរស ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ពួកបុរសណា កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលបុរសទាំងនោះ ចាប់បដិសន្ធិ សោមនស្សិន្ទ្រិយ របស់បុរសទាំងនោះ នឹងមិនកើតឡើង ឯបុរិសិន្ទ្រិយ របស់បុរសទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្ដាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព ពួកសត្វណា កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង បុរិសិន្ទ្រិយ មិនកើតឡើងផង ។

[ ១៦០ ] បុរិសិន្ទ្រិយ របស់សត្វណា មិនកើតឡើង ឧបេក្ខិន្ទ្រិយ

របស់សត្វនោះ នឹងមិនកើតឡើងឬ ។ បុរិសិន្ទ្រិយ របស់ពួកសត្វមិនមែនជាបុរសទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព ពួកសត្វណា កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត បុរិសិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង ឧបេក្ខិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត ឧបេក្ខិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង បុរិសិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ បណ្តាពួកបុរស ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ពួកបុរសណា កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលបុរសទាំងនោះចាប់បដិសន្ធិ ឧបេក្ខិន្ទ្រិយ របស់បុរសទាំងនោះ នឹងមិនកើតឡើង ឯបុរិសិន្ទ្រិយ របស់បុរសទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្តាពួកសត្វ ដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព ពួកសត្វណា កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង បុរិសិន្ទ្រិយ មិនកើតឡើងផង ។

[ ១៦១ ] បុរិសិន្ទ្រិយ របស់សត្វណា មិនកើតឡើង សទ្ធិន្ទ្រិយ ។បេ។ បញ្ញិន្ទ្រិយ មនិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ បុរិសិន្ទ្រិយ របស់ពួកសត្វ មិនមែនជាបុរសទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ

មិនកើតឡើង ឯមនិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បុរិសិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភពនោះ ក្នុងរូបាវចរភព និងអរូបាវចរភពនោះ មិនកើតឡើងផង មនិន្ទ្រិយ នឹងមិនកើតឡើងផង ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង បុរិសិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ មនិន្ទ្រិយ របស់ពួកបុរស ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ នឹងមិនកើតឡើង ឯបុរិសិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ មនិន្ទ្រិយ របស់ពួកសត្វ ដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភពក្នុងរូបាវចរភព និងអរូបាវចរភពនោះ នឹងមិនកើតឡើងផង បុរិសិន្ទ្រិយ មិនកើតឡើងផង ។

[ ១៦២ ] ជីវិតិន្ទ្រិយ របស់សត្វណា មិនកើតឡើង សោមនស្សិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ជីវិតិន្ទ្រិយ របស់សត្វទាំងអស់នោះ កាលច្យុត មិនកើតឡើងក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ឯសោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខា ក្នុងលំដាប់នៃចិត្តណា នឹងកើតឡើង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ជីវិតិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង សោមនស្សិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្តនោះ ។ មួយទៀត សោមនស្សិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ជីវិតិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ បច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខា ក្នុងលំដាប់នៃចិត្តណា នឹងកើត

ឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ឯជីវិតិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បច្ឆិមចិត្តដែលប្រកបដោយឧបេក្ខា ក្នុងលំដាប់នៃចិត្តណា នឹងកើតឡើង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ជីវិតិន្ទ្រិយ មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្តនោះ ។

[ ១៦៣ ] ជីវិតិន្ទ្រិយ របស់សត្វណា មិនកើតឡើង ឧបេក្ខិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ជីវិតិន្ទ្រិយ របស់ពួកសត្វទាំងអស់នោះ កាលច្យុត មិនកើតឡើងក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បច្ឆិមចិត្ត ដែលប្រកបដោយសោមនស្ស ក្នុងលំដាប់នៃចិត្តណា នឹងកើតឡើង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ជីវិតិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង ឧបេក្ខិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្តនោះ ។ មួយទៀត ឧបេក្ខិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ជីវិតិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ បច្ឆិមចិត្ត ដែលប្រកបដោយសោមនស្ស ក្នុងលំដាប់នៃចិត្តណា នឹងកើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ឯជីវិតិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បច្ឆិមចិត្ត ដែលប្រកបដោយសោមនស្ស ក្នុងលំដាប់នៃចិត្តណា នឹងកើតឡើង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ឧបេក្ខិន្ទ្រិយ

របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ជីវិតិន្ទ្រិយ មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្តនោះ ។

[ ១៦៤ ] ជីវិតិន្ទ្រិយ របស់សត្វណា មិនកើតឡើង សទ្ធិន្ទ្រិយ ។បេ។ បញ្ញិន្ទ្រិយ មនិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ជីវិតិន្ទ្រិយ របស់សត្វទាំងអស់នោះ កាលច្យុត មិនកើតឡើងក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ឯមនិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ជីវិតិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង មនិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ជីវិតិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ មនិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ឯជីវិតិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ មនិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ជីវិតិន្ទ្រិយ មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ។

[ ១៦៥ ] សោមនស្សិន្ទ្រិយ របស់សត្វណា មិនកើតឡើង ឧបេក្ខិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ សោមនស្សិន្ទ្រិយ របស់សត្វដែលចូលកាន់និរោធ និងអសញ្ញសត្វទាំងអស់នោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកសោមនស្ស ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បច្ឆិមចិត្ត ដែលប្រកបដោយសោមនស្ស ក្នុងលំដាប់នៃចិត្តណា របស់ពួកសត្វអ្នកព្រមព្រៀងដោយបច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខា នឹងកើតឡើង ក្នុងភង្គក្ខណៈនៃ

បច្ឆិមចិត្ត ដែលប្រកបដោយសោមនស្ស សោមនស្សិន្ទ្រិយ របស់សត្វទាំង នោះ មិនកើតឡើងផង ឧបេក្ខិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងភង្គក្ខណៈ នៃចិត្តនោះ ។ មួយទៀត ឧបេក្ខិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង សោមនស្សិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ បច្ឆិមចិត្ត ដែលប្រកប ដោយសោមនស្ស ក្នុងលំដាប់នៃចិត្តណា នឹងកើតឡើង ក្នុងឧប្បាទក្ខណៈ នៃបច្ឆិមចិត្ត ដែលប្រកបដោយសោមនស្ស ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ឯសោមនស្សិន្ទ្រិយ របស់ សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បច្ឆិមចិត្ត ដែលប្រកបដោយ សោមនស្ស ក្នុងលំដាប់នៃចិត្តណា របស់ពួកសត្វអ្នកព្រមព្រៀងដោយ បច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខា នឹងកើតឡើង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ដែលប្រកបដោយសោមនស្ស ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើត ឡើងផង សោមនស្សិន្ទ្រិយ មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្តនោះ ។

[ ១៦៦ ] សោមនស្សិន្ទ្រិយ របស់សត្វណា មិនកើតឡើង សទ្ធិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ សោមនស្សិន្ទ្រិយ របស់សត្វដែល ចូលកាន់និរោធ និងអសញ្ញសត្វទាំងអស់នោះ មិនកើតឡើង ក្នុងភង្គក្ខណៈ នៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកសោមនស្ស ឯសទ្ធិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ សោមនស្សិន្ទ្រិយ របស់ ពួកសត្វអ្នកព្រមព្រៀងដោយបច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខានោះ មិន កើតឡើងផង សទ្ធិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត

ដែលប្រកបដោយសោមនស្ស ។ មួយទៀត សទ្ធិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង សោមនស្សិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ សទ្ធិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ដែលប្រកបដោយសោមនស្ស ឯសោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ សទ្ធិន្ទ្រិយ របស់ពួកសត្វអ្នកព្រមព្រៀងដោយបច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខានោះ នឹងមិនកើតឡើងផង សោមនស្សិន្ទ្រិយ មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ដែលប្រកបដោយសោមនស្ស ។

[ ១៦៧ ] សោមនស្សិន្ទ្រិយ របស់សត្វណា មិនកើតឡើង បញ្ញិន្ទ្រិយ ។បេ។ មនិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ សោមនស្សិន្ទ្រិយ របស់សត្វដែលចូលកាន់និរោធ និងអសញ្ញសត្វទាំងអស់នោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកសោមនស្ស ឯមនិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ សោមនស្សិន្ទ្រិយ របស់ពួកសត្វអ្នកព្រមព្រៀងដោយបច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខានោះ មិនកើតឡើងផង មនិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ដែលប្រកបដោយសោមនស្ស ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង សោមនស្សិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ មនិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ដែលប្រកបដោយសោមនស្ស ឯសោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ មនិន្ទ្រិយ របស់ពួកសត្វអ្នកព្រមព្រៀង

ដោយបច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខានោះ នឹងមិនកើតឡើងផង សោមនស្សិន្ទ្រិយ មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ដែលប្រកបដោយសោមនស្ស ។

[ ១៦៨ ] ឧបេក្ខិន្ទ្រិយ របស់សត្វណា មិនកើតឡើង សទ្ធិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ឧបេក្ខិន្ទ្រិយ របស់សត្វដែលចូលកាន់និរោធ និងអសញ្ញសត្វទាំងអស់នោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកឧបេក្ខា ឯសទ្ធិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ឧបេក្ខិន្ទ្រិយ របស់ពួកសត្វ អ្នកព្រមព្រៀងដោយបច្ឆិមចិត្ត ដែលប្រកបដោយសោមនស្សនោះ មិនកើតឡើងផង សទ្ធិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខា ។ មួយទៀត សទ្ធិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ឧបេក្ខិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ សទ្ធិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខា ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ សទ្ធិន្ទ្រិយ របស់សត្វអ្នកព្រមព្រៀងដោយបច្ឆិមចិត្ត ដែលប្រកបដោយសោមនស្សនោះ នឹងមិនកើតឡើងផង ឧបេក្ខិន្ទ្រិយ មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខា ។

[ ១៦៩ ] ឧបេក្ខិន្ទ្រិយ របស់សត្វណា មិនកើតឡើង បញ្ញិន្ទ្រិយ ។បេ។ មនិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ឧបេក្ខិន្ទ្រិយ របស់សត្វដែល

ចូលកាន់និរោធ និងអសញ្ញសត្វទាំងអស់នោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកឧបេក្ខា ឯមនិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ឧបេក្ខិន្ទ្រិយ របស់ពួកសត្វអ្នកព្រមព្រៀងដោយបច្ឆិមចិត្ត ដែលប្រកបដោយសោមនស្សនោះ មិនកើតឡើងផង មនិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខា ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ឧបេក្ខិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ មនិន្ទ្រិយរបស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខា ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ មនិន្ទ្រិយរបស់ពួកសត្វអ្នកព្រមព្រៀងដោយបច្ឆិមចិត្ត ដែលប្រកបដោយសោមនស្សនោះ នឹងមិនកើតឡើងផង ឧបេក្ខិន្ទ្រិយ មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខា ។

[ ១៧០ ] សទ្ធិន្ទ្រិយ របស់សត្វណា មិនកើតឡើង បញ្ញិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ សទ្ធិន្ទ្រិយ របស់ពួកសត្វ ដែលចូលកាន់និរោធ និងអសញ្ញសត្វទាំងអស់នោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកសទ្ធា ឯបញ្ញិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ សទ្ធិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង បញ្ញិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ។ មួយទៀត បញ្ញិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង សទ្ធិន្ទ្រិយ របស់

សត្វនោះ មិនកើតឡើងឬ ។ បញ្ញិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ឯសទ្ធិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បញ្ញិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង សទ្ធិន្ទ្រិយ មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ។

[ ១៧១ ] សទ្ធិន្ទ្រិយ របស់សត្វណា មិនកើតឡើង មនិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ សទ្ធិន្ទ្រិយ របស់ពួកសត្វ ដែលចូលកាន់និរោធ និងអសញ្ញសត្វទាំងអស់នោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកសទ្ធា ឯមនិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ សទ្ធិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង មនិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិម-ចិត្ត ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង សទ្ធិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ មនិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ឯសទ្ធិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ មនិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង សទ្ធិន្ទ្រិយ មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ។

[ ១៧២ ] បញ្ញិន្ទ្រិយ របស់សត្វណា មិនកើតឡើង មនិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ បញ្ញិន្ទ្រិយ របស់ពួកសត្វដែលចូលកាន់និរោធ និងអសញ្ញសត្វទាំងអស់នោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកញាណ ឯមនិន្ទ្រិយ របស់សត្វ

ទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បញ្ញិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង មនិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង បញ្ញិន្ទ្រិយ របស់សត្វនោះ មិនកើតឡើងឬ ។ មនិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ឯបញ្ញិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ មនិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង បញ្ញិន្ទ្រិយ មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ។

[ ១៧៣ ] ចក្ខុន្ទ្រិយ មិនកើតឡើង ក្នុងទីណា ។បេ។

[ ១៧៤ ] ចក្ខុន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា សោតិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ចក្ខុន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងនោះ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព មិនកើតឡើង ក្នុងទីនោះ ឯសោតិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ឯចក្ខុន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងបញ្ចវោការភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្មនោះ មិនកើតឡើងផង សោតិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត សោតិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខុន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ សោតិន្ទ្រិយ របស់ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភពនោះ នឹងមិនកើតឡើង ក្នុងទីនោះ ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ សោតិន្ទ្រិយ របស់

ពួកសត្វដែលបរិនិព្វាន ក្នុងបញ្ចវោការភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម នោះ នឹងមិនកើតឡើងផង ចក្ខុន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៧៥ ] ចក្ខុន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា ឃានិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ចក្ខុន្ទ្រិយ របស់ពួកសត្វ អ្នកមិនមានចក្ខុទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់ កាមាវចរភព មិនកើតឡើង ក្នុងទីនោះ ឯឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខុន្ទ្រិយ របស់ពួកសត្វដែលបរិ-និព្វាន ក្នុងកាមាវចរភព កាលច្យុតចាករូបាវចរភព ពួកអសញ្ញសត្វ និង ពួកអរូបព្រហ្មនោះ មិនកើតឡើងផង ឃានិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុង ទីនោះ ។ មួយទៀត ឃានិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទី ណា ចក្ខុន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ឃានិន្ទ្រិយ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព កាល ចូលទៅកាន់រូបាវចរភព នឹងមិនកើតឡើង ក្នុងទីនោះ ឯចក្ខុន្ទ្រិយ របស់ សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ឃានិន្ទ្រិយ របស់ពួក សត្វ ដែលបរិនិព្វាន ក្នុងកាមាវចរភព កាលច្យុតចាករូបាវចរភព ពួក អសញ្ញសត្វ និងពួកអរូបព្រហ្មនោះ នឹងមិនកើតឡើងផង ចក្ខុន្ទ្រិយ មិន កើតឡើងផង ក្នុងទីនោះ ។

[ ១៧៦ ] ចក្ខុន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា ឥត្ថិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ចក្ខុន្ទ្រិយ របស់សត្វអ្នក

មិនមានចក្ខុទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព មិនកើតឡើង ក្នុងទីនោះ ឯឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វ ដែលបរិនិព្វានក្នុងកាមាវចរភព កាលច្យុតចាករូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ពួកបុរសណា សម្តែងនូវភពពីរ-បី ដោយបុរិសភាពទុំះឯង ហើយនឹងបរិនិព្វាន កាលបុរសទាំងនោះច្យុត ចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង ឥត្ថិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ឥត្ថិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខុន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព កាលចូលទៅកាន់រូបាវចរភព ពួកបុរសណា សម្តែងនូវភពពីរ-បី ដោយបុរិសភាពទុំះឯង ហើយនឹងបរិនិព្វាន កាលបុរសទាំងនោះចាប់បដិសន្ធិ ឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ ឯចក្ខុន្ទ្រិយ របស់បុរសទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វ ដែលបរិនិព្វានក្នុងកាមាវចរភព កាលច្យុតចាករូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ពួកបុរសណា សម្តែងនូវភពពីរ-បី ដោយបុរិសភាពទុំះឯង ហើយនឹងបរិនិព្វាន កាលបុរសទាំងនោះច្យុត ឥត្ថិន្ទ្រិយ របស់បុរសទាំងនោះ នឹងមិនកើតឡើងផង ចក្ខុន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៧៧ ] ចក្ខុន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា បុរិសិន្ទ្រិយ

របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ចក្ខុន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព មិនកើតឡើង ក្នុងទីនោះ ឯបុរិសិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វ ដែលបរិនិព្វាន ក្នុងកាមាវចរភព កាលច្យុតចាករូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ពួកស្ត្រីណា សម្តែងនូវភពពីរ-បី ដោយឥត្ថីកាពន្ទុះឯង ហើយនឹងបរិនិព្វាន កាលស្ត្រីទាំងនោះច្យុត ចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង បុរិសិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត បុរិសិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខុន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព កាលចូលទៅកាន់រូបាវចរភព ពួកស្ត្រីណា សម្តែងនូវភពពីរ-បី ដោយឥត្ថីកាពន្ទុះឯង ហើយនឹងបរិនិព្វាន កាលស្ត្រីទាំងនោះ ចាប់បដិសន្ធិ បុរិសិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ។ បណ្តាពួកសត្វ ដែលបរិនិព្វានក្នុងកាមាវចរភព កាលច្យុតចាករូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ពួកស្ត្រីណា សម្តែងនូវភពពីរ-បី ដោយឥត្ថីកាពន្ទុះឯង ហើយនឹងបរិនិព្វាន កាលស្ត្រីទាំងនោះច្យុត បុរិសិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខុន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៧៨ ] ចក្ខុន្ទ្រិយរបស់សត្វណា មិនកើតឡើង ក្នុងទីណា ជីវិតិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ចក្ខុន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ក្នុងទីនោះ ឯជីវិតិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខុន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភពនោះ មិនកើតឡើងផង ជីវិតិន្ទ្រិយនឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ជីវិតិន្ទ្រិយ របស់សត្វណានឹងមិនកើតឡើង ក្នុងទីណា ចក្ខុន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ជីវិតិន្ទ្រិយ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភពនោះ នឹងមិនកើតឡើង ក្នុងទីនោះ ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ជីវិតិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភពនោះ នឹងមិនកើតឡើងផង ចក្ខុន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៧៩ ] ចក្ខុន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា សោមនស្សិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ចក្ខុន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងនោះ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព មិនកើតឡើង ក្នុងទីនោះ ឯសោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងបញ្ចវោការភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ពួក

សត្វណា ជាអ្នកមានចក្ខុ កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង សោមនស្សិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត សោមនស្សិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខុន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ជាអ្នកមានចក្ខុ កើតឡើង ដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់បដិសន្ធិ សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងបញ្ចវោការភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ពួកសត្វណា ជាអ្នកមានចក្ខុ កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខុន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៨០ ] ចក្ខុន្ទ្រិយរបស់សត្វណា មិនកើតឡើង ក្នុងទីណា ឧបេក្ខិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ចក្ខុន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងនោះ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព និងពួកអរូបព្រហ្ម មិនកើតឡើង ក្នុងទីនោះ ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុង

អរូបភព និងពួកអសញ្ញសត្វ ពួកសត្វណា ជាអ្នកមានចក្ខុ កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង ឧបេក្ខិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ឧបេក្ខិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខុន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ជាអ្នកមានចក្ខុ កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់បដិសន្ធិ ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព និងពួកអសញ្ញសត្វ ពួកសត្វណា ជាអ្នកមានចក្ខុ កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខុន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៨១ ] ចក្ខុន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា សទ្ធិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ចក្ខុន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងនោះ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព និងពួកអរូបព្រហ្ម មិនកើតឡើង ក្នុងទីនោះ ឯសទ្ធិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខុន្ទ្រិយ របស់

ពួកសត្វដែលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព និងពួកអសញ្ញសត្វនោះ មិនកើតឡើងផង សទ្ធិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត សទ្ធិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខុន្ទ្រិយរបស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ សទ្ធិន្ទ្រិយ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភពនោះ កាលចូលទៅកាន់បញ្ចវោការភព នឹងមិនកើតឡើង ក្នុងទីនោះ ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ សទ្ធិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព និងពួកអសញ្ញសត្វនោះ នឹងមិនកើតឡើងផង ចក្ខុន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៨២ ] ចក្ខុន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា បញ្ញិន្ទ្រិយ ។បេ។ មនិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ចក្ខុន្ទ្រិយ របស់សត្វអ្នកមិនមានចក្ខុទាំងនោះ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព និងពួកអរូបព្រហ្ម មិនកើតឡើង ក្នុងទីនោះ ឯមនិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខុន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព និងពួកអសញ្ញសត្វនោះ មិនកើតឡើងផង មនិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខុន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។

មនិន្ទ្រិយ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភពនោះ កាលចូលទៅកាន់បញ្ច-
វោការភព នឹងមិនកើតឡើង ក្នុងទីនោះ ឯចក្ខុន្ទ្រិយ របស់សត្វទាំងនោះ
មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ មនិន្ទ្រិយ របស់ពួកសត្វដែលបរិ-
និព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព
និងពួកអសញ្ញសត្វនោះ នឹងមិនកើតឡើងផង ចក្ខុន្ទ្រិយ មិនកើតឡើងផង
ក្នុងទីនោះ ។

[ ១៨៣ ] ឈានិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា ឥត្ថិន្ទ្រិយ
របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ឈានិន្ទ្រិយ របស់សត្វ
អ្នកមិនមានឈានៈទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់
កាមាវចរភព មិនកើតឡើងក្នុងទីនោះ ឯឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ មិន
មែនជានឹងមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វដែលបរិនិព្វាន ក្នុង
កាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វ ពួកបុរសណា សម្រេច
នូវភពពីរ-បី ដោយបុរិសភាពទុំះឯង ហើយនឹងបរិនិព្វាន កាលសត្វទាំង
នោះច្យុត ឈានិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង ឥត្ថិន្ទ្រិយ នឹង
មិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ឥត្ថិន្ទ្រិយ របស់សត្វណា នឹងមិន
កើតឡើង ក្នុងទីណា ឈានិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះ
ឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព
ពួកបុរសណា សម្រេចនូវភពពីរ-បី ដោយបុរិសភាពទុំះឯង ហើយនឹងបរិ-
និព្វាន កាលបុរសទាំងនោះ ចាប់បដិសន្ធិ ឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ

នឹងមិនកើតឡើង ក្នុងទីនោះ ឯឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វ ពួកបុរសណា សម្តែងនូវភពពីរ-បី ដោយបុរិសភាពទុំះឯង ហើយនឹងបរិនិព្វាន កាលបុរសទាំងនោះច្យុត ឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ឃានិន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៨៤ ] ឃានិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា បុរិសិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ឃានិន្ទ្រិយ របស់សត្វអ្នកមិនមានឃានៈទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព មិនកើតឡើងក្នុងទីនោះ ឯបុរិសិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វ ពួកស្ត្រីណា សម្តែងនូវភពពីរ-បី ដោយឥត្ថីភាពទុំះឯង ហើយនឹងបរិនិព្វាន កាលស្ត្រីទាំងនោះច្យុត ឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង បុរិសិន្ទ្រិយ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយទៀត បុរិសិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឃានិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ពួកស្ត្រីណា សម្តែងនូវភពពីរ-បី ដោយឥត្ថីភាពទុំះឯង ហើយនឹងបរិនិព្វាន កាលស្ត្រីទាំងនោះ ចាប់បដិសន្ធិ បុរិសិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិន

កើតឡើង ក្នុងទីនោះ ឯឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ បណ្ដាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វ ពួកស្ត្រីណា សម្ដែងនូវភពពីរ-បី ដោយឥត្ថីភាពនុ៎ះឯង ហើយនឹងបរិនិព្វាន កាលស្ត្រីទាំងនោះច្យុត បុរិសិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ឃានិន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៨៥ ] ឃានិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា ជីវិតិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ឃានិន្ទ្រិយ របស់សត្វអ្នកមិនមានឃានៈទាំងអស់នោះ កាលច្យុត កាលចាប់បដិសន្ធិ មិនកើតឡើង ក្នុងទីនោះ ឯជីវិតិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ឃានិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព មិនកើតឡើងផង ជីវិតិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ជីវិតិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឃានិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ជីវិតិន្ទ្រិយ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភពនោះ កាលចូលទៅកាន់កាមាវចរភព នឹងមិនកើតឡើង ក្នុងទីនោះ ឯឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ជីវិតិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភពនោះ នឹងមិន

កើតឡើងផង ឈានិន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៨៦ ] ឈានិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា សោមនស្សិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ឈានិន្ទ្រិយ របស់សត្វអ្នកមិនមានឈានៈទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួករូបាវចរសត្វ មិនកើតឡើង ក្នុងទីនោះ ឯសោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ពួកសត្វណា កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ឈានិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង សោមនស្សិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត សោមនស្សិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឈានិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ពួកសត្វណា ជាអ្នកមានឈានៈ កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់បដិសន្ធិ សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ ឯឈានិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វ ដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភពក្នុងរូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ពួកសត្វណា កើតឡើងដោយឧបេក្ខា ហើយ

នឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ឃានិន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៨៧ ] ឃានិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា ឧបេក្ខិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ឃានិន្ទ្រិយ របស់សត្វ អ្នកមិនមានឃានៈទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វ មិនកើតឡើង ក្នុងទីនោះ ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព និងពួកអសញ្ញសត្វ ពួកសត្វណា កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង ឧបេក្ខិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ឧបេក្ខិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឃានិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ពួកសត្វណា ជាអ្នកមានឃានៈ កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះ ចាប់បដិសន្ធិ ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ ឯឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព

និងអរូបាវចរភព និងពួកអសញ្ញសត្វ ពួកសត្វណា កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ឃានិន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៨៨ ] ឃានិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា សទ្ធិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ឃានិន្ទ្រិយ របស់សត្វអ្នកមិនមានឃានៈទាំងនោះ កាលច្យុតចាកកាមាវចរភព ចូលទៅកាន់កាមាវចរភព ពួករូបាវចរសត្វ និងអរូបាវចរសត្វ មិនកើតឡើង ក្នុងទីនោះ ឯសទ្ធិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ឃានិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព និងពួកអសញ្ញសត្វនោះ មិនកើតឡើងផង សទ្ធិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត សទ្ធិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឃានិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ សទ្ធិន្ទ្រិយ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព នឹងមិនកើតឡើង ក្នុងទីនោះ ឯឃានិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ សទ្ធិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វាន ក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព និងពួកអសញ្ញសត្វនោះ នឹងមិនកើតឡើងផង ឃានិន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៨៩ ] យានិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា បញ្ញិន្ទ្រិយ ។បេ។ មនិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ យានិន្ទ្រិយ របស់សត្វអ្នកមិនមានយានៈទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វ មិនកើតឡើង ក្នុងទីនោះ ឯមនិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ យានិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព និងពួកអសញ្ញសត្វនោះ មិនកើតឡើងផង មនិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា យានិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ មនិន្ទ្រិយ របស់សត្វអ្នកមានយានៈទាំងនោះ ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ នឹងមិនកើតឡើង ក្នុងទីនោះ ឯយានិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ មនិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព និងពួកអសញ្ញ-សត្វ នឹងមិនកើតឡើងផង យានិន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៩០ ] ឥត្ថិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា បុរិសិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ឥត្ថិន្ទ្រិយ របស់សត្វដែលមិនមែនជាស្ត្រីទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព មិនកើតឡើង ក្នុងទីនោះ ឯបុរិសិន្ទ្រិយ របស់សត្វទាំងនោះ

មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វ ពួកស្ត្រីណា សម្តែងនូវភពពីរ-បី ដោយឥត្ថីភាពទុំៈឯង ហើយនឹងបរិនិព្វាន កាលស្ត្រីទាំងនោះច្យុត ឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង បុរិសិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត បុរិសិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឥត្ថិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកស្ត្រី ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ពួកស្ត្រីណា សម្តែងនូវភពពីរ-បី ដោយឥត្ថីភាពទុំៈឯង ហើយនឹងបរិនិព្វាន កាលស្ត្រីទាំងនោះ ចាប់បដិសន្ធិ បុរិសិន្ទ្រិយ របស់ស្ត្រីទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ ឯឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ មិនមែនជាមិនកើតឡើងក្នុងទីនោះទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វ ពួកស្ត្រីណា សម្តែងនូវភពពីរ-បី ដោយឥត្ថីភាពទុំៈឯង ហើយនឹងបរិនិព្វាន កាលស្ត្រីទាំងនោះច្យុត បុរិសិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ឥត្ថិន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[១៩១] ឥត្ថិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា ជីវិតិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ឥត្ថិន្ទ្រិយ របស់សត្វមិនមែនជាស្ត្រីទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វ មិនកើតឡើង ក្នុងទីនោះ ឯជីវិតិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ

ឥត្ថិន្ទ្រិយ របស់ពួកសត្វ ដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព មិនកើតឡើងផង ជីវិតិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ជីវិតិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា ឥត្ថិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ជីវិតិន្ទ្រិយ របស់ស្ត្រីទាំងនោះ ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ នឹងមិនកើតឡើង ក្នុងទីនោះ ឯឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ជីវិតិន្ទ្រិយ របស់ពួកសត្វ ដែលបរិនិព្វាន ក្នុងកាមាវចរភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភពនោះ នឹងមិនកើតឡើងផង ឥត្ថិន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៩២ ] ឥត្ថិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា សោមនស្សិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ឥត្ថិន្ទ្រិយ របស់ពួកសត្វដែលមិនមែនជាស្ត្រីទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួករូបាវចរសត្វ មិនកើតឡើង ក្នុងទីនោះ ឯសោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វ ដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ពួកសត្វណា កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង សោមនស្សិន្ទ្រិយ

នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត សោមនស្សិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឥត្ថិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកស្រ្តីដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ពួកស្រ្តីណា កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលស្រ្តីទាំងនោះចាប់បដិសន្ធិ សោមនស្សិន្ទ្រិយ របស់ស្រ្តីទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ ឯឥត្ថិន្ទ្រិយ របស់ស្រ្តីទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វ ដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ពួកសត្វណា កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ឥត្ថិន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៩៣ ] ឥត្ថិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា ឧបេក្ខិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ឥត្ថិន្ទ្រិយ របស់ពួកសត្វ ដែលមិនមែនជាស្រ្តីទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វ មិនកើតឡើង ក្នុងទីនោះ ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព និងពួកអសញ្ញសត្វ ពួកសត្វណា កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន

កាលសត្វទាំងនោះច្យុត ឥត្ថិន្ទ្រិយ របស់សត្វទាំងនោះ មិនកើតឡើងផង ឧបេក្ខិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ឧបេក្ខិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឥត្ថិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកស្ត្រី ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ពួកស្ត្រីណា កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលស្ត្រីទាំងនោះ ចាប់បដិសន្ធិ ឧបេក្ខិន្ទ្រិយ របស់ស្ត្រីទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ ឯឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វ ដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព និងពួកអសញ្ញសត្វ ពួកសត្វណា កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលសត្វទាំងនោះច្យុត ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ឥត្ថិន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៩៤ ] ឥត្ថិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា សទ្ធិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ឥត្ថិន្ទ្រិយ របស់សត្វដែលមិនមែនជាស្ត្រីទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វ មិនកើតឡើង ក្នុងទីនោះ ឯសទ្ធិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ឥត្ថិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព និងពួក

អសញ្ញសត្វនោះ មិនកើតឡើងផង សទ្ធិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត សទ្ធិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឥត្ថិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ សទ្ធិន្ទ្រិយ របស់ស្ត្រីទាំងនោះ ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ នឹងមិនកើតឡើង ក្នុងទីនោះ ឯឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ សទ្ធិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វាន ក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព និងពួកអសញ្ញសត្វនោះ នឹងមិនកើតឡើងផង ឥត្ថិន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៩៥ ] ឥត្ថិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា បញ្ញិន្ទ្រិយ ។បេ។ មនិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ឥត្ថិន្ទ្រិយ របស់សត្វមិនមែនជាស្ត្រីទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វ មិនកើតឡើង ក្នុងទីនោះ ឯមនិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ឥត្ថិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វាន ក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព និងពួកអសញ្ញសត្វនោះ មិនកើតឡើងផង មនិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឥត្ថិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ មនិន្ទ្រិយ របស់ស្ត្រីទាំងនោះ ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ នឹងមិនកើតឡើង

ក្នុងទីនោះ ឯឥត្ថិន្ទ្រិយ របស់ស្ត្រីទាំងនោះ មិនមែនជាមិនកើតឡើងក្នុងទីនោះទេ ឥត្ថិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមកភព ក្នុងរូបាវចរភព និងអរូបាវចរភព និងពួកអសញ្ញសត្វនោះ នឹងមិនកើតឡើងផង ឥត្ថិន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៩៦ ] បុរិសិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា ជីវិតិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ បុរិសិន្ទ្រិយ របស់សត្វដែលមិនមែនជាបុរសទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វ មិនកើតឡើង ក្នុងទីនោះ ឯជីវិតិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ បុរិសិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វាន ក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមកភព ក្នុងរូបាវចរភព និងអរូបាវចរភពនោះ មិនកើតឡើងផង ជីវិតិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ជីវិតិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា បុរិសិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ជីវិតិន្ទ្រិយ របស់បុរសទាំងនោះ ដែលកើតក្នុងបច្ឆិមកភព កាលចាប់បដិសន្ធិ នឹងមិនកើតឡើង ក្នុងទីនោះ ឯបុរិសិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ជីវិតិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមកភព ក្នុងរូបាវចរភព និងអរូបាវចរភពនោះ នឹងមិនកើតឡើងផង បុរិសិន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៩៧ ] បុរិសិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា សោមនស្សិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ បុរិសិន្ទ្រិយ របស់សត្វដែលមិនមែនជាបុរសទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួករូបាវចរសត្វនោះ មិនកើតឡើង ក្នុងទីនោះ ឯសោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ពួកបុរសណា កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលបុរសទាំងនោះច្យុត បុរិសិន្ទ្រិយ របស់បុរសទាំងនោះ មិនកើតឡើងផង សោមនស្សិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត សោមនស្សិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា បុរិសិន្ទ្រិយរបស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកបុរសដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ពួកបុរសណា កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលបុរសទាំងនោះចាប់បដិសន្ធិ សោមនស្សិន្ទ្រិយ របស់បុរសទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ ឯបុរិសិន្ទ្រិយ របស់បុរសទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ពួកបុរសណា កើតឡើងដោយឧបេក្ខា ហើយនឹងបរិនិព្វាន កាលបុរសទាំងនោះច្យុត សោមនស្សិន្ទ្រិយ របស់បុរសទាំងនោះ នឹងមិនកើតឡើងផង បុរិសិន្ទ្រិយ

មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៩៨ ] បុរិសិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា ឧបេក្ខិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ បុរិសិន្ទ្រិយ របស់សត្វដែលមិនមែនជាបុរសទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វ មិនកើតឡើង ក្នុងទីនោះ ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព និងពួកអសញ្ញសត្វ ពួកបុរសណា កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលបុរសទាំងនោះច្យុត បុរិសិន្ទ្រិយ របស់បុរសទាំងនោះ មិនកើតឡើងផង ឧបេក្ខិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត ឧបេក្ខិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា បុរិសិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ បណ្តាពួកបុរសដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ពួកបុរសណា កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន កាលបុរសទាំងនោះ ចាប់បដិសន្ធិ ឧបេក្ខិន្ទ្រិយ របស់បុរសទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ ឯបុរិសិន្ទ្រិយ របស់បុរសទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ បណ្តាពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព និងពួកអសញ្ញសត្វ ពួកបុរសណា កើតឡើងដោយសោមនស្ស ហើយនឹងបរិនិព្វាន

កាលបុរសទាំងនោះច្យុត ឧបេក្ខិន្ទ្រិយ របស់បុរសទាំងនោះ នឹងមិនកើតឡើងផង បុរិសិន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៩៩ ] បុរិសិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា សទ្ធិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ បុរិសិន្ទ្រិយ របស់សត្វ ដែលមិនមែនជាបុរសទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វ មិនកើតឡើង ក្នុងទីនោះ ឯសទ្ធិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ បុរិសិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងកាមាវចរ-ភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព និងពួកអសញ្ញសត្វនោះ មិនកើតឡើងផង សទ្ធិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត សទ្ធិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា បុរិសិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ សទ្ធិន្ទ្រិយ របស់ពួកបុរសទាំងនោះ ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ នឹងមិនកើតឡើង ក្នុងទីនោះ ឯបុរិសិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ សទ្ធិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព និងពួកអសញ្ញសត្វនោះ នឹងមិនកើតឡើងផង បុរិសិន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ២០០ ] បុរិសិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា

បញ្ចិន្ទ្រិយ ។បេ។ មនិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ បុរិសិន្ទ្រិយ របស់សត្វដែលមិនមែនជាបុរសទាំងនោះ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ពួករូបាវចរសត្វ និងពួកអរូបាវចរសត្វ មិនកើតឡើង ក្នុងទីនោះ ឯមនិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ បុរិសិន្ទ្រិយ របស់ពួកសត្វដែលបរិនិព្វាន ក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរ-ភព និងពួកអរូបាវចរភព និងអសញ្ញសត្វនោះ មិនកើតឡើងផង មនិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយទៀត មនិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា បុរិសិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ មនិន្ទ្រិយ របស់បុរសទាំងនោះ ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ នឹងមិនកើតឡើង ក្នុងទីនោះ ឯបុរិសិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ មនិន្ទ្រិយ របស់ពួកសត្វ ដែលបរិ-និព្វានក្នុងកាមាវចរភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងអរូបាវចរភព និងពួកអសញ្ញសត្វនោះ នឹងមិនកើតឡើងផង បុរិសិន្ទ្រិយ មិនកើតឡើងផង ក្នុងទីនោះ ។

[ ២០១ ] ជីវិតិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា សោម-នស្សិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ជីវិតិន្ទ្រិយ របស់សត្វទាំងនោះ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព មិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ក្នុងទីនោះ ឯសោមនស្សិន្ទ្រិយ

របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ បច្ឆិមចិត្ត ដែលប្រកបដោយឧបេក្ខា ក្នុងលំដាប់នៃចិត្តណា នឹងកើតឡើងក្នុងភង្គក្ខណៈ នៃបច្ឆិមចិត្ត ជីវិតិន្ទ្រិយ របស់សត្វទាំងនោះ កាលច្យុតចាកអសញ្ញសត្វ មិន កើតឡើងផង សោមនស្សិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្ត នោះ ក្នុងទីនោះ ។ មួយទៀត សោមនស្សិន្ទ្រិយ របស់សត្វណា នឹងមិន កើតឡើង ក្នុងទីណា ជីវិតិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ បច្ឆិមចិត្តដែលប្រកបដោយឧបេក្ខា ក្នុងលំដាប់នៃចិត្តណា នឹងកើតឡើង ក្នុង ឧប្បាទក្ខណៈនៃបច្ឆិមចិត្ត សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ កាលចូល ទៅកាន់អសញ្ញសត្វ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ក្នុងទី នោះ ឯជីវិតិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះ ទេ បច្ឆិមចិត្តដែលប្រកបដោយឧបេក្ខា ក្នុងលំដាប់នៃចិត្តណា នឹងកើតឡើង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត សោមនស្សិន្ទ្រិយ របស់សត្វទាំងនោះ កាលច្យុត ចាកអសញ្ញសត្វ នឹងមិនកើតឡើងផង ជីវិតិន្ទ្រិយ មិនកើតឡើងផង ក្នុង ភង្គក្ខណៈនៃចិត្តនោះ ក្នុងទីនោះ ។

[ ២០២ ] ជីវិតិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា ឧបេក្ខិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ជីវិតិន្ទ្រិយ របស់សត្វទាំង នោះ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព មិនកើតឡើង ក្នុង ភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ក្នុងទីនោះ ឯឧបេក្ខិន្ទ្រិយ របស់សត្វទាំង នោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ បច្ឆិមចិត្តដែលប្រកបដោយ

សោមនស្ស ក្នុងលំដាប់នៃចិត្តណា នឹងកើតឡើង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ជីវិតិន្ទ្រិយ របស់សត្វទាំងនោះ កាលច្យុតចាកអសញ្ញសត្វ មិនកើតឡើងផង ឧបេក្ខិន្ទ្រិយ នឹងមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្តនោះ ក្នុងទីនោះ ។ មួយទៀត ឧបេក្ខិន្ទ្រិយ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ជីវិតិន្ទ្រិយ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ បច្ឆិមចិត្តដែលប្រកបដោយសោមនស្ស ក្នុងលំដាប់នៃចិត្តណា នឹងកើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ កាលចូលទៅកាន់អសញ្ញសត្វ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ក្នុងទីនោះ ឯជីវិតិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ បច្ឆិមចិត្តដែលប្រកបដោយសោមនស្ស ក្នុងលំដាប់នៃចិត្តណា នឹងកើតឡើង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ឧបេក្ខិន្ទ្រិយ របស់សត្វទាំងនោះ កាលច្យុតចាកអសញ្ញសត្វ នឹងមិនកើតឡើងផង ជីវិតិន្ទ្រិយ មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្តនោះ ក្នុងទីនោះ ។

[ ២០៣ ] ជីវិតិន្ទ្រិយ របស់សត្វណា មិនកើតឡើង ក្នុងទីណា សទ្ធិន្ទ្រិយ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ជីវិតិន្ទ្រិយ របស់សត្វទាំងនោះ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព មិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ក្នុងទីនោះ ឯសទ្ធិន្ទ្រិយ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ជីវិតិន្ទ្រិយ របស់សត្វទាំងនោះ កាលច្យុតចាកអសញ្ញសត្វ មិនកើតឡើងផង សទ្ធិន្ទ្រិយ នឹងមិនកើតឡើង

[ ៣៦៩ ] បុគ្គលណា នឹងលះបង់ នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ នឹងចម្រើននូវអញ្ញិន្ទ្រិយឬ ។ អើ ។ មួយទៀត បុគ្គលណា នឹងចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងលះបង់នូវទោមនស្សិន្ទ្រិយឬ ។ បុគ្គលពីរពួក នឹងចម្រើននូវអញ្ញិន្ទ្រិយ តែនឹងមិនលះបង់នូវទោមនស្សិន្ទ្រិយទេ ឯបុគ្គល ៥ ពួក ឈ្មោះថា នឹងចម្រើននូវអញ្ញិន្ទ្រិយផង នឹងលះបង់នូវទោមនស្សិន្ទ្រិយផង ។

[ ៣៧០ ] បុគ្គលណា នឹងលះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់ នូវអញ្ញាតាវិន្ទ្រិយឬ ។ អើ ។ មួយទៀត

បុគ្គលណា នឹងធ្វើឲ្យជាក់ច្បាស់ នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងលះបង់នូវទោមនស្សិន្ទ្រិយឬ ។ បុគ្គល ៣ ពួក នឹងធ្វើឲ្យជាក់ច្បាស់ នូវអញ្ញាតាវិន្ទ្រិយ តែនឹងមិនលះបង់នូវទោមនស្សិន្ទ្រិយទេ ឯបុគ្គល ៥ ពួក ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់ នូវអញ្ញាតាវិន្ទ្រិយផង នឹងលះបង់នូវទោមនស្សិន្ទ្រិយផង ។

[ ៣៧១ ] បុគ្គលណា នឹងចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងចម្រើននូវអញ្ញិន្ទ្រិយឬ ។ អើ ។ មួយទៀត បុគ្គលណា នឹងចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងចម្រើននូវអនញ្ញ-តញ្ញស្សាមីតិន្ទ្រិយឬ ។ បុគ្គល ៦ ពួក នឹងចម្រើននូវអញ្ញិន្ទ្រិយ តែនឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយទេ ឯពួកបុថុជ្ជនណា នឹងបានចំពោះនូវមគ្គ ពួកបុថុជ្ជននោះ ឈ្មោះថា នឹងចម្រើននូវអញ្ញិន្ទ្រិយផង នឹងចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង ។

[ ៣៧២ ] បុគ្គលណា នឹងចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ អើ ។ មួយទៀត បុគ្គលណា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ បុគ្គល ៧ ពួក នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ តែនឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយទេ ឯពួកបុថុជ្ជនណា នឹងបានចំពោះនូវមគ្គ ពួកបុថុជ្ជននោះ ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង នឹងចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង ។

[ ៣៧៣ ] បុគ្គលណា នឹងចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ អើ ។ មួយទៀត បុគ្គលណា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងចម្រើននូវអញ្ញិន្ទ្រិយឬ ។ បុគ្គលអ្នកប្រកបដោយមគ្គដ៏ប្រសើរ នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ តែនឹងមិនចម្រើននូវអញ្ញិន្ទ្រិយទេ ឯបុគ្គល ៧ ពួក ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់ នូវអញ្ញាតាវិន្ទ្រិយផង នឹងចម្រើននូវអញ្ញិន្ទ្រិយផង ។

[ ៣៧៤ ] បុគ្គលណា នឹងមិនកំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយឬ ។ អើ ។ មួយទៀត បុគ្គលណា នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនកំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ បុគ្គលពីរពួក នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយ តែមិនមែនជានឹងមិនកំណត់ដឹងនូវចក្ខុន្ទ្រិយទេ ឯបុគ្គល ៣ ពួក ឈ្មោះថា នឹងមិនលះបង់ នូវទោមនស្សិន្ទ្រិយផង នឹងមិនកំណត់ដឹង នូវចក្ខុន្ទ្រិយផង ។

[ ៣៧៥ ] បុគ្គលណា នឹងមិនកំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ អើ ។ មួយទៀត បុគ្គលណា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនកំណត់ដឹង នូវចក្ខុន្ទ្រិយឬ ។ បុគ្គល ៦ ពួក នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តែមិនមែនជានឹងមិនកំណត់ដឹងនូវចក្ខុន្ទ្រិយទេ ឯបុគ្គល ៣ ពួក ឈ្មោះថា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង

នឹងមិនកំណត់ដឹង នូវចក្ខុន្ទ្រិយផង ។

[ ៣៧៦ ] បុគ្គលណា នឹងមិនកំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយឬ ។ អើ ។ មួយទៀត បុគ្គលណា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនកំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ អើ ។

[ ៣៧៧ ] បុគ្គលណា នឹងមិនកំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ បុគ្គលអ្នកប្រកបដោយមគ្គដ៏ប្រសើរ នឹងមិនកំណត់ដឹងនូវចក្ខុន្ទ្រិយ តែមិនមែនជានឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយទេ ឯបុគ្គលពីរពួក ឈ្មោះថា នឹងមិនកំណត់ដឹងនូវចក្ខុន្ទ្រិយផង នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនកំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ អើ ។

[ ៣៧៨ ] បុគ្គលណា នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ អើ ។ មួយទៀត បុគ្គលណា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយឬ ។ បុគ្គល ៤ ពួក នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តែមិនមែនជានឹងមិនលះបង់នូវទោមនស្សិន្ទ្រិយទេ ឯបុគ្គល ៥ ពួក ឈ្មោះថា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយផង ។

[ ៣៧៩ ] បុគ្គលណា នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយឬ ។ បុគ្គលពីរពួក នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយ តែមិនមែនជានឹងមិនចម្រើននូវអញ្ញិន្ទ្រិយទេ ឯបុគ្គល ៣ ពួក ឈ្មោះថា នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយផង នឹងមិនចម្រើននូវអញ្ញិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយឬ ។ អើ ។

[ ៣៨០ ] បុគ្គលណា នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ បុគ្គល ៣ ពួក នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយ តែមិនមែនជានឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយទេ ឯបុគ្គលពីរពួក ឈ្មោះថា នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយផង នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយឬ ។ អើ ។

[ ៣៨១ ] បុគ្គលណា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយឬ ។ បុគ្គល ៦ ពួក នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តែមិនមែនជានឹងមិនចម្រើននូវអញ្ញិន្ទ្រិយទេ ឯបុគ្គល ៣ ពួក នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង នឹងមិនចម្រើននូវអញ្ញិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ អើ ។

[ ៣៨២ ] បុគ្គលណា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ បុគ្គល ៧ ពួក នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តែមិនមែនជានឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយទេ ឯបុគ្គលពីរពួក ឈ្មោះថា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ អើ ។

[ ៣៨៣ ] បុគ្គលណា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ បុគ្គលអ្នកប្រកបដោយមគ្គដ៏ប្រសើរ នឹងមិនចម្រើននូវអញ្ញិន្ទ្រិយ តែមិនមែនជានឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយទេ ឯបុគ្គលពីរពួក ឈ្មោះថា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយផង នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយឬ ។ អើ ។

[ ៣៨៤ ] បុគ្គលណា កំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា លះបង់ហើយ នូវទោមនស្សិន្ទ្រិយឬ ។ អើ ។ មួយទៀត បុគ្គលណា លះបង់ហើយ នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ បុគ្គលពីរពួក លះបង់ហើយ នូវទោមនស្សិន្ទ្រិយ តែមិនកំណត់ដឹងនូវចក្ខុន្ទ្រិយទេ បុគ្គលអ្នកប្រកបដោយមគ្គដ៏ប្រសើរ ឈ្មោះថា

លះបង់ហើយ នូវទោមនស្សិន្ទ្រិយផង កំណត់ដឹង នូវចក្ខុន្ទ្រិយផង ។

[ ៣៨៥ ] បុគ្គលណា កំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា ចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ អើ ។ មួយទៀត បុគ្គលណា ចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ បុគ្គល ៦ ពួក ចម្រើនហើយ នូវអនញ្ញា-តញ្ញស្សាមីតិន្ទ្រិយ តែមិនកំណត់ដឹងនូវចក្ខុន្ទ្រិយទេ ឯបុគ្គលអ្នកប្រកបដោយមគ្គដ៏ប្រសើរ ឈ្មោះថា ចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង កំណត់ដឹងនូវចក្ខុន្ទ្រិយផង ។

[ ៣៨៦ ] បុគ្គលណា កំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា ចម្រើនហើយ នូវអញ្ញិន្ទ្រិយឬ ។ មិនមែនទេ ។ មួយទៀត បុគ្គលណា ចម្រើនហើយ នូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ មិនមែនទេ ។

[ ៣៨៧ ] បុគ្គលណា កំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា ធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ មិនមែនទេ ។ មួយទៀត បុគ្គលណា ធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ មិនមែនទេ ។

[ ៣៨៨ ] បុគ្គលណា លះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា ចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ អើ ។ មួយទៀត បុគ្គលណា ចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះ

ថា លះបង់នូវទោមនស្សិន្ទ្រិយឬ ។ បុគ្គល ៦ ពួក ចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តែមិនលះបង់នូវទោមនស្សិន្ទ្រិយទេ ឯបុគ្គលអ្នកប្រកបដោយអនាគាមិមគ្គ ឈ្មោះថា ចម្រើនហើយ នូវអនញ្ញាតញ្ញស្សា-មីតិន្ទ្រិយផង លះបង់នូវទោមនស្សិន្ទ្រិយផង ។

[ ៣៨៩ ] បុគ្គលណា លះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា ចម្រើនហើយ នូវអញ្ញិន្ទ្រិយឬ ។ មិនមែនទេ ។ មួយទៀត បុគ្គលណា ចម្រើនហើយ នូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា លះបង់នូវទោមនស្សិន្ទ្រិយឬ ។ មិនមែនទេ ។

[ ៣៩០ ] បុគ្គលណា លះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា ធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយឬ ។ មិនមែនទេ ។ មួយទៀត បុគ្គលណា ធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា លះបង់នូវទោមនស្សិន្ទ្រិយឬ ។ មិនមែនទេ ។

[ ៣៩១ ] បុគ្គលណា ចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា ចម្រើនហើយ នូវអញ្ញិន្ទ្រិយឬ ។ មិនមែនទេ ។ មួយទៀត បុគ្គលណា ចម្រើនហើយ នូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា ចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ មិនមែនទេ ។

[ ៣៩២ ] បុគ្គលណា ចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា ធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយឬ ។ មិនមែនទេ ។ មួយទៀត បុគ្គលណា ធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយ បុគ្គល

នោះ ឈ្មោះថា ចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ មិនមែនទេ ។

[ ៣៩៣ ] បុគ្គលណា ចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា ធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយឬ ។ មិនមែនទេ ។ មួយទៀត បុគ្គលណា ធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា ចម្រើននូវអញ្ញិន្ទ្រិយឬ ។ មិនមែនទេ ។

[ ៣៩៤ ] បុគ្គលណា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយឬ ។ បុគ្គលពីរពួក មិនកំណត់ដឹងនូវចក្ខុន្ទ្រិយ តែមិនមែនជាមិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយទេ ឯបុគ្គល ៦ ពួក ឈ្មោះថា មិនកំណត់ដឹង នូវចក្ខុន្ទ្រិយផង មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយផង ។ មួយទៀត បុគ្គលណា មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ អើ ។

[ ៣៩៥ ] បុគ្គលណា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ បុគ្គល ៦ ពួក មិនកំណត់ដឹងនូវចក្ខុន្ទ្រិយ មិនមែនជាមិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយទេ ឯបុគ្គលពីរពួក ឈ្មោះថា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយផង មិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង ។ មួយទៀត បុគ្គលណា មិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ អើ ។

[ ៣៩៦ ] បុគ្គលណា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា

មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយឬ ។ ព្រះអរហន្ត មិនកំណត់ដឹងនូវចក្ខុន្ទ្រិយ តែមិនមែនជាមិនចម្រើនហើយ នូវអញ្ញិន្ទ្រិយទេ បុគ្គល ៧ ពួក ឈ្មោះថា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយផង មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយផង ។ មួយទៀត បុគ្គលណា មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ បុគ្គលអ្នកប្រកបដោយមគ្គដ៏ប្រសើរ មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយ តែមិនមែនជាមិនកំណត់ដឹងនូវចក្ខុន្ទ្រិយទេ ឯបុគ្គល ៧ ពួក ឈ្មោះថា មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយផង មិនកំណត់ដឹងនូវចក្ខុន្ទ្រិយផង ។

[ ៣៩៧ ] បុគ្គលណា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយឬ ។ ព្រះអរហន្តមិនកំណត់ដឹងនូវចក្ខុន្ទ្រិយ តែមិនមែនជាមិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយទេ ឯបុគ្គល ៨ ពួក ឈ្មោះថា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយផង មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ បុគ្គលអ្នកប្រកបដោយមគ្គដ៏ប្រសើរ មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយ តែមិនមែនជាមិនកំណត់ដឹងនូវចក្ខុន្ទ្រិយទេ ឯបុគ្គល ៨ ពួក ឈ្មោះថា មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយផង មិនកំណត់ដឹងនូវចក្ខុន្ទ្រិយផង ។

[ ៣៩៨ ] បុគ្គលណា មិនលះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះ

ថា មិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ បុគ្គល ៦ ពួក មិនលះបង់នូវទោមនស្សិន្ទ្រិយ តែមិនមែនជាមិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយទេ បុគ្គលពីរពួក ឈ្មោះថា មិនលះបង់នូវទោមនស្សិន្ទ្រិយផង មិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង ។ មួយទៀត បុគ្គលណា មិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនលះបង់នូវទោមនស្សិន្ទ្រិយឬ ។ អើ ។

[ ៣៩៩ ] បុគ្គលណា មិនលះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយឬ ។ ព្រះអរហន្ត មិនលះបង់នូវទោមនស្សិន្ទ្រិយ តែមិនមែនជាមិនចម្រើនហើយ នូវអញ្ញិន្ទ្រិយទេ ឯបុគ្គល ៧ ពួក ឈ្មោះថា មិនលះបង់នូវទោមនស្សិន្ទ្រិយផង មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយផង ។ មួយទៀត បុគ្គលណា មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនលះបង់នូវទោមនស្សិន្ទ្រិយឬ ។ បុគ្គលអ្នកប្រកបដោយអនាគាមិមគ្គ មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយ តែមិនមែនជាមិនលះបង់នូវទោមនស្សិន្ទ្រិយទេ ឯបុគ្គល ៧ ពួក ឈ្មោះថា មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយផង មិនលះបង់នូវទោមនស្សិន្ទ្រិយផង ។

[ ៤០០ ] បុគ្គលណា មិនលះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយឬ ។ ព្រះអរហន្ត មិនលះបង់នូវទោមនស្សិន្ទ្រិយ តែមិនមែនជាមិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយទេ ឯបុគ្គល ៨ ពួក ឈ្មោះថា មិនលះបង់នូវទោមនស្សិន្ទ្រិយ

ផង មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនលះបង់នូវទោមនស្សិន្ទ្រិយឬ ។ បុគ្គលអ្នកប្រកបដោយអនាគាមិមគ្គ មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយ តែមិនមែនជាមិនលះបង់នូវទោមនស្សិន្ទ្រិយទេ ឯបុគ្គល ៨ ពួក ឈ្មោះថា មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយផង មិនលះបង់នូវទោមនស្សិន្ទ្រិយផង ។

[ ៤០១ ] បុគ្គលណា មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយឬ ។ ព្រះអរហន្ត មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តែមិនមែនជាមិនចម្រើនហើយ នូវអញ្ញិន្ទ្រិយទេ ឯបុគ្គល ៧ ពួក ឈ្មោះថា មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយផង ។ មួយទៀត បុគ្គលណា មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ បុគ្គលទី ៨ មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយ តែមិនមែនជាមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយទេ ឯបុគ្គល ៧ ពួក ឈ្មោះថា មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយផង មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង ។

[ ៤០២ ] បុគ្គលណា មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយឬ ។ ព្រះអរហន្ត មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តែមិនមែនជាមិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយទេ ឯបុគ្គល ៧ ពួក ឈ្មោះថា មិនចម្រើន

នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ បុគ្គលទី ៨ មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយ តែមិនមែនជាមិនចម្រើន នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយទេ ឯបុគ្គល ៧ ពួក ឈ្មោះថា មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយផង មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង ។

[ ៤០៣ ] បុគ្គលណា មិនចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយឬ ។ ព្រះអរហន្ត មិនចម្រើន នូវអញ្ញិន្ទ្រិយ តែមិនមែនជាមិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយទេ ឯបុគ្គល ៥ ពួក ឈ្មោះថា មិនចម្រើននូវអញ្ញិន្ទ្រិយផង មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនចម្រើននូវអញ្ញិន្ទ្រិយឬ ។ បុគ្គល ៣ ពួក អ្នកប្រកបដោយមគ្គដ៏ប្រសើរ មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយ តែមិនមែនជាមិនចម្រើននូវអញ្ញិន្ទ្រិយទេ បុគ្គល ៥ ពួក ឈ្មោះថា មិនធ្វើឲ្យជាក់ច្បាស់ហើយ នូវអញ្ញាតាវិន្ទ្រិយផង មិនចម្រើននូវអញ្ញិន្ទ្រិយផង ។

[ ៤០៤ ] បុគ្គលណា កំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងលះបង់នូវទោមនស្សិន្ទ្រិយឬ ។ មិនមែនទេ ។ មួយទៀត បុគ្គលណា

នឹងលះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ មិនមែនទេ ។

[ ៤០៥ ] បុគ្គលណា កំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ មិនមែនទេ ។ មួយទៀត បុគ្គលណា នឹងចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ មិនមែនទេ ។

[ ៤០៦ ] បុគ្គលណា កំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងចម្រើននូវអញ្ញិន្ទ្រិយឬ ។ មិនមែនទេ ។ មួយទៀត បុគ្គលណា នឹងចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ មិនមែនទេ ។

[ ៤០៧ ] បុគ្គលណា កំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ អើ ។ មួយទៀត បុគ្គលណា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ បុគ្គល ៧ ពួក នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ តែមិនកំណត់ដឹងនូវចក្ខុន្ទ្រិយទេ ឯបុគ្គលអ្នកប្រកបដោយមគ្គដ៏ប្រសើរ ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់ នូវអញ្ញាតាវិន្ទ្រិយផង កំណត់ដឹងនូវចក្ខុន្ទ្រិយផង ។

[ ៤០៨ ] បុគ្គលណា លះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ មិនមែនទេ ។ មួយទៀត បុគ្គលណា នឹងចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា

លះបង់នូវទោមនស្សិន្ទ្រិយឬ ។ មិនមែនទេ ។

[ ៤០៩ ] បុគ្គលណា លះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងចម្រើននូវអញ្ញិន្ទ្រិយឬ ។ អើ ។ មួយទៀត បុគ្គលណា នឹងចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា លះបង់នូវទោមនស្សិន្ទ្រិយឬ ។ បុគ្គល ៦ ពួក នឹងចម្រើននូវអញ្ញិន្ទ្រិយ តែមិនលះបង់នូវទោមនស្សិន្ទ្រិយទេ ឯបុគ្គលអ្នកប្រកបដោយអនាគាមិមគ្គ ឈ្មោះថា នឹងចម្រើននូវអញ្ញិន្ទ្រិយផង លះបង់នូវទោមនស្សិន្ទ្រិយផង ។

[ ៤១០ ] បុគ្គលណា លះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ អើ ។ មួយទៀត បុគ្គលណា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា លះបង់នូវទោមនស្សិន្ទ្រិយឬ ។ បុគ្គល ៧ ពួក នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ តែមិនលះបង់នូវទោមនស្សិន្ទ្រិយទេ ឯបុគ្គលអ្នកប្រកបដោយអនាគាមិមគ្គ ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង លះបង់នូវទោមនស្សិន្ទ្រិយផង ។

[ ៤១១ ] បុគ្គលណា ចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងចម្រើននូវអញ្ញិន្ទ្រិយឬ ។ អើ ។ មួយទៀត បុគ្គលណា នឹងចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា ចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ បុគ្គល ៦ ពួក នឹងចម្រើននូវអញ្ញិន្ទ្រិយ តែមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយទេ ឯបុគ្គលទី ៨ ឈ្មោះថា នឹងចម្រើននូវអញ្ញិន្ទ្រិយ

ផង ចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង ។

[ ៤១២ ] បុគ្គលណា ចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ អើ ។ មួយទៀត បុគ្គលណា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា ចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ បុគ្គល ៧ ពួក នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ តែមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយទេ ឯបុគ្គលទី ៨ ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង ចម្រើននូវអនញ្ញា-តញ្ញស្សាមីតិន្ទ្រិយផង ។

[ ៤១៣ ] បុគ្គលណា ចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា ធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ អើ ។ មួយទៀត បុគ្គលណា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា ចម្រើននូវអញ្ញិន្ទ្រិយឬ ។ បុគ្គល ៥ ពួក នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ តែមិនចម្រើននូវអញ្ញិន្ទ្រិយទេ ឯបុគ្គល ៣ ពួក អ្នកប្រកបដោយមគ្គដ៏ប្រសើរ ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង ចម្រើននូវអញ្ញិន្ទ្រិយផង ។

[ ៤១៤ ] បុគ្គលណា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនលះបង់នូវទោមនស្សិន្ទ្រិយឬ ។ បុគ្គល ៥ ពួក មិនកំណត់ដឹងនូវចក្ខុន្ទ្រិយ តែមិនមែនជាមិនលះបង់នូវទោមនស្សិន្ទ្រិយទេ ឯបុគ្គល ៤ ពួក ឈ្មោះថា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយផង នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ

ឈ្មោះថា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ បុគ្គលអ្នកប្រកបដោយមគ្គដ៏ប្រសើរ នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយ តែមិនមែនជាមិនកំណត់ដឹងនូវចក្ខុន្ទ្រិយទេ ឯបុគ្គល ៤ ពួក ឈ្មោះថា នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយផង មិនកំណត់ដឹងនូវចក្ខុន្ទ្រិយផង ៗ

[ ៤១៥ ] បុគ្គលណា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ ពួកបុថុជ្ជនណា នឹងបានចំពោះនូវមគ្គ ពួកបុថុជ្ជននោះ មិនកំណត់ដឹងនូវចក្ខុន្ទ្រិយ តែមិនមែនជានឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយទេ ឯបុគ្គល ៨ ពួក ឈ្មោះថា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយផង នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង ៗ មួយទៀត បុគ្គលណា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ បុគ្គលអ្នកប្រកបដោយមគ្គដ៏ប្រសើរ នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តែមិនមែនជាមិនកំណត់ដឹងនូវចក្ខុន្ទ្រិយទេ ឯបុគ្គល ៨ ពួក ឈ្មោះថា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សា-មីតិន្ទ្រិយផង មិនកំណត់ដឹងនូវចក្ខុន្ទ្រិយផង ៗ

[ ៤១៦ ] បុគ្គលណា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយឬ ។ បុគ្គល ៧ ពួក មិនកំណត់ដឹងនូវចក្ខុន្ទ្រិយ តែមិនមែនជានឹងមិនចម្រើននូវអញ្ញិន្ទ្រិយទេ ឯបុគ្គលពីរពួក ឈ្មោះថា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយផង នឹងមិនចម្រើននូវអញ្ញិន្ទ្រិយផង ៗ មួយទៀត បុគ្គលណា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនកំណត់

ដឹងនូវចក្ខុន្ទ្រិយឬ ។ បុគ្គល អ្នកប្រកបដោយមគ្គដ៏ប្រសើរ នឹងមិនចម្រើននូវអញ្ញិន្ទ្រិយ តែមិនមែនជាមិនកំណត់ដឹងនូវចក្ខុន្ទ្រិយទេ ឯបុគ្គលពីរពួក ឈ្មោះថា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយផង មិនកំណត់ដឹងនូវចក្ខុន្ទ្រិយផង ។

[ ៤១៧ ] បុគ្គលណា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ បុគ្គល ៧ ពួក មិនកំណត់ដឹងនូវចក្ខុន្ទ្រិយ តែមិនមែនជានឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយទេ ឯបុគ្គលពីរពួក ឈ្មោះថា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយផង នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹងនូវចក្ខុន្ទ្រិយឬ ។ អើ ។

[ ៤១៨ ] បុគ្គលណា មិនលះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ ពួកបុថុជ្ជនណា នឹងបានចំពោះនូវមគ្គ ពួកបុថុជ្ជនទោះ មិនលះបង់នូវទោមនស្សិន្ទ្រិយ តែមិនមែនជានឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយទេ ឯបុគ្គល ៨ ពួក ឈ្មោះថា មិនលះបង់នូវទោមនស្សិន្ទ្រិយផង នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនលះបង់នូវទោមនស្សិន្ទ្រិយឬ ។ បុគ្គលអ្នកប្រកបដោយអនាគាមិមគ្គ នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តែមិនមែនជាមិនលះបង់នូវទោមនស្សិន្ទ្រិយទេ ឯបុគ្គល ៨ ពួក ឈ្មោះថា នឹងមិន

ចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង មិនលះបង់នូវទោមនស្សិន្ទ្រិយផង ។

[ ៤១៩ ] បុគ្គលណា មិនលះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយឬ ។ បុគ្គល ៦ ពួក មិនលះបង់នូវទោមនស្សិន្ទ្រិយ តែមិនមែនជានឹងមិនចម្រើន នូវអញ្ញិន្ទ្រិយទេ ឯបុគ្គល ៣ ពួក ឈ្មោះថា នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយផង នឹងមិនចម្រើននូវអញ្ញិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនលះបង់នូវទោមនស្សិន្ទ្រិយឬ ។ អើ ។

[ ៤២០ ] បុគ្គលណា មិនលះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ បុគ្គល ៧ ពួក មិនលះបង់នូវទោមនស្សិន្ទ្រិយ តែមិនមែនជានឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតា-វិន្ទ្រិយទេ ឯបុគ្គលពីរពួក ឈ្មោះថា មិនលះបង់នូវទោមនស្សិន្ទ្រិយផង នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនលះបង់នូវទោមនស្សិន្ទ្រិយឬ ។ អើ ។

[ ៤២១ ] បុគ្គលណា មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយឬ ។ បុគ្គល ៦ ពួក មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តែមិនមែនជានឹងមិនចម្រើន នូវអញ្ញិន្ទ្រិយទេ ឯបុគ្គល ៣ ពួក ឈ្មោះថា មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង នឹងមិនចម្រើននូវអញ្ញិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនចម្រើននូវ

អញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ឬ ។ អើ ។

[ ៤២២ ] បុគ្គលណា មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ បុគ្គល ៧ ពួក មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តែមិនមែនជានឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយទេ ឯបុគ្គលពីរពួក ឈ្មោះថា មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ អើ ។

[ ៤២៣ ] បុគ្គលណា មិនចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ បុគ្គល ៥ ពួក មិនចម្រើននូវអញ្ញិន្ទ្រិយ តែមិនមែនជានឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយទេ ឯបុគ្គលពីរពួក ឈ្មោះថា មិនចម្រើននូវអញ្ញិន្ទ្រិយផង នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនចម្រើននូវអញ្ញិន្ទ្រិយឬ ។ អើ ។

[ ៤២៤ ] បុគ្គលណា កំណត់ដឹងហើយនូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា លះបង់នូវទោមនស្សិន្ទ្រិយឬ ។ មិនមែនទេ ។ មួយទៀត បុគ្គលណា នឹងលះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងហើយនូវចក្ខុន្ទ្រិយឬ ។ មិនមែនទេ ។

[ ៤២៥ ] បុគ្គលណា កំណត់ដឹងហើយ នូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ មិនមែនទេ ។ មួយទៀត បុគ្គលណា នឹងចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងហើយ នូវចក្ខុន្ទ្រិយឬ ។ មិនមែនទេ ។

[ ៤២៦ ] បុគ្គលណា កំណត់ដឹងហើយ នូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងចម្រើននូវអញ្ញិន្ទ្រិយឬ ។ មិនមែនទេ ។ មួយទៀត បុគ្គលណា នឹងចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងហើយ នូវចក្ខុន្ទ្រិយឬ ។ មិនមែនទេ ។

[ ៤២៧ ] បុគ្គលណា កំណត់ដឹងហើយ នូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ មិនមែនទេ ។ មួយទៀត បុគ្គលណា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងហើយ នូវចក្ខុន្ទ្រិយឬ ។ មិនមែនទេ ។

[ ៤២៨ ] បុគ្គលណា លះបង់ហើយ នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ មិនមែនទេ ។ មួយទៀត បុគ្គលណា នឹងចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា លះបង់ហើយ នូវទោមនស្សិន្ទ្រិយឬ ។ មិនមែនទេ ។

[ ៤២៩ ] បុគ្គលណា លះបង់ហើយ នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងចម្រើននូវអញ្ញិន្ទ្រិយឬ ។ បុគ្គលពីរពួក លះបង់ហើយ នូវ

ទោមនស្សិន្ទ្រិយ តែនឹងមិនចម្រើននូវអញ្ញិន្ទ្រិយទេ ឯអនាគាមិបុគ្គល ឈ្មោះថា លះបង់ហើយ នូវទោមនស្សិន្ទ្រិយផង នឹងចម្រើននូវអញ្ញិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា លះបង់ហើយ នូវទោមនស្សិន្ទ្រិយឬ ។ បុគ្គល ៦ ពួក នឹងចម្រើននូវអញ្ញិន្ទ្រិយ តែមិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយទេ ឯអនាគាមិបុគ្គល ឈ្មោះថា នឹងចម្រើននូវអញ្ញិន្ទ្រិយផង លះបង់ហើយ នូវទោមនស្សិន្ទ្រិយផង ។

[ ៤៣០ ] បុគ្គលណា លះបង់ហើយ នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ ព្រះអរហន្ត លះបង់ហើយ នូវទោមនស្សិន្ទ្រិយ តែនឹងមិនធ្វើឲ្យជាក់ច្បាស់ នូវអញ្ញាតាវិន្ទ្រិយទេ ឯបុគ្គលពីរពួក ឈ្មោះថា លះបង់ហើយ នូវទោមនស្សិន្ទ្រិយផង នឹងធ្វើឲ្យជាក់ច្បាស់ នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា លះបង់ហើយ នូវទោម-នស្សិន្ទ្រិយឬ ។ បុគ្គល ៦ ពួក នឹងធ្វើឲ្យជាក់ច្បាស់ នូវអញ្ញាតាវិន្ទ្រិយ តែមិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយទេ ឯបុគ្គលពីរពួក ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់ នូវអញ្ញាតាវិន្ទ្រិយផង លះបង់ហើយ នូវទោមនស្សិន្ទ្រិយផង ។

[ ៤៣១ ] បុគ្គលណា ចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងចម្រើននូវអញ្ញិន្ទ្រិយឬ ។ បុគ្គលពីរពួក ចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តែនឹងមិនចម្រើននូវអញ្ញិន្ទ្រិយទេ ឯបុគ្គល ៥ ពួក ឈ្មោះថា ចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង

នឹងចម្រើននូវអញ្ញិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា ចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ បុគ្គលពីរពួក នឹងចម្រើននូវអញ្ញិន្ទ្រិយ តែមិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយទេ ឯបុគ្គល ៥ ពួក ឈ្មោះថា នឹងចម្រើននូវអញ្ញិន្ទ្រិយផង ចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង ។

[ ៤៣២ ] បុគ្គលណា ចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ ព្រះអរហន្តចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តែនឹងមិនធ្វើឲ្យជាក់ច្បាស់ នូវអញ្ញាតាវិន្ទ្រិយទេ ឯបុគ្គល ៦ ពួក ឈ្មោះថា ចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង នឹងធ្វើឲ្យជាក់ច្បាស់ នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា ចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ បុគ្គលពីរពួក នឹងធ្វើឲ្យជាក់ច្បាស់ នូវអញ្ញាតាវិន្ទ្រិយ តែមិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយទេ ឯបុគ្គល ៦ ពួក ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង ចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង ។

[ ៤៣៣ ] បុគ្គលណា នឹងចម្រើនហើយ នូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ មិនមែនទេ ។ មួយទៀត បុគ្គលណា នឹងធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងចម្រើនហើយ នូវអញ្ញិន្ទ្រិយឬ ។ មិនមែនទេ ។

[ ៤៣៤ ] បុគ្គលណា មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយ បុគ្គលនោះឈ្មោះថា នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយឬ ។ បុគ្គល ៥ ពួក មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយ តែមិនមែនជានឹងមិនលះបង់នូវទោមនស្សិន្ទ្រិយទេ ឯបុគ្គល ៣ ពួក ឈ្មោះថា មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយផង នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយឬ ។ ព្រះអរហន្ត នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយ តែមិនមែនជាមិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយទេ ឯបុគ្គល ៣ ពួក ឈ្មោះថា នឹងមិនលះបង់នូវទោមនស្សិន្ទ្រិយផង មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយផង ។

[ ៤៣៥ ] បុគ្គលណា មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយ បុគ្គលនោះឈ្មោះថា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ ពួកបុថុជ្ជនណា នឹងបានចំពោះនូវមគ្គ ពួកបុថុជ្ជននោះ មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយ តែមិនមែនជានឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយទេ ឯបុគ្គល ៨ ពួក ឈ្មោះថា មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយផង នឹងមិនចម្រើន នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយឬ ។ ព្រះអរហន្ត នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តែមិនមែនជាមិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយទេ ឯបុគ្គល ៨ ពួក ឈ្មោះថា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយផង ។

[ ៤៣៦ ] បុគ្គលណា មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយឬ ។ បុគ្គល ៧ ពួក មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយ តែមិនមែនជានឹងមិនចម្រើននូវអញ្ញិន្ទ្រិយទេ ឯបុគ្គលពីរពួក ឈ្មោះថា មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយផង នឹងមិនចម្រើននូវអញ្ញិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយឬ ។ ព្រះអរហន្ត នឹងមិនចម្រើននូវអញ្ញិន្ទ្រិយ តែមិនមែនជាមិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយទេ ឯបុគ្គលពីរពួក ឈ្មោះថា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយផង មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយផង ។

[ ៤៣៧ ] បុគ្គលណា មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ បុគ្គល ៨ ពួក មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយ តែមិនមែនជានឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយទេ ឯពួកបុថុជ្ជនណា នឹងមិនបានចំពោះនូវមគ្គ ពួកបុថុជ្ជននោះ ឈ្មោះថា មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយផង នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយឬ ។ ព្រះអរហន្ត នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ តែមិនមែនជាមិនកំណត់ដឹងហើយ នូវចក្ខុន្ទ្រិយទេ ឯពួកបុថុជ្ជនណា នឹងមិនបានចំពោះនូវមគ្គ ពួកបុថុជ្ជននោះ ឈ្មោះថា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង មិនកំណត់

ដឹងហើយ នូវចក្ខុន្ទ្រិយផង ។

[ ៤៣៨ ] បុគ្គលណា មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ ពួកបុថុជ្ជនណា នឹងបានចំពោះនូវមគ្គ ពួកបុថុជ្ជននោះ មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយ តែមិនមែនជានឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយទេ ឯបុគ្គល ៦ ពួក ឈ្មោះថា មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយផង នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយឬ ។ បុគ្គល ៣ ពួក នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តែមិនមែនជានឹងមិនលះបង់នូវទោមនស្សិន្ទ្រិយទេ ឯបុគ្គល ៦ ពួក ឈ្មោះថា នឹងមិនចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយផង ។

[ ៤៣៩ ] បុគ្គលណា មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយឬ ។ បុគ្គល ៦ ពួក មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយ តែមិនមែនជានឹងមិនចម្រើននូវអញ្ញិន្ទ្រិយទេ ឯពួកបុថុជ្ជនណា នឹងមិនបានចំពោះនូវមគ្គ ពួកបុថុជ្ជននោះ ឈ្មោះថា មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយផង នឹងមិនចម្រើននូវអញ្ញិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយឬ ។ បុគ្គលពីរពួក នឹងមិនចម្រើននូវ

អញ្ញិន្ទ្រិយ តែមិនមែនជាមិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយទេ ឯពួកបុថុជ្ជនណា នឹងមិនបានចំពោះនូវមគ្គ ពួកបុថុជ្ជននោះ ឈ្មោះថា មិនចម្រើននូវអញ្ញិន្ទ្រិយផង មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយផង ។

[ ៤៤០ ] បុគ្គលណា មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ ឯបុគ្គល ៦ ពួក មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយ តែមិនមែនជានឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយទេ ឯពួកបុថុជ្ជនណា នឹងមិនបានចំពោះនូវមគ្គ ពួកបុថុជ្ជននោះ ឈ្មោះថា មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយផង នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយឬ ។ ព្រះអរហន្ត នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ តែមិនមែនជាមិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយទេ ពួកបុថុជ្ជនណា នឹងមិនបានចំពោះនូវមគ្គ ពួកបុថុជ្ជននោះ ឈ្មោះថា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង មិនលះបង់ហើយ នូវទោមនស្សិន្ទ្រិយផង ។

[ ៤៤១ ] បុគ្គលណា មិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនចម្រើននូវអញ្ញិន្ទ្រិយឬ ។ បុគ្គលពីរពួក មិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តែមិនមែនជានឹងមិនចម្រើននូវអញ្ញិន្ទ្រិយទេ ឯពួកបុថុជ្ជនណា នឹងមិនបានចំពោះនូវមគ្គ ពួកបុថុជ្ជននោះ ឈ្មោះថា មិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង នឹងមិនចម្រើន

នូវអញ្ញិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ បុគ្គលពីរពួក នឹងមិនចម្រើននូវអញ្ញិន្ទ្រិយ តែមិនមែនជាមិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយទេ ឯពួកបុថុជ្ជនណា នឹងមិនបានចំពោះនូវមគ្គ ពួកបុថុជ្ជននោះ ឈ្មោះថា នឹងមិនចម្រើននូវអញ្ញិន្ទ្រិយផង មិនចម្រើនហើយនូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង ។

[ ៤៤២ ] បុគ្គលណា មិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ បុគ្គលពីរពួក មិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តែមិនមែនជានឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយទេ ឯពួកបុថុជ្ជនណា នឹងបានចំពោះនូវមគ្គ ពួកបុថុជ្ជននោះ ឈ្មោះថា មិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនចម្រើនហើយនូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយឬ ។ ព្រះអរហន្ត នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ តែមិនមែនជាមិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយទេ ឯពួកបុថុជ្ជនណា នឹងមិនបានចំពោះនូវមគ្គ ពួកបុថុជ្ជននោះ ឈ្មោះថា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង មិនចម្រើនហើយ នូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយផង ។

[ ៤៤៣ ] បុគ្គលណា មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយ បុគ្គលនោះ

ឈ្មោះថា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយឬ ។ បុគ្គល ៨ ពួក មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយ តែមិនមែនជានឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយទេ ឯពួកបុថុជ្ជនណា នឹងមិនបានចំពោះនូវមគ្គ ពួកបុថុជ្ជននោះ ឈ្មោះថា មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយផង នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង ។ មួយទៀត បុគ្គលណា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយឬ ។ ព្រះអរហន្ត នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ តែមិនមែនជាមិនចម្រើនហើយ នូវអញ្ញិន្ទ្រិយទេ ឯពួកបុថុជ្ជនណា នឹងមិនបានចំពោះនូវមគ្គ ពួកបុថុជ្ជននោះ ឈ្មោះថា នឹងមិនធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយផង មិនចម្រើនហើយ នូវអញ្ញិន្ទ្រិយផង ។

ឥន្ទ្រិយយមកៈទី ១០ ចប់

យមកប្បករណៈ បច្ឆិមភាគ ចប់

# អដ្ឋកថា

## ឥន្ទ្រិយយមកៈ

[ ១-១១១ ] ឥឡូវនេះ ជាកិច្ចពណ៌នាឥន្ទ្រិយយមកៈ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងក្នុងលំដាប់បន្ទាប់អំពីធម្មយមកៈ ព្រោះទ្រង់សង្គ្រោះធម៌ទាំងឡាយ មានកុសលធម៌ជាដើម ដែលទ្រង់សម្តែងហើយ ក្នុងមូលយមកៈទាំងនោះឯង ឲ្យជាចំណែកមួយដោយអំណាចនៃធម៌ដែលបាន ។ ក្នុងឥន្ទ្រិយយមកៈនោះ គប្បីជ្រាបការកំណត់ព្រះបាលី ដោយន័យដែលពោលហើយ ក្នុងខន្ធយមកៈជាដើមនោះឯង ។

ក្នុងឥន្ទ្រិយយមកៈនេះ មហាវារៈ ៣ មានបណ្ណត្តិវារៈជាដើម និងអន្តរវារៈដ៏សេស ក៏ដូចគ្នាតាមដែលមកហើយ ក្នុងយមកៈទាំងឡាយ មានខន្ធយមកៈជាដើមនោះឯង មួយអន្លើដោយប្រភេទនៃកាលជាដើម តែយមកៈទាំងឡាយមានច្រើនជាងធាតុយមកៈ ព្រោះភាពនៃឥន្ទ្រិយទាំងឡាយមានច្រើន លោកមិនប្រកបជិវ្ហាយតនៈ និងកាយាយតនៈជាមួយចក្ខាយតនៈ និងចក្ខុធាតុ ដោយន័យដែលមានចក្ខាយតនៈ និងចក្ខុធាតុជាមូល ក្នុងបុគ្គលវារៈជាដើម ខាងដើម និងមិនកាន់យកយមកៈទាំងឡាយ មានជិវ្ហាយតនៈ និងកាយាយតនៈជាមូល យ៉ាងណា ក្នុងឥន្ទ្រិយយមកៈនេះ លោកក៏មិនប្រកបជិវ្ហិន្ទ្រិយ និងកាយិន្ទ្រិយ ក្នុងន័យដែលមានចក្ខុន្ទ្រិយជាមូល និងមិនកាន់យកយមកៈទាំងឡាយ ដែលមានជិវ្ហិន្ទ្រិយ និងកាយិន្ទ្រិយជាមូលយ៉ាងនោះដូចគ្នា ។ គប្បីជ្រាបហេតុក្នុងការមិនកាន់យកយមកៈទាំងឡាយនោះ តាមន័យដែលលោកពោលហើយ ក្នុងយមកៈនោះឯង ។

ឯមនិន្ទ្រិយ គប្បីជ្រាបថា លោកប្រកបហើយ ដោយមូលទាំងឡាយ មានចក្ខុន្ទ្រិយជាមូលជាដើម យ៉ាងណា សូម្បីមូលទាំងឡាយ មានឥន្ទ្រិយជាមូល ក៏យ៉ាងនោះឯង មនិន្ទ្រិយ រមែងដល់នូវការប្រកប ព្រោះហេតុណា ព្រោះហេតុនោះ គប្បីជ្រាបថា លោកមិនប្រកបហើយ ដោយលំដាប់បទដែលលើកឡើង ប្រកបក្នុងទីបំផុតជាមួយមូលទាំងឡាយ មានចក្ខុន្ទ្រិយទាំងអស់នោះជាដើម ។

លោកប្រកបឥត្ថិន្ទ្រិយ និងចក្ខុន្ទ្រិយ បុរិសិន្ទ្រិយ និងចក្ខុន្ទ្រិយ ជីវិតិន្ទ្រិយ និងចក្ខុន្ទ្រិយ ។ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ ទោមនស្សិន្ទ្រិយ មិនមានក្នុងបដិសន្ធិ ព្រោះហេតុនោះ ទើបលោកមិនកាន់យក ។

សោមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ លោកកាន់យកហើយ ក្នុងបដិសន្ធិ ព្រោះកើតមានព្រមនឹងការកើតឡើង ។ ឥន្ទ្រិយ ៥ មានសទ្ធិន្ទ្រិយជាដើម ក៏ដូចគ្នា ។ ឥន្ទ្រិយដែលជាលោកុត្តរ ៣ លោកមិនកាន់យក ព្រោះមិនមានក្នុងបដិសន្ធិនោះឯង ។ ឥន្ទ្រិយទាំងឡាយណា លោកកាន់យកហើយ ដោយអំណាចនៃឥន្ទ្រិយទាំងនោះ គប្បីជ្រាបការរាប់យមកៈ ក្នុងន័យដែលមានចក្ខុន្ទ្រិយជាមូល ក្នុងឥន្ទ្រិយយមកៈនេះ ដោយប្រការដូច្នេះ ។ ក្នុងទីនេះ គប្បីជ្រាបការរាប់យមកៈ ក្នុងន័យដែលមានចក្ខុន្ទ្រិយជាមូល ក្នុងទីនេះ យ៉ាងណា ក្នុងទីទាំងពួង ក៏យ៉ាងនោះ គប្បីជ្រាបការកំណត់ព្រះបាលី ក្នុងវារៈទាំងឡាយ យ៉ាងនេះជាមុនថា យមកៈទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់កាន់យកហើយ គួររាប់យមកៈទាំងឡាយ ដោយអំណាចនៃ

យមកៈទាំងនោះ ។ម្យ៉ាងទៀត កាលរាប់ គប្បីរាប់ដោយអំណាចនៃមោឃបុច្ឆា ។

## បវត្តិវារៈ

ក្នុងការវិនិច្ឆ័យអត្ថនេះ គប្បីជ្រាបនយមុខនេះដូចតទៅ

[ ១១២ ] បទថា **សចក្ខុកានំ ន ឥត្ថីនំ** លោកពោលហើយ ដោយអំណាចនៃសត្វទាំងឡាយដែលមានរូប មានព្រហ្មបារិសជ្ជាជាដើម និងដោយអំណាចនៃបុរសភេទ និងបុគ្គលមិនមានភេទ ព្រោះថា ឥត្ថិន្ទ្រិយ រមែងមិនកើតដល់រូបព្រហ្ម បុរស និងបុគ្គលមិនមានភេទ ( ឡើយ ) ទាំងនោះ ។

[ ១១៣ ] បទថា **សចក្ខុកានំ ន បុរិសានំ** លោកពោលហើយដោយអំណាចនៃរូបព្រហ្មផង នៃស្ត្រីភេទ និងបុគ្គលដែលមិនមានភេទផង ព្រោះថា បុរិសិន្ទ្រិយ រមែងមិនកើតដល់រូបព្រហ្ម ស្ត្រី និងបុគ្គលមិនមានភេទទាំងនោះ ។

[ ១១៤ ] បទថា **អចក្ខុកានំ ឧបបជ្ជន្តានំ តេសំ ជីវិតិន្ទ្រិយំ ឧប្បជ្ជតិ** លោកពោលសំដៅយកសត្វទាំងឡាយ ក្នុងឯកវោការភព ចតុវោការភព និងក្នុងកាមធាតុ ។

[ ១១៥ ] បទថា **សចក្ខុកានំ វិនា សោមនស្សេន** លោកពោលហើយ ដោយអំណាចនៃបុគ្គលដែលបដិសន្ធិ ដោយមហាវិបាកបដិសន្ធិ ៤ ដែលសហគតៈដោយឧបេក្ខា ។

[ ១១៦ ] បទថា **សចក្ខុកានំ វិនា ឧបេក្ខាយ** លោកពោលដោយ

អំណាចនៃបុគ្គលដែលបដិសន្ធិ សហគតៈដោយសោមនស្ស ។ បទថា **ឧបេក្ខាយ អចក្ខុកានំ** លោកពោលដោយអំណាចនៃអហេតុកបដិសន្ធិ ។

[ ១១៧ ] បទថា **អហេតុកានំ** លោកពោលហើយ ព្រោះការមិនមាននៃឥន្ទ្រិយទាំងឡាយ មានសទ្ធិន្ទ្រិយជាដើម មួយអន្លើដោយអហេតុក-បដិសន្ធិ ។

ពិតហើយ ក្នុងអហេតុកបដិសន្ធិ រមែងមិនមានសទ្ធា សតិ បញ្ញា ពិតប្រាកដ ឯសមាធិ និងវីរិយៈ រមែងមិនដល់នូវភាពជាឥន្ទ្រិយ ។

បទថា **សហេតុកានំ អចក្ខុកានំ** លោកពោលហើយដោយអំណាច គព្ភសេយ្យកសត្វ និងព្រហ្មដែលមិនមានរូប ។ ពិតហើយ ពួកសហេតុកៈ ដទៃ ឈ្មោះថា **អចក្ខុកោ** ប្រែថា មិនមានចក្ខុនោះ មិនមានឡើយ ។

បទថា **សចក្ខុកានំ អហេតុកានំ** លោកពោលសំដៅយកសត្វក្នុង អបាយ ដោយអំណាចនៃឱបបាតិកៈ ។

[ ១១៨ ] បទថា **សចក្ខុកានំ ញាណវិប្បយុត្តានំ** លោកពោល សំដៅយកសត្វដែលបដិសន្ធិដោយហេតុ ២ ក្នុងកាមធាតុ ។

បទថា **សចក្ខុកានំ ញាណសម្បយុត្តានំ** លោកពោលសំដៅយក ព្រហ្មផង ទេវតា និងមនុស្ស ក្នុងកាមាវចរផង ។

បទថា **ញាណសម្បយុត្តានំ អចក្ខុកានំ** លោកពោលសំដៅយក អរូបព្រហ្ម និងតិហេតុកសត្វ ដែលកើតក្នុងស្ថានសួគ៌ ។

[ ១៤១ ] ក្នុងជីវិតិន្ទ្រិយមូល បទថា **វិនា សោមនស្សេន ឧប-**

**បដ្ឋន្តានំ** *លោកពោលសំដៅយកជីវិតិន្ទ្រិយទាំង ២ យ៉ាង ។*

*បទថា* **បវត្តេ សោមនស្សវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ** *លោកពោលសំដៅយកអរូបជីវិតិន្ទ្រិយ ។*

*គប្បីជ្រាបការប្រកបជីវិតិន្ទ្រិយដោយអំណាចនៃបដិសន្ធិ និងបវត្តិក្នុងទីទាំងពួងដោយន័យនេះ សូម្បីក្នុងមូលទាំងឡាយ មានសោមនស្សិន្ទ្រិយជាមូលជាដើម គប្បីកាន់យកអត្ថ ដោយអំណាចនៃបដិសន្ធិ និងបវត្តិនោះឯង តែក្នុងបដិលោមន័យ ក្នុងនិរោធវារៈ គប្បីជ្រាបការកើត ការមិនកើត ការរលត់ និងការមិនរលត់ ក្នុងចុតិ បដិសន្ធិ និងបវត្តិទាំង ៣ កាល ដោយអំណាចនៃធម៌ទាំងឡាយនោះផង ពួកជនទៃផង តាមដែលបាន ។*

[ ៤៦១ ] *ក្នុងអនាគតវារៈ បទថា* **ឋានេវ ភាវេន** *ដូច្នេះ អធិប្បាយថា ដោយការកាន់យកបុរិសបដិសន្ធិនោះឯង ព្រោះមិនដល់នូវឥត្ថីភាវៈក្នុងចន្លោះ ដោយបុរិសភាវៈនោះឯង ។*

*ពាក្យវិសជ្ជនាថា* **កតិចិ ភវេ ទស្សេត្វា បរិនិព្វាយិស្សន្តិ** *អធិប្បាយថា បុរសណា កាន់យកហើយ នូវបដិសន្ធិក្នុងភូមិណាមួយ មិនដល់ហើយនូវឥត្ថីភាវៈនោះឯង នឹងបរិនិព្វាន ( សេចក្តីថា កើតក្នុងភពណា ដោយភេទណា នឹងបរិនិព្វានដោយភេទនោះ ក្នុងភពនោះ ) ។*

*ក្នុងបញ្ហាទី ២ ក៏ន័យនេះដូចគ្នា ។ បទថា* **សុទ្ធាវាសានំ ឧបបត្តិចិត្តស្ស ភង្គក្ខណេ មនិន្ទ្រិយញ្ច នុប្បជ្ជិត្ថ**[១] *មនិន្ទ្រិយរបស់សុទ្ធាវាសសត្វ*

*១- បទនេះ បិដកខ្មែរ មិនមាន ។*

ទាំងនោះ មិនកើតឡើងហើយ ក្នុងកង្គក្ខណៈនៃឧបបត្តិចិត្ត ដូច្នេះ ក្នុងអតីតវារៈ ដោយបច្ចុប្បន្នវារៈ ( បច្ចុប្បន្នាតីតវារៈ ) អធិប្បាយថា បណ្ឌិតមិនគួរកាន់យកអត្ថ ដោយអំណាចការឈានកន្លងឧប្បាទក្ខណៈ ដូចក្នុងចិត្តយមកៈ តែគួរកាន់យកដោយអំណាចនៃការមិនកើតឡើងហើយ ក្នុងភពនោះ ។ គប្បីជ្រាបការវិនិច្ឆ័យអត្ថ ក្នុងបវត្តិវារៈទាំងអស់ ដោយនយមុខនេះ ។

## បរិញ្ញាវារៈ

[ ៣២៣ ] ក្នុងបរិញ្ញាវារៈ លោកសម្តែងចក្ខុសោតយមកៈតែម្យ៉ាងប៉ុណ្ណោះ ក្នុងមូលទាំងឡាយ មានចក្ខុមូលជាដើម ។ ឥន្ទ្រិយទាំងឡាយដ៏សេស ដែលជាលោកិយអព្យាកតៈផង ដែលលាយឡំដោយលោកិយ-អព្យាកតៈផង ជាឥន្ទ្រិយដែលគួរកំណត់ដឹងដូចគ្នា ព្រោះហេតុនោះ ឥន្ទ្រិយទាំងនោះ សូម្បីលោកមិនសម្តែង ក៏ឈ្មោះថា សម្តែងដោយន័យនេះឯង ។ អកុសល ជាធម៌ដែលបុគ្គលគប្បីលះដោយចំណែកមួយប៉ុណ្ណោះ កុសលគប្បីចម្រើនដោយចំណែកមួយ លោកុត្តរដែលជាអព្យាកតៈ ដែលបុគ្គលគប្បីធ្វើឲ្យជាក់ច្បាស់ ព្រោះហេតុនោះ ទើបលោកពោលថា លះបង់នូវទោមនស្សិន្ទ្រិយ ចម្រើននូវអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ធ្វើឲ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ ចំណែកអញ្ញិន្ទ្រិយ បុគ្គលគួរចម្រើនក៏មាន គួរធ្វើឲ្យជាក់ច្បាស់ក៏មាន អញ្ញិន្ទ្រិយនោះ លោកកាន់យកដោយអំណាចភាវនា គឺការធ្វើឲ្យចម្រើននោះឯង ។

[ ៣២៤ ] ក្នុងបទទាំងឡាយនោះ បទថា **ទេ្វ បុគ្គលា** បានដល់

បុគ្គលដែលដល់ព្រមដោយសកទាគាមិមគ្គ និងដល់ព្រមដោយអរហត្តមគ្គ ក្នុងបុគ្គលទាំង ២ នោះ បុគ្គលម្នាក់ ឈ្មោះថា មិនមែនកំពុងលះទោមនស្សិន្ទ្រិយ ព្រោះមិនអាចកាត់ផ្តាច់បាន បុគ្គលម្នាក់ ឈ្មោះថា មិនមែនកំពុងលះទោមនស្សិន្ទ្រិយ ព្រោះភាពដែលលោកលះទោមនស្សិន្ទ្រិយហើយ ។

[ ៣៣៨ ] បទថា **ចក្ខុន្ទ្រិយំ ន បរិជានាតិ** បានដល់ មិនមែនកំពុងកំណត់ដឹង ព្រោះភាពដែលលោកមិនអាចញ៉ាំងមគ្គ ដែលមិនទាន់កើត ឲ្យកើតឡើងបាន បណ្ឌិតគប្បីជ្រាបអត្ថក្នុងពាក្យវិសជ្ជនាទាំងពួង ដោយន័យនេះឯង ។l៙៚

**បរិញ្ញាវារៈ ចប់**

**អដ្ឋកថាឥន្ទ្រិយយមកៈ ចប់**

# និគមនកថា

បុរស ស្ត្រីណា ដល់ព្រមដោយកិច្ច តាំងនៅក្នុងឱវាទរបស់ព្រះសាស្ដាសម្មាសម្ពុទ្ធអង្គណា ដែលធ្វើកិច្ចស្រេចហើយ បុរស ស្ត្រីនោះ កំណត់តាំងមាំនៅក្នុងឱវាទរបស់ព្រះមុនីល្អហើយ រមែងជាអ្នកឈានកន្លងអំណាចរបស់ស្ដេចយម ព្រះសម្មាសម្ពុទ្ធ ទ្រង់ជាទេវតាក្រៃលែងជាងទេវតាទាំងពួង ដែលមិនមាននូវមន្ទិល ដែលនាំទៅកាន់អំណាចរបស់ស្ដេចយម ទ្រង់គង់កណ្ដាលមហាទេវបរិស័ទ ក្នុងទេវបុរី ទ្រង់ប្រកាសបករណ៍ ឈ្មោះយមកៈណា ខ្ញុំ ( ពុទ្ធឃោសាចារ្យ ) ប្រារព្ធអដ្ឋកថានៃបករណ៍យមកៈនោះ ដើម្បីសម្ដែងវិធីកំណត់ព្រះបាលី និងន័យរបស់អត្ថ ក្នុងពាក្យបុច្ឆាវិសជ្ជនា ។

ឥឡូវនេះ អដ្ឋកថានៃបករណ៍នោះ ដល់នូវការសម្រេចហើយ ដោយបែបផែន មានប្រមាណ ៥ ភាណវារៈ ដោយប្រាសចាកអន្តរាយក្នុងលោកដែលមានអន្តរាយច្រើន យ៉ាងណា ចូរសត្វទាំងឡាយ ជាអ្នកមានការសម្រេចក្នុងហិតានុហិតប្រយោជន៍ ដល់ព្រមដោយសេចក្ដីសុខ ចូរមនោរថទាំងពួងរបស់សព្វសត្វ ដល់នូវសេចក្ដីសម្រេចយ៉ាងនោះហោង ។

## អដ្ឋកថា យមកប្បករណ៍ ចប់

# ក្បាលទី ៧៤

# អភិធម្មបិដក ចាលីប្រែ ~៩២

## យមក ចដ្ឋភាគ

## ឥន្ទ្រិយយមកៈ

### *សន្ទឹកចង្អុលប្រាប់មាតិកា*


| *មាតិកា* | | *លេខទំព័រ* |
|---|---|---|
| *អភិធម្មបិដក បណ្ណត្តិវារៈ* | ...... ...... ...... ...... ...... | ២ |
| *អភិធម្មបិដក ឧទ្ទេស* | ...... ...... ...... ...... ...... | ២ |
| *អភិធម្មបិដក និទ្ទេសវារៈ* | ...... ...... ...... ...... ...... | ២០ |
| *អភិធម្មបិដក បវត្តិវារៈ* | ...... ...... ...... ...... ...... | ៦៧ |


## ចាលីប្រែ ~៩៣

## ឥន្ទ្រិយយមកៈ


| | | |
|---|---|---|
| *អភិធម្មបិដក បវត្តិវារៈ* | ...... ...... ...... ...... ...... | ២៨៧ |
| *អភិធម្មបិដក បរិញ្ញាវារៈ* | ...... ...... ...... ...... ...... | ៤៨៣ |
| *អដ្ឋកថាឥន្ទ្រិយយមកៈ* | ...... ...... ...... ...... ...... | ៥២៨ |
| *អដ្ឋកថាបវត្តិវារៈ* | ...... ...... ...... ...... ...... | ៥៣០ |
| *អដ្ឋកថាបរិញ្ញាវារៈ* | ...... ...... ...... ...... ...... | ៥៣៣ |
| *និគមគាថា* | ...... ...... ...... ...... ...... | ៥៣៥ |